**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការវិនិយោគមូលបត្រនៅកម្ពុជា

កម្មសិក្សាចាប់ពីថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០២០ ដល់ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ២០២០

ឈ្មោះស្ថាប័ន៖ **គណៈកម្មការមូលបត្រកម្ពុជា**


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **វង្ស សុភាព**

**ហេង សុខលាភ**

សាស្ត្រាចារ្យណែនាំ

លោក **ឈាង ហ៊ុយ**


ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ

ជំនាន់ទី ១៣

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេររបាយការណ៍ ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ វង្ស សុភាព និងហេង សុខលាភ ជានិស្សិតថ្នាក់បរិញ្ញាបត្រធនាគារនិងហិរញ្ញវត្ថុជំនាន់ទី១៣ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៩-២០២០ បានធ្វើរបាយការណ៍សារណាបញ្ចប់ការសិក្សាស្រាវជ្រាវលើប្រធានបទ **“ការវិនិយោគមូលបត្រនៅកម្ពុជា”**។ យើងខ្ញុំសូមធ្វើការបង្ហាញពីសេចក្តីដឹងគុណ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖

- លោកឪពុក អ្នកម្តាយជាអ្នកមានគុណទាំងពីរ ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ មើលថែរក្សា ប្រៀនប្រដៅអប់រំទូន្មាន ដោយបំណងល្អ និងប្រកបដោយភាពកក់ក្តៅ សេចក្តីស្រឡាញ់ ក្នុងគោលបំណងឲ្យកូនគ្រប់រូបដើរតាមគន្លងធម៌ និងមានអនាគតភ្លឺស្វាងប្រកបដោយចំណេះដឹងជ្រៅជ្រះ។
- ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស និងព្រឹទ្ធបុរសរង ដែលបានបង្រៀនប្រៀនប្រដៅអប់រំទូន្មាន ផ្តល់ចំណេះដឹង ព្រមទាំងផ្តល់ឱកាសដល់យើងខ្ញុំ និងនិស្សិតដទៃធ្វើការស្រាវជ្រាវក្នុងគោលបំណងបង្កើនចំណេះដឹងឲ្យកាន់តែស៊ីជម្រៅអំពីប្រធានបទស្រាវជ្រាវ។
- លោកសាស្រ្តាចារ្យ ឈាង ហ៊ុយ ដែលបានដឹកនាំយើងខ្ញុំ ដោយផ្តល់ជាមតិយោបល់ ផ្តល់នូវគំនិតស្ថាបនា ហើយជួយកែលម្អ ដើម្បីធ្វើឲ្យរបាយការណ៍នេះកាន់តែមានភាពល្អប្រសើរឡើង។
- លោកសាស្រ្តាចារ្យ កែប សំភី និងបុគ្គលិកនៅគណៈកម្មការមូលបត្រកម្ពុជា ដែលបានជួយណែនាំ ផ្តល់យោបល់ ក៏ដូចជាផ្តល់ឯកសារនានា ដែលពាក់ព័ន្ធនឹងរបាយការណ៍កម្មសិក្សានេះ។
- លោក និងលោកស្រីសាស្រ្តាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ជាពិសេស លោក និងលោកស្រីសាស្រ្តាចារ្យផ្នែកធនាគារ និងហិរញ្ញវត្ថុដែលបានចំណាយពេលវេលាបង្រៀនខ្ញុំដោយយកចិត្តទុកដាក់ ខិតខំអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីឲ្យនិស្សិតយល់ដឹងបានច្រើន។
- មិត្តនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ផ្នែកធនាគារ និងហិរញ្ញវត្ថុជំនាន់ទី១៣ទាំងអស់ និងរៀមច្បង ដែលបានជួយគាំទ្រយើងខ្ញុំក្នុងដំណើរការស្រាវជ្រាវនេះ។

ជាចុងបញ្ចប់ យើងខ្ញុំសូមគោរពជូនពរដល់បុគ្គលដែលមានគុណឱ្យមានសុខភាពល្អ ទទួលបានជោគជ័យទាំងក្នុងវិស័យការងារ និងក្រុមគ្រួសារ និងបានជួបតែពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំជានិស្សិតជំនាន់ទី ១៣ ជំនាញធនាគារនិងហិរញ្ញវត្ថុនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៩-២០២០ បានធ្វើការចុះស្រាវជ្រាវ និងចងក្រងកិច្ចការស្រាវជ្រាវនេះឡើងក្នុងគោលបំណងដើម្បីផ្តល់ជាចំណេះដឹងនិងព្រមទាំងមូលដ្ឋានគ្រឹះសំខាន់ៗទាក់ទងនឹងវិស័យហិរញ្ញវត្ថុ ជាពិសេសវិស័យមូលបត្រនៅក្នុងប្រទេសកម្ពុជាទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែង ដល់សិស្សប្អូនជំនាន់ក្រោយ ហើយយើងខ្ញុំក៏សង្ឃឹមថាកិច្ចការស្រាវជ្រាវនេះនឹងផ្តល់ជាប្រយោជន៍ និងចំណេះដឹងដល់អ្នកអានផងដែរ។

ក្នុងការស្រាវជ្រាវប្រធានបទស្តីពី "**ការវិនិយោគមូលបត្រនៅកម្ពុជា**" នេះគឺបានផ្តោតសំខាន់ទៅលើវិស័យមូលបត្រក្នុងប្រទេសកម្ពុជាដែលរួមមានទ្រឹស្តីដែលពាក់ព័ន្ធនឹងមូលបត្រ ដំណើរការនៃការបោះផ្សាយលក់មូលបត្រ ដំណើរការនៃការជួញដូរមូលបត្រ និងការវិនិយោគមូលបត្របំណុលក្នុងទីផ្សារមូលបត្រកម្ពុជា។ យើងខ្ញុំបានខិតខំប្រឹងប្រែងទាំងកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីសរសេររបាយការណ៍បញ្ចប់ការសិក្សាមួយនេះឡើង។

ជាចុងបញ្ចប់ យើងខ្ញុំសង្ឃឹមថាកិច្ចការស្រាវជ្រាវនេះនឹងផ្តល់ជាប្រយោជន៍ពត៌មាន និងចំណេះដឹងដល់អ្នកអាន ជាពិសេសវិនិយោគិន។ យើងខ្ញុំសូមអភ័យទោសរាល់កំហុសឆ្គង ដែលកើតមានដោយអចេតនា។ ដូចនេះយើងខ្ញុំនឹងចាំទទួលនូវការរិះគន់ដោយស្ថាបនាអំពីកំហុសខុសឆ្គងទាំងឡាយដោយសេចក្តីពេញចិត្ត ហើយយើងខ្ញុំនឹងធ្វើការកែប្រែឱ្យកាន់តែល្អប្រសើរឡើង។

# មាតិកា

បញ្ជីអក្សរកាត់ ...................................................................................... vi
បញ្ជីតារាង ...................................................................................... vii
បញ្ជីរូបភាព ...................................................................................... viii
បញ្ជីឧបសម្ព័ន្ធ ...................................................................................... ix

## សេចក្តីផ្តើម

១.លំនាំបញ្ហានៃការស្រាវជ្រាវ ...................................................................................... ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ...................................................................................... ២
៣. គោលបំណងនៃការស្រាវជ្រាវ ...................................................................................... ២
៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ...................................................................................... ៣
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ...................................................................................... ៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ ...................................................................................... ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ...................................................................................... ៤

## ជំពូកទី ១
## រំលឹកទ្រឹស្តី

១.១. និយមន័យមូលបត្រ ...................................................................................... ៥
១.២. ប្រភេទមូលបត្រ ...................................................................................... ៥
១.២.១. មូលបត្រកម្មសិទ្ធិ ...................................................................................... ៥
១.២.២. មូលបត្របំណុល ...................................................................................... ៧
១.២.២.១ ការចេញផ្សាយប័ណ្ណរតនាគាររយៈពេលខ្លី ( Treasury Bill ) ...................................................................................... ៨
១.២.២.២ មូលបត្រអាចជួញដូរ ( NCD ) ...................................................................................... ៨
១.២.២.៣ ប្រតិបត្តិការណ៍ផ្តល់សន្ទីភាពដោយមានការធានា ( LPCO ) ...................................................................................... ១០
១.២.២.៤ សញ្ញាបណ្ណសាជីវកម្ម ( Corporate Bond ) ...................................................................................... ១១
១.២.៣. ឧបករណ៍និស្សន្ទ ...................................................................................... ១១
១.៣. ទីផ្សារមូលបត្រ ...................................................................................... ១២
១.៤. អត្ថប្រយោជន៍ទីផ្សារមូលបត្រ ...................................................................................... ១២
១.៥. គុណវិបត្តិរបស់ទីផ្សារមូលបត្រ ...................................................................................... ១៣

១.៦. អ្នកចូលរួមក្នុងទីផ្សារមូលបត្រ ........ ១៤
១.៦.១ តួអង្គលើទីផ្សារដំបូង........ ១៤
១.៦.១.១. ក្រុមហ៊ុនធានាទិញមូលបត្រ........ ១៥
១.៦.១.២. ក្រុមហ៊ុនបោះផ្សាយមូលបត្រ........ ១៦
១.៦.១.៣. វិនិយោគិន ........ ១៦
១.៦.២. តួអង្គក្នុងទីផ្សារបន្ទាប់........ ១៧
១.៦.២.១ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា........ ១៧
១.៦.២.២ វិនិយោគិន ........ ១៩
១.៦.២.៣ ក្រុមហ៊ុនមូលបត្រ ........ ១៩
១.៦.២.៤ អន្តរការីទីផ្សារ........ ១៩
១.៦.៣. តួអង្គចូលរួមដទៃទៀត ........ ២២
១.៦.៣.១. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ........ ២២
១.៦.៣.២. ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ........ ២២
១.៦.៣.៣. ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ........ ២៣
១.៦.៣.៤. ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃនិងអ្នកវាយតម្លៃឯករាជ្យ ........ ២៤
១.៦.៣.៥. ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល........ ២៥

## ជំពូកទី ២

## គណៈកម្មការមូលបត្រកម្ពុជា

២.១. ប្រវត្តិនៃការបង្កើតគណៈកម្មការមូលបត្រកម្ពុជា ........ ២៧
២.២ រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញាបស់គណៈកម្មការមូលបត្រកម្ពុជា........ ២៧
២.២.១. រូបសញ្ញា........ ២៧
២.២.២. អត្ថន័យនៃរូបសញ្ញា ........ ២៨
២.៣. ចក្ខុវិស័យ និងបេសកម្ម ........ ២៩
២.៣.១ ចក្ខុវិស័យ ........ ២៩
២.៣.២ បេសកម្ម ........ ៣០
២.៤. គោលដៅ និងគោលបំណង........ ៣០
២.៥. រចនាសម្ព័ន្ធ........ ៣១

២.៦. សមាជិករបស់គណៈកម្មការមូលបត្រកម្ពុជា អាណត្តិទី២ (២០១៣-២០១៨)......................................៣១
២.៧. មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា......................................................................៣២
២.៨. មុខងារ និងតួនាទីនាយកដ្ឋានរបស់គណៈកម្មការមូលបត្រកម្ពុជា......................................... ៣៣
២.៨.១ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ......................................................................... ៣៣
២.៨.២ នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ...................................................... ៣៣
២.៨.៣. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ..................................................................៣៤
២.៨.៤. នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ....................................................................៣៥
២.៨.៥ នាយកដ្ឋានកិច្ចការគតិយុត្ត ..................................................................................៣៦
២.៨.៦ នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ ....៣៦
២.៨.៧. អង្គភាពសវនកម្មផ្ទៃក្នុង ......................................................................................... ៣៧

## ជំពូកទី ៣

## ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

៣.១. ប្រវត្តិ ផ.ម.ក...................................................................................................................៣៩
៣.២. ចក្ខុវិស័យ និងបេសកម្ម...........................................................................................................៣៩
៣.៣. រចនាសម្ព័ន្ធគ្រប់គ្រង ............................................................................................................ ៤០
៣.៤. ក្រុមប្រឹក្សាភិបាល ................................................................................................................ ៤០
៣.៥. សមាជិក............................................................................................................................ ៤១

## ជំពូកទី៤

## ការវិនិយោគមូលបត្រនៅកម្ពុជា

៤.១. ការជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រកម្ពុជា................................................................. ៤២
៤.២. ការវិនិយោគមូលបត្រកម្មសិទ្ធិ ...............................................................................................៤៣
៤.២.១. ដំណាក់កាលទី១ ការត្រៀមខ្លួនមុននឹងជួញដូរ .........................................................៤៣
៤.២.១.១. ការជ្រើសរើសក្រុមហ៊ុនមូលបត្រ...........................................................................៤៣
៤.២.១.២. ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន (Investor ID)................................៤៣
៤.២.១.៣. ការបើកគណនីជួញដូរ............................................................................... ៤៤
៤.២.២. ការជួញដូរភាគហ៊ុននៅទីផ្សារដំបូង.............................................................................៤៤
៤.២.៣ ការជួញដូរ (ទិញ-លក់) ភាគហ៊ុននៅទីផ្សារបន្ទាប់........................................................ ៤៥

៤.២.៣.១. ការដាក់បញ្ជា និងនីតិវិធីក្នុងការជួញដូរ ........................................................ ៤៥
៤.២.៣.២. ម៉ោងជួញដូរ ......................................................................................................... ៤៧
៤.២.៣.៣.ប្រភេទនៃបញ្ជា.................................................................................................... ៤៧
៤.២.៣.៤. ឯកតាជួញដូរ/ឯកតាថ្លៃ ....................................................................................... ៤៨
៤.២.៣.៥. ដែនប្រែប្រួលថ្លៃប្រចាំថ្ងៃ ....................................................................................... ៤៩
៤.២.៣.៦. វិធីសាស្ត្រជួញដូរ.................................................................................................. ៤៩
៤.២.៣.៧. យន្តការនៃការផាត់ទាត់ និងការទូទាត់ .............................................................. ៥១
៤.២.៣.៨. យន្តការនៃការរក្សាទុកមូលបត្រ ........................................................................... ៥៣
៤.២.៣.៩. ការលើកទឹកចិត្តផ្នែកពន្ធ ....................................................................................... ៥៤
៤.៣. ការវិនិយោគមូលបត្របំណុល................................................................................................... ៥៦
៤.៣.១. និយមន័យ ................................................................................................................. ៥៦
៤.៣.២. អំពីទីផ្សារសញ្ញាបណ្ណ.................................................................................................. ៥៦
៤.៣.៣. វិធីសាស្ត្រជួញដូរ ......................................................................................................... ៥៧
៤.៣.៤.វិធានផ្សេងៗទាក់ទងនឹងការជួញដូរមូលបត្របំណុល .................................................... ៥៧
៤.៣.៥. ភាពខុសគ្នារវាងការវិនិយោគសញ្ញាបណ្ណនិងភាគហ៊ុន.................................................. ៥៨
៤.៤. សកម្មភាពជួញដូរភាគហ៊ុនរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្របំណុល ត្រីមាសទី៤ ២០១៩ ........ ៥៩
៤.៤.១.គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត (HKL) .................................................. ៥៩
៤.៤.២. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូ សុិ (LOLC) ................................................................... ៥៩
៤.៤.៣. ធនាគារវឌ្ឍនៈ អាសុីចំកាត់ (ABA)................................................................................. ៥៩
៤.៥. ជួញដូរភាគហ៊ុនរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ត្រីមាសទី៤ ២០១៩................................... ៦០
៤.៥.១.ភាគហ៊ុនរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PWSA) ....................................................... ៦០
៤.៥.២.-ភាគហ៊ុនរបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន អុិនធើណេសិនណល (ខេមបូឌា) ភីអិលសុី (GTI) ..... ៦១
៤.៥.៣.-ភាគហ៊ុនរបស់កំពង់ផែស្វយ័តភ្នំពេញ (PPAP) ................................................................ ៦១
៤.៥.៤.-ភាគហ៊ុនរបស់ភ្នំពេញអេសអុីហ្សិត ភីអិលសុី (PPSP) ..................................................... ៦២
៤.៥.៥.-ភាគហ៊ុនរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS) ...................................................... ៦៣

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន.................................................................................................................. ៦៤

២. អនុសាសន៍.....................................................................................................................៦៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- គ.ម.ក = គណៈកម្មការមូលបត្រកម្ពុជា
- ផ.ម.ក = ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- CCP = Central Counter Party
- CSO = Clearing and Settlement operator
- CSX = Cambodia Securities Exchange
- IPO = Initial Public offering
- NBC = National Bank of Cambodia
- SECC = Securities and Exchange Commission of Cambodia
- SF = Securities Firm

# បញ្ជីតារាង

- តារាងទី ១ ៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PWSA......................................................................៥៩
- តារាងទី ២ ៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន GTI.........................................................................៦០
- តារាងទី ៣ ៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PPAP......................................................................៦០
- តារាងទី ៤. ៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PPSP.....................................................................៦១
- តារាងទី ៥ ៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PAS.........................................................................៦២

# បញ្ជីរូបភាព


- រូបភាពទី ១ ៖ តួអង្គលើទីផ្សារដំបូង ........ ១៨
- រូបភាពទី ២ ៖ រូបសញ្ញានៃគ.ម.ក ........ ២៨
- រូបភាពទី ៣ ៖ ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា ........ ២៩
- រូបភាពទី ៤ ៖ រចនាសម្ព័ន្ធចាត់តាំងរបស់គណៈកម្មការមូលបត្រកម្ពុជា ........ ៣១
- រូបភាពទី ៥៖ រចនាសម្ព័ន្ធគ្រប់គ្រង ផ.ម.ក. ........ ៣៩
- រូបភាពទី ៦៖ ក្រុមប្រឹក្សាភិបាល ផ.ម.ក. ........ ៣៩
- រូបភាពទី ៧ ៖ ការដាក់បញ្ជា និងនីតិវិធីក្នុងការជួញដូរ ........ ៤៦
- រូបភាពទី ៨ ៖ ពេលវេលានៃការជួញដូរនៅទីផ្សារមូលបត្រកម្ពុជា ........ ៤៦
- រូបភាពទី ៩ ៖ យន្តការនៃការផាត់ទាត់ និងការទូទាត់ ........ ៥១

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ អនុក្រឹត្យស្តីពី ការលើកទឹកចិត្តពន្ធដារ ក្នុងវិស័យមូលបត្រ
ឧបសម្ព័ន្ធទី២៖ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
ឧបសម្ព័ន្ធទី៣៖ ប្រកាសស្តីពី គោលការណ៍ណែនាំស្តីពី ការធ្វើប៉ុកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

តាមរយៈការដាក់ចេញនូវគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៏វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ការអភិវឌ្ឍន៏វិស័យហិរញ្ញវត្ថុបានក្លាយជារបៀបវីរៈអាទិភាពមួយក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមនៅកម្ពុជា។ ក្នុងពេលជាមួយគ្នានេះដែរ មានប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍជាច្រើនបានប្រឹងប្រែងពង្រឹងវិស័យហិរញ្ញវត្ថុដែលជាផ្នែកមួយយ៉ាងសំខាន់ដែលជំរុញអោយសេដ្ឋកិច្ចជាតិមានការរីកលូតលាស់។ ជាក់ស្តែង កម្ពុជាជាសមាជិកអាស៊ាន និងកំពុងស្ថិតក្នុងការធ្វើសមាហរណកម្មអាស៊ាន កម្ពុជាត្រូវតែធានាអោយបាននូវការអភិវឌ្ឍន៍ដែលប្រកបដោយចីរភាព និងស្ថេរភាព។

ដោយសង្កេតឃើញថា កំណើនសេដ្ឋកិច្ចនៅអត្រា ៧% ក្នុងអំឡុងប៉ុន្មានឆ្នាំចុងក្រោយនេះ បានធ្វើអោយប្រទេសកម្ពុជា កំពុងឈានទៅមុខជាលំដាប់។ ការស្ទុះឡើងនៃសេដ្ឋកិច្ចនេះ បានបង្កើតជាបរិយាកាសមួយដ៏ល្អ ដែលអាច ទាក់ទាញបានទាំងវិនិយោគិនក្នុងស្រុក និងក្រៅស្រុកឱ្យមកធ្វើការវិនិយោគ និងបណ្តាក់ទុនយ៉ាងសស្រាក់ សស្រាំក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយមានការផ្តួចផ្តើមពីរាជរដ្ឋាភិបាលកម្ពុជាលើគោលនយោបាយអភិវឌ្ឍវិស័យហិរញ្ញវត្ថុ យើងសង្កេតឃើញថាទីផ្សារមូលបត្រ បាននឹងកំពុងរីកលូតលាស់យ៉ាងខ្លាំងក្នុងសេដ្ឋកិច្ចកម្ពុជា ពីព្រោះប្រទេសកម្ពុជាអាចចាត់ទុកជាទីផ្សារមួយដ៏វ័យក្មេងក្នុងវិស័យនេះ ដែលជាហេតុធ្វើឱ្យវិនិយោគិនយល់ថាមានឱកាសទទួលបានផលចំណេញច្រើន។

លើសពីនេះទៅទៀត ដើម្បីផ្តល់នូវភាពរលូននៃដំណើរការរបស់ទីផ្សារមូលបត្រកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ត្រូវបានបង្កើតឡើង និងដើរតួយ៉ាងសំខាន់ក្នុងការតាក់តែងច្បាប់ស្តីពីការប្រព្រឹត្តទៅនូវទីផ្សារមូលបត្រ លក្ខខណ្ឌក្នុងការចូលរួម នីតិវិធីក្នុងការជួញដូរមូលបត្រ ធ្វើការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មានដល់សាធារណជនតាមរយៈបណ្តាញសង្គម និងលើគេហទំព័ររបស់ខ្លួន។ ក្រោយមក ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក) ត្រូវបានបង្កើតឡើងដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធ ផាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុមូលបត្រ។ តាមរយៈការធ្វើសន្និសិទ្ធសិក្ខាសាលាបណ្តុះបណ្តាលព្រឹត្តិការណ៍នានា កម្មវិធីប្រកួតប្រជែងទាក់ទងនឹងមូលបត្រ យើងឃើញថា វិស័យនេះ ទទួលបានការចាប់អារម្មណ៍ច្រើនពីសាធារណជន និងក្រុមហ៊ុនឯកជនជាច្រើន។ ម្យ៉ាងទៀតកាទាក់ទាញនេះ បានធ្វើឱ្យមហាជនចង់ដឹងចង់លឺពីដំណើរការ និងនីតិវិធីក្នុងការជួញដូរមូលបត្រ ជាពិសេសជំរុញការជួញដូរ មូលបត្រឱ្យកាន់តែមានចលនាក្នុងទីផ្សារមូលបត្រកម្ពុជា។ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ក្រុមហ៊ុន រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWSA) បានឡើងទីផ្សារមូលបត្រដោយជោគជ័យមុនគេ។ ការប្រព្រឹត្ត ដូចនេះ បានជំរុញឱ្យមាន

ការចូលរួមពីក្រុមហ៊ុនឯកជនមួយចំនួនជាបន្តបន្ទាប់ និងការត្រៀមខ្លួនក្រុមហ៊ុន មួយចំនួនទៀត ដើម្បីឡើងទីផ្សារមូលបត្រ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

វិស័យមូលបត្រត្រូវបានចាត់ទុកជាកាតាលីករមួយរបស់សេដ្ឋកិច្ច ព្រោះវាជាមធ្យោបាយមួយក្នុងការកៀងគរមូលធនសម្រាប់ផ្តល់ជាហិរញ្ញប្បទានដល់ការវិនិយោគគ្រប់ប្រភេទ។ អាស្រ័យហេតុនេះហើយទើបធ្វើអោយការ រីកលូតលាស់នៃវិស័យមូលបត្រគឺកត្តាចាំបាច់ដែលត្រូវយកចិត្តទុកដាក់ ដើម្បីពង្រឹងនូវការប្រកួតប្រជែង សេដ្ឋកិច្ច ក្នុងស្រុក តាមតំបន់អាស៊ាន តាមតំបន់អាស៊ី និងពិភពលោក។ ដោយឡែកនៅប្រទេសកម្ពុជា បើ ទោះបីជាមានការជ្រោមជ្រែងពីរាជរដ្ឋាភិបាល ក្នុងការពង្រីកនូវវិស័យមូលបត្រក៏ពិតមែន យើងសង្កេត ឃើញថា ធនធានមនុស្សក្នុង វិស័យនេះនៅមានកម្រិត ស្ថាប័នពាក់ព័ន្ធនៅមានកង្វះខាតខាងបច្ចេកវិទ្យាក្នុងការគ្រប់គ្រង ឱ្យកាន់តែមានប្រសិទ្ធភាព ព្រោះវិស័យមូលបត្រទើបតែបង្កើតឡើងឱ្យដំណើរការ ដូចនេះហើយវិស័យនេះ នៅមានភាពវ័យក្មេង ហើយការលូតលាស់មិនទាន់ទូលំទូលាយនៅឡើយទេ។ មួយវិញទៀត ប្រជាជនកម្ពុជា ភាគច្រើនពុំទាន់បានយល់ឱ្យស៊ីជម្រៅអំពីដំណើរការនៃការជួញដូរមូលបត្រនៅលើទីផ្សារនៅឡើយទេ។ ដោយមើលឃើញនូវចំណុចខ្វះខាតទាំងនេះ ហើយទើបមានការសិក្សាលើប្រធានបទការវិនិយោគលើមូលបត្រ ដើម្បីឆ្លើយតមនឹងសំនួរដូចខាងក្រោម៖

- តើលក្ខខណ្ឌអ្វីខ្លះដែលវិនិយោគិនត្រូវត្រៀមខ្លួនមុននឹងធ្វើការវិនិយោគ?
- តើការទិញ-លក់មូលបត្រនៅលើទីផ្សារមូលបត្រនៅកម្ពុជាយ៉ាងដូចម្តេច?
- តើកត្តាអ្វីខ្លះដែលវិនិយោគិនត្រូវពិចារណាមុនធ្វើការវិនិយោគ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

របាយការណ៍សិក្សាស្រាវជ្រាវនេះ មានគោលបំណងរួមគឺសិក្សាលើពីការវិនិយោគលើមូលបត្រនៅកម្ពុជា ដោយឡែកការសិក្សាស្រាវជ្រាវនេះនឹងមានគោលបំណងជាក់លាក់ដូចខាងក្រោម៖

- ស្វែងយល់អំពីប្រភេទមូលបត្រ
- ស្វែងយល់ពីទីផ្សារមូលបត្រកម្ពុជា
- ស្វែងយល់អំពីគណៈកម្មការមូលបត្រកម្ពុជា
- យល់ដឹងពីដំណើរការនៃការជួញដូរមូលបត្រ( កម្មសិទ្ធិ និងបំណុល )
- ស្វែងយល់អំពីអ្នកចូលរួមក្នុងការទិញលក់មូលបត្រ

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

របាយការណ៍កម្មសិក្សានេះនឹងផ្តោតសំខាន់ទៅលើការវិនិយោគមូលបត្រនៅក្នុងទីផ្សារមូលបត្រកម្ពុជា និងការត្រៀមខ្លួនមុនពេលវិនិយោគ។ ទោះបីជាបច្ចុប្បន្ននេះមានឧបករណ៍ហិរញ្ញវត្ថុជាច្រើនដាក់ដំណើរការលើទីផ្សារក៏ដោយ ដោយឡែករបាយការណ៍កម្មសិក្សានេះ នឹងសិក្សាអំពីការជួញដូរលមូលបត្រតែ ២ ប្រភេទប៉ុណ្ណោះ គឺ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល ដោយប្រើប្រាស់ទិន្នន័យក្នុងឆ្នាំ ២០១៩ យកមកវិភាគ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

របាយការណ៍សិក្សាស្រាវជ្រាវលើប្រធានបទ « ការវិនិយោគមូលបត្រនៅកម្ពុជា » នេះនឹងត្រូវបានយកទៅវិភាគតាមបែបពិពណ៌នា (គុណវិស័យ) និងពឹងផ្អែកទាំងស្រុងលើប្រភពទិន្នន័យដែលមានស្រាប់ (បន្ទាប់បន្សំ) ដូចខាងក្រោម៖

- ការចុះកម្មសិក្សានៅគណៈកម្មការមូលបត្រកម្ពុជា
- ទិន្នន័យទទួលបានពីប្រព័ន្ធអ៊ីនធើណេតដែលពាក់ព័ន្ធនឹងការជួញដូចមូលបត្រ
- ព័ត៌មានទទួលបានពីគេហទំព័ររបស់ ផ.ម.ក., ផ.ម.ក. ក្រុមហ៊ុនមូលបត្រ និងភាគីពាក់ព័ន្ធ
- របាយការណ៍កម្មសិក្សាឬសារណាបញ្ចប់ការសិក្សាដែលពាក់ព័ន្ធនឹងប្រធានបទ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវអំពីប្រធានបទនេះមានអត្ថប្រយោជន៍ និងសារៈសំខាន់ជាច្រើនដូចដែលបានរៀបរាប់នៅខាងក្រោមនេះ

- ផ្តល់នូវចំណេះដឹងយ៉ាងទូលំទូលាយអំពីវិស័យមូលបត្រនៅកម្ពុជា ដោយផ្សារភ្ជាប់ជាមួយនឹងទ្រឹស្តី និងមេរៀនដែលបានរៀនរួចមក
- បង្កើននូវសមត្ថភាពក្នុងការស្រាវជ្រាវ និងចេះប្រមូលនូវទិន្នន័យថ្មីៗ ដើម្បីមកធ្វើជាភស្តុតាងក្នុងការតាក់តែងរបាយការណ៍កម្មសិក្សារនេះឡើង។
- ចេះវិភាគ និងរៀបចំឯកសារឱ្យមានសណ្តាប់ធ្នាប់ និងមានទំនួលខុសត្រូវចំពោះការងាររបស់ខ្លួន។
- រំលឹកឡើងវិញនូវទ្រឹស្តីដែលបានរៀន និងយល់ដឹងកន្លងមក។
- ស្គាល់ពាក្យបច្ចេកទេសថ្មីៗទាក់ទងនឹងវិស័យមូលបត្រ
- ផ្តល់ជាព័ត៌មាន និងឯកសារដល់សាធារណជន និងសិស្សប្អូនជំនាន់ក្រោយដែលមានបំណងចង់ដឹងលឺ ពីការវិនិយោគជួញដូរ មូលបត្រលើទីផ្សារកម្ពុជា
- ផ្តល់ជាឯកសារដល់ក្រុមហ៊ុនដែលត្រៀមខ្លួនបោះផ្សាយលក់មូលបត្រ និងវិនិយោគិនឱ្យយល់ដឹងពីដំណើរការទិញ-លក់មូលបត្រលើទីផ្សារកម្ពុជា។

- របាយការណ៍នៃការស្រាវជ្រាវនេះ ផ្តល់ជាគំនិតមួយចំនួនដល់ស្ថាប័នដែលពាក់ព័ន្ធ ដើម្បីធ្វើឱ្យប្រសើរឡើងនូវចំណុចខ្វះខាតមួយចំនួន ដែលជាបញ្ហាចោទទៅលើការប្រព្រឹត្តទៅនៃប្រតិបត្តិការរបស់ទីផ្សារសព្វថ្ងៃ។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីសម្រួលដល់ដំណើរការនៃការស្រាវជ្រាវ យើងបានបែងចែករបាយការណ៍នេះជា ៣ជំពូកដូចខាងក្រោម៖



# ជំពូក ១

# រំលឹកទ្រឹស្តី

# ជំពូកទី ១
# រំលឹកទ្រឹស្តី

## ១.១. និយមន័យមូលបត្រ

មូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុ គឺជាមូលបត្រដែលបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលផ្សេងទៀតដែលត្រូវបានអនុញ្ញាតិអោយបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយអនុលោមតាមច្បាប់។[1]

មូលបត្រទាំងនោះរួមមាន៖

- មូលបត្រកម្មសិទ្ធិ
- មូលបត្របំណុល
- ផលប្រយោជន៍ក្នុងគំរោងវិនិយោគរួម
- ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ
- ឧបករណ៍ហិរញ្ញវត្ថុដទៃទៀតដែលកំណត់ថាជាមូលបត្រ

ទោះបីជាមានឧបករណ៍ហិរញ្ញវត្ថុច្រើនប្រភេទក្តី ដោយឡែកមានតែមូលបត្រកម្មសិទ្ធិ, មូលបត្របំណុល និង ឧបករណ៍និស្សន្ទប៉ុណ្ណោះដែលបានដាក់អោយមានដំណើរការជួញដូរលើទីផ្សារមូលបត្រនៃព្រះរាជាណាចក្រកម្ពុជាក្នុងពេលបច្ចុប្បន្ន។

## ១.២. ប្រភេទមូលបត្រ

គេចែកមូលបត្រជា ៣ ប្រភេទ រួមមានមូលបត្រកម្មសិទ្ធិ មូលបត្របំណុល ឧបករណ៍និស្សន្ទ៖

### ១.២.១. មូលបត្រកម្មសិទ្ធិ

មូលបត្រកម្មសិទ្ធិ គឺសំដៅដល់ផលប្រយោជន៍ ឬសិទ្ធិស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលបរទេសប្រហាក់ប្រហែល ហើយរាប់បញ្ចូលទាំងភាគហ៊ុនដេលមានសិទ្ធិបោះឆ្នោត និងភាគហ៊ុនគ្មានសិទ្ធិបោះឆ្នោត ភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងភាគហ៊ុនបុរិមា។[2]

មូលបត្រកម្មសិទ្ធិ ជាប្រភេទមូលបត្រដែលត្រូវបានបោះផ្សាយដោយក្រុមហ៊ុនសាធារណៈដើម្បីគៀងគរមូលនិធិពីសាធារណៈជន។ លទ្ធផលដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនចុះបញ្ជី ជាធម្មតាអាចវាយតម្លៃបានតាមរយៈភាគលាភដែលភាគហ៊ុនិកទទួលបាន និងតាមរយៈថ្លៃភាគហ៊ុនដែលបានដាក់ថ្លៃលើទីផ្សារ។

[1] សុន្ទានុក្រម "ការអប់រំអំពីមូលបត្រ" http://www.secc.gov.kh/khmer/m75. (ចូលទស្សនាថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២០)
[2] សុន្ទានុក្រម "ការអប់រំអំពីមូលបត្រ" http://www.secc.gov.kh/khmer/m75. (ចូលទស្សនាថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២០)

មូលបត្រកម្មសិទ្ធិមាន ២ប្រភេទ៖

• ភាគហ៊ុនធម្មតា (Common Stock) ៖ ផ្តល់ឱ្យភាគហ៊ុនិកនូវសិទ្ធិបោះឆ្នោត និងត្រួតពិនិត្យលើការសម្រេចចិត្តមួយចំនួន។ ម្ចាស់ភាគហ៊ុនអាចទទួលបានភាគលាភទៅតាមការកើនឡើង ឬថយចុះនៃប្រាក់ចំណេញរបស់ក្រុមហ៊ុន។ អ្នកកាន់កាប់ភាគហ៊ុនប្រភេទនេះទទួលបានសិទ្ធិក្នុងការទិញភាគហ៊ុនថ្មីរបស់ក្រុមហ៊ុន នៅពេលដែលក្រុមហ៊ុនធ្វើការបង្កើនដើមទុនចុះបញ្ជីរបស់ខ្លួន។[3]

• ភាគហ៊ុនបុរិមា (Preferred Stock) ៖ ពុំមានសិទ្ធិក្នុងការបោះឆ្នោតឡើយ ប៉ុន្តែអាចទទួលបានភាគលាភចែកមុនម្ចាស់ភាគហ៊ុនធម្មតា នៅពេលដែលក្រុមហ៊ុនជួបប្រទះនូវភាពក្ស័យធន។[4]

➢ **អត្ថប្រយោជន៍នៃការជួញដូរភាគហ៊ុន**

ការជួញដូរភាគហ៊ុនផ្តល់អត្ថប្រយោជន៍ជាច្រើនដល់វិនិយោគិន ដូចជា៖

**(ក) ឱកាសវិនិយោគ និងប្រាក់ចំណេញ**

ជំនួសឱ្យ ឬ បន្ថែមលើការបើកអាជីវកម្មដោយខ្លួនឯង ការកាន់កាប់ភាគហ៊ុនផ្តល់ឱ្យវិនិយោគិន នូវឱកាសក្នុងការចូលរួមចំណែកក្នុងអាជីវកម្មមួយដែលមិនតម្រូវឱ្យមានជំនាញនិងបទពិសោធន៍ពាក់ព័ន្ធ ឬការតាមដានត្រួតពិនិត្យជាប់ជាប្រចាំឡើយ។ ទន្ទឹមនឹងនេះ ប្រាក់ចំណេញពីការជួញដូរ និងភាគលាភទទួលបានពីការកាន់កាប់ភាគហ៊ុនអាចមានចំនួនច្រើនលើសផលវិនិយោគដទៃទៀត។

**(ខ) លទ្ធភាពក្នុងការវិនិយោគដោយវិនិយោគិនតូចៗ**

ផ្សារភាគហ៊ុនអនុញ្ញាតឱ្យវិនិយោគិនដែលមានប្រាក់តិចតួច អាចក្លាយជាម្ចាស់(មួយផ្នែក)នៃក្រុមហ៊ុនធំៗ និងទទួលបានផលចំណេញដូចវិនិយោគិនជាអ្នកមាននិងជាស្ថាប័នផងដែរ ទៅតាមសមមាត្រភាគហ៊ុនដែលពួកគេកាន់កាប់។

**(គ) ការលើកទឹកចិត្តផ្នែកពន្ធ**

- មិនមានពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិពេលជួញដូរភាគហ៊ុន
- មិនមានពន្ធលើចំណេញមូលធន(capital gain)
- មិនមានពន្ធលើភាគលាភសម្រាប់និវេសនជនកម្ពុជា ចំណែកអនិវេសនជន ពន្ធលើភាគលាភត្រូវបន្ថយមកត្រឹម៧% (ពីអត្រាដើម ១៤%)

**(ឃ) ពិពិធកម្មនៃសំណុំវិនិយោគ និងចំណូលបន្ថែម**

---

[3] អ៊ួន រិទ្ធី(២០១៩), យុទ្ធសាស្ត្រជំរុញទីផ្សារមូលបត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា, សាកលវិទ្យាល័យឥន្ទ្រវិជ្ជា ទំព័រ ០៧

[4] កែប សំភី,២០២០, ប្រភេទមូលបត្រកម្មសិទ្ធិ, (អត្ថបទបង្ហាញដល់និស្សិតឆ្នាំទី៤,សាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)

ក្រៅពីប្រភពចំណូលចម្បងដូចជាប្រាក់ខែ ឬប្រាក់ចំណេញពីអាជីវកម្ម និងប្រាក់ចំណូលបន្ថែមផ្សេងទៀតក្នុងទម្រង់ជាការប្រាក់ដែលបានពីការដាក់ប្រាក់សន្សំមានកាលកំណត់ ចំណូលពីការជួល ឬចំណេញពីអចលនទ្រព្យ លោកអ្នកអាចវិនិយោគក្នុងផ្សារភាគហ៊ុនដើម្បីធ្វើពិពិធកម្មសំណុំវិនិយោគ និងដើម្បីទទួលបានចំណូលបន្ថែម។ បន្ថែមពីលើនេះ ថ្លៃសេវាសម្រាប់ការជួញដូរមូលបត្រមានកម្រិតទាប ដោយស្ថិតក្នុងរង្វង់ ០,៥% នៃតម្លៃជួញដូរតែប៉ុណ្ណោះ។

- **ហានិភ័យនៃការជួញដូរភាគហ៊ុន**

ការជួញដូរភាគហ៊ុនអាចជួបនូវហានិភ័យមួយចំនួនដែលធ្វើឱ្យថ្លៃនៃភាគហ៊ុនធ្លាក់ចុះ ឬមានការប្រែប្រួលខ្លាំង។[5]

យើងអាចចាត់ថ្នាក់ហានិភ័យទាំងនោះ ជាបីប្រភេទចម្បងៗ ដូចតទៅ៖

- **ហានិភ័យជាប្រព័ន្ធ ឬហានិភ័យទីផ្សារ** គឺជាភាពមិនច្បាស់លាស់ដែលកើតមានឡើងចំពោះទីផ្សារទាំងមូល និងមិនអាចចៀសវាងបានតាមការធ្វើពិពិធកម្ម ដូចជា ហានិភ័យនៃការធ្លាក់ចុះសេដ្ឋកិច្ច ហានិភ័យអតិផរណា ហានិភ័យអស្ថេរភាពនយោបាយ ហានិភ័យនៃការកើនឡើងអត្រាការប្រាក់ ជាដើម។
- **ហានិភ័យមិនមែនជាប្រព័ន្ធ** គឺជាភាពមិនច្បាស់លាស់ដែលកើតមានចំពោះក្រុមហ៊ុនឬវិស័យណាមួយ ដែលអាចកាត់បន្ថយបានដោយការធ្វើពិពិធកម្ម។ ហានិភ័យទាំងនោះរួមមាន អសាធនីយភាពនៃក្រុមហ៊ុន ការកេងបន្លំផ្ទៃក្នុងនៃបញ្ជីគណនេយ្យ សកម្មភាពជួញដូរផ្ទៃក្នុង ជាដើម។
- **ហានិភ័យសន្ទនីយភាព** សំដៅដល់ហានិភ័យដែលអ្នកទិញនិងអ្នកលក់មិនអាចរកគ្នាឃើញ ដើម្បីជួញដូរនៅពេលត្រូវការ និងនៅថ្លៃសមស្រប‌មួយ ដោយសារកង្វះសន្ទនីយភាពក្នុងទីផ្សារ។

### ១.២.២. មូលបត្របំណុល

មូលបត្របំណុល គឺសំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដែលបោះផ្សាយដោយបុគ្គលណាមួយដោយបញ្ជាក់ ឬទទួលស្គាល់នូវបំណុលរបស់ខ្លួនចំពោះបុគ្គលមួយទៀតដែលអោយប្រាក់ខ្ចី ឬប្រាក់បញ្ញើជាមួយបុគ្គលនោះ ឬបុគ្គលនោះជំពាក់តាមវិធីផ្សេងពីនេះ ហើយទោះបីជាមាន ឬគ្មានទ្រព្យដាក់ធានាក្តី។[6]

[5] http://csx.com.kh/news/faq/listPosts.do?MNCD=7060#sec1_3 (ចូលទស្សនាថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២០)

[6] សន្ទានុក្រម “ការអប់រំអំពីមូលបត្រ” http://www.secc.gov.kh/khmer/m75.php?pn=2 (ចូលទស្សនាថ្ងៃទី០៧ ខែមិថុនា ឆ្នាំ ២០២០)

### ១.២.២.១. ការចេញផ្សាយប័ណ្ណរតនាគាររយៈពេលខ្លី (Treasury Bill)

ប័ណ្ណរតនាគារត្រូវបានបោះផ្សាយដំបូងដោយរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីឆ្នាំ២០០៣ ដល់២០០៦ ទើបផ្អាកបោះផ្សាយ។ ប័ណ្ណរតនាគារត្រូវបានចេញផ្សាយចំនួន៣៣លើក ជាមួយនឹងការសងវិញចំនួន ៣៣លើកដែរ ចាប់ពីដំណើរការដេញថ្លៃលើកដំបូងថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៣ មកដល់ឆ្នាំ២០០៦។[7]

**គោលបំណងនៃការចេញផ្សាយប័ណ្ណរតនាគាររយៈពេលខ្លី**

ប័ណ្ណរតនាគារ ត្រូវបានចេញផ្សាយក្នុងគោលបំណងជំនួសឲ្យការខ្ចីប្រាក់រៀលដែលមានរយៈពេលកំណត់ស្មើ រឺ តិចជាងពីរឆ្នាំ។ ប័ណ្ណរតនាគារមានពីរប្រភេទគឺ ប័ណ្ណរតនាគារគណនីចរន្ត (Treasury Bill Current Account) និងប័ណ្ណរតនាគារជារូបវន្ត (Treasury Bill On Tap)។ ប័ណ្ណរតនាគារគណនីចរន្ត គឺសម្រាប់លក់ជូនតែគ្រឹះស្ថានធនាគារ ក្រុមហ៊ុនធានារ៉ាប់រង និង អន្តការីផ្សេងៗ និង ប័ណ្ណរតនាគារជារូបវន្ត គឺសម្រាប់លក់ឲ្យសហគ្រាស និងអង្គភាពផ្សេងទៀត ដែលមិនមែនជាអង្គភាពហិរញ្ញវត្ថុ។ ប័ណ្ណនេះអាចដាក់លក់ជាការធានា ឬអាចខ្ចីដោយការបង្វែពីគណនីមួយទៅមួយទៀត។ យ៉ាងណាមិញ ប័ណ្ណនេះត្រូវបានផ្អាកទៅវិញ ដោយសារាជរដ្ឋាភិបាលពុំមានត្រូវការ។

### ១.២.២.២. មូលបត្រអាចជួញដូរបាន (NCD)

មូលបត្រអាចជួញដូរបាន (NCD) គឺជាប័ណ្ណបំណុលរយៈពេលខ្លីមានការប្រាក់ ដែលចេញដោយធនាគារជាតិនៃកម្ពុជា។ មូលបត្រនេះត្រូវបានចេញផ្សាយជាប្រាក់រៀល (KHR) និងប្រាក់ដុល្លារអាមេរិក (USD) ដើម្បីជួយ ដល់បណ្តាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុវិនិយោគនូវសន្ទនីយភាពរយៈពេលខ្លីរបស់ខ្លួន។ តម្លៃនាមចារឹកអប្បបរមា គឺ ៥០.០០០ ដុល្លារអាមេរិក ឬ ២០០.០០០.០០០ រៀល ។ កាលវសាននៃ KHR-NCD មានចាប់ពី ២ សប្តាហ៍ ដល់ ១ឆ្នាំ ចំណែកឯ USD-NCD វិញ មានកាលវសានចាប់ពី ២ សប្តាហ៍ដល់ ៦ខែ។ អត្រាការប្រាក់របស់ NCD ត្រូវបានកំណត់ដោយធនាគារជាតិនៃកម្ពុជា ហើយប្រែប្រួលជារៀងរាល់ថ្ងៃទៅតាមលក្ខខណ្ឌទីផ្សារ។ [8]

- ចំណុចខ្លាំង (គុណសម្បត្តិនៃ NCD )

គុណសម្បត្តិនៃការកាន់កាប់ NCD រួមមាន៖

[7] ចិត្ត ផានិត និងវង្ស ស្រីលុច្ស(២០១៩), ការអភិវឌ្ឍន៍ទីផ្សារមូលបត្របំណុលនៅកម្ពុជា, សាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច, ទំព័រ ៧៤

[8] ទិដ្ឋភាពទូទៅមូលបត្រអាចជួញដូរ(NCD) "គោលនយោបាយរូបិយវត្ថុ https://www.nbc.org.kh/monetary_policy/ncds_overview.php (ចូលទស្សនាថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០)

- គ្មានហានិភ័យ: ដោយសារតែ NCD បានគាំទ្រដោយប្រកាសស្តីពីការចេញផ្សាយមូលបត្រអាចជួញដូរបានដោយធនាគារជាតិនៃកម្ពុជា និងចេញដោយNBCដូច្នេះឧបករណ៍នេះគ្មានហានិភ័យឥណទានឡើយ។
- ទទួលបានការប្រាក់: NCD គឺជាឧបករណ៍អាចជួញដូរបានដែលមានការប្រាក់ ដូច្នេះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលបានប្រើប្រាក់បម្រុងសល់ទំនេររបស់ខ្លួនជាវ NCD អាចនឹងទទួលបានការប្រាក់ដែលនឹងត្រូវបានទូទាត់សងនាកាលវសានទៅក្នុងគណនីចរន្តរបស់ម្ចាស់មូលបត្រដែលបានបើកនៅNBC។ អត្រាការប្រាក់របស់ NCD ខ្ពស់ជាងអត្រាការប្រាក់របស់ប្រាក់បញ្ញើមានកាលកំណត់។ រូបមន្តសម្រាប់ គណនាការប្រាក់ NCD មានដូចខាងក្រោម:

$$I = Prt$$

ដោយ

I =គឺជាការប្រាក់

P=គឺជាចំនួនប្រាក់ដើម

$r$ = គឺជាអត្រាការប្រាក់ប្រចាំឆ្នាំ ជាភាគរយដោយចែក

ជាមួយចំនួនថ្ងៃពិតប្រាកដក្នុងឆ្នាំនីមួយៗ

$t$ = អាយុកាល NCD

- អាចប្តូរសាច់ប្រាក់បានរហ័ស: NCD គឺជាឧបករណ៍បំណុលរយៈពេលខ្លី គ្មានហានិភ័យ និងចេញផ្សាយ ដោយ NBC ដូច្នេះ NCD អាចត្រូវបានជួញដូរនៅក្នុងទីផ្សារទីពីរដែលមានកម្រិតសន្ទនីយភាពខ្ពស់។ លើសពីនេះទៀត ស្ថិតក្នុងដំណាក់កាលបណ្តោះអាសន្ន ធនាគារជាតិនៃកម្ពុជា នឹងទទួទិញត្រឡប់វិញមុនកាលវសានតាមថ្លៃអប្បហារ ប្រសិនបើម្ចា ស់ NCD មានការលំបាកក្នុងការស្វែងរកសមភាគី។ រូបមន្តសម្រាប់ គណនាការទិញ NCD ត្រឡប់វិញមានដូចខាងក្រោម:

$$\text{ថ្លៃទិញត្រឡប់វិញ} = \frac{\text{ប្រាក់ដើម} + \text{ការប្រាក់}}{១ + \left(\frac{\text{អត្រាទិញត្រឡប់វិញប្រចាំឆ្នាំ x ចំនួនថ្ងៃនៅសល់ដល់កាលវសាន}}{\text{ចំនួនថ្ងៃពិតប្រាកដក្នុងឆ្នាំនីមួយៗ}}\right)}$$

- អាចប្តូរកម្មសិទ្ធិ: ម្ចាស់ NCD អាចផ្ទេរ NCD ទៅឱ្យភាគីណាមួយនៅ ពេលណាមួយក៏បាននៅក្នុងទីផ្សារអន្តរធនាគារ។ NBC នឹងផ្ទេរកម្មសិទ្ធិភាពជូន នៅពេលណាបានទទួលការជូនដំណឹងពីអ្នកទិញ និងអ្នកលក់ ។

- អាចធ្វើជាវត្ថុធានា: NCD អាចត្រូវបានប្រើជាវត្ថុធានាសម្រាប់ប្រតិបត្តិការឥណទាន ពីធនាគារជាតិនៃកម្ពុជា និងនៅក្នុងទីផ្សារអន្តរធនាគារ។

➢ ចំណុចខ្សោយ( គុណវិបត្តិនៃ NCD )

គុណវិបត្តិមួយចំនួនមានដូចជា៖

- វិនិយោគិនមិនអាចវិនិយោគមូលនិធិរបស់ខ្លួន តាមកាលវសានដែលគេចង់បានឡើយ ព្រោះកាលវសាន នេះត្រូវបានកំណត់ជាមុនដោយធនាគារជាតិនៃកម្ពុជា ។
- អត្រាការប្រាក់ NCD មានកម្រិតថេរ ដូច្នេះវិនិយោគិនមិនអាចទទួលបានការប្រាក់ខ្ពស់ឡើយ ប្រសិនបើ អត្រាការប្រាក់កើនឡើង ក្នុងអំឡុងពេលវិនិយោគនេះ។
- រាល់សំណើសុំការលក់ NCD ឲ្យ NBC វិញ គឺអាស្រ័យលើការសំរេចចិត្តរបស់ NBC។ NBC លើកទឹកចិត្តឱ្យវិនិយោគិនទាំងអស់ លក់ NCD នៅក្នុងទីផ្សារអន្តរធនាគារ ។
- តម្លៃ NCD ដែលធនាគារជាតិនៃកម្ពុជានឹងត្រូវទិញត្រឡប់វិញ គឺអាស្រ័យទៅនឹងរយៈពេលកាន់កាប់ និងអត្រាអប្បហាររបស់ NBC ។
- ក្នុងអំឡុងពេលនៃការវិនិយោគ វិនិយោគិនអាចប្រឈមមុខនឹងហានិភ័យនៃអត្រាការប្រាក់ ដោយសារតែ ការប្រែប្រួលអត្រាទីផ្សារ។

**១.២.២.៣.ប្រតិបត្តិការណ៍ផ្តល់សន្ទីភាពដោយមានការធានា (LPCO)**

LPCOគឺជាសកម្មភាពរបស់ធនាគារជាតិដើម្បីផ្តល់ឱ្យឬយកសាច់ប្រាក់ងាយស្រួលជារូបិយប័ណ្ណរបស់ខ្លួនទៅឬពីធនាគារឬក្រុមធនាគារ។ ធនាគារកណ្តាលប្រើប្រតិបត្តិការទីផ្សារបើកចំហជាមធ្យោបាយចម្បងនៃការអនុវត្តគោលនយោបាយរូបិយវត្ថុ។ វាអាចចូលទៅក្នុងការធ្វើប្រតិបត្តិការសងប្រាក់វិញឬធានាសុវត្ថិភាពជាមួយធនាគារពាណិជ្ជកម្មដែលធនាគារកណ្តាលផ្តល់ប្រាក់ជាប្រាក់កក់សម្រាប់រយៈពេលកំណត់មួយហើយធ្វើសមកាលកម្មទ្រព្យសម្បត្តិដែលមានសិទ្ធិជាទ្រព្យបញ្ចាំ។ គោលបំណងធម្មតានៃប្រតិបត្តិការទីផ្សារបើកចំហគឺដើម្បីគ្រប់គ្រងដោយប្រយោលនូវការផ្គត់ផ្គង់ប្រាក់សរុប - ដោយពង្រីកឬចុះកិច្ចសន្យា។[9]

នៅថ្ងៃទី ១៣ ខែតុលាឆ្នាំ ២០១៦ ធនាគារជាតិនៃកម្ពុជារៀបចំវេទិកាជជែកវែកញែកជាមួយធនាគារនិងស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងអស់ស្តីពីប្រតិបត្តិការ (LPCO) ដឹកនាំដោយលោកជំទាវ ជា សិរី អគ្គនាយកធនាគារជាតិ។[10]

[9] National Bank to Begin LPCO (October 17, 2016) https://www.khmertimeskh.com/61232/national-bank-to-begin-lpco/ (ចូលទស្សនាថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២០)

[10] https://www.nbc.org.kh/english/news_and_events/news_info.php?id=230 (ចូលទស្សនាថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២០)

គោលបំណងរបស់អិលអូអិលស៊ីគឺដើម្បី

- បង្កើតអត្រាគោលសម្រាប់ទីផ្សារដើម្បីបម្រើដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុដោយផ្អែកលើយន្តការទីផ្សារ
- លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលរៀល / - គាំទ្រដល់ការអភិវឌ្ឍវិស័យកសិកម្មនិង
- ចូលរួមចំណែកក្នុងការកាត់បន្ថយអត្រាការប្រាក់ខ្ពស់បច្ចុប្បន្នក្នុងរៀល។

**១.២.២.៤. សញ្ញាប័ណ្ណសាជីវកម្ម** ( Corporate Bond )

សញ្ញាប័ណ្ណសាជីវកម្ម គឺត្រូវបានបោះផ្សាយដោយក្រុមហ៊ុនឯកជន ក្នុងគោលបំណងដើម្បីលក់ទៅអោយសាធារណជនក្នុងរយះពេលកំណត់ណាមួយ។ អ្នកដែលទិញមូលបត្របំណុលពីក្រុមហ៊ុន ជាអ្នកកាន់កាប់លើមូលបត្របំណុល និងជាម្ចាស់បំណុល និងទទួលបានការប្រាក់មកវិញ រួមជាមួយនឹងដើមក្នុងកាលកំណត់ណាមួយ។[11]

➢ **ប្រភេទសញ្ញាបណ្ណសាជីវកម្ម**[12]

យោងតាមប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈចេញដោយ គ.ម.ក. សញ្ញាបណ្ណសាជីវកម្មអាចចែកចេញជា៖

- សញ្ញាបណ្ណធម្មតា ( Plain Vanilla Bond ) សំដៅដល់សញ្ញាបណ្ណដែលមានអត្រាគូប៉ុងថេរ មានកំណត់ឥណប្រតិទានជាមុននៅ កាលបរិច្ឆេទបោះផ្សាយ មិនមានការលើកកម្ពស់ ( Enhancement ) ឬលក្ខណៈបន្ថែមដូចជាសិទ្ធិទិញត្រលប់ ( Call Option ) ឬ សិទ្ធិលក់ ( Put Option ) និងមិនមានការធានា។
- សញ្ញាបណ្ណមានបុគ្គលធានា ( Guaranteed Bond ) សំដៅដល់សញ្ញាបណ្ណដែលផ្តល់ការធានាថា ការប្រាក់និងប្រាក់ដើមនឹងត្រូវបានទូទាត់សងដោយភាគីទីបី ដែលជានីតិបុគ្គល ករណីដែលបុគ្គលបោះផ្សាយមិនមានលទ្ធភាពសងបំណុល ( Default ) ដោយមូលហេតុដូចជា អសាធនភាព ឬក្ស័យធន។
- សញ្ញាបណ្ណមានវត្ថុធានា ( Secured Bond ) សំដៅដល់សញ្ញាបណ្ណដែលមានដាក់ទ្រព្យសកម្មជាវត្ថុធានា លើកលែងតែ មូលបត្របំណុលដែលមានទ្រព្យធានា ( Asset Backed Securities ) ដែលត្រូវកំណត់នៅក្នុងបទប្បញ្ញត្តិដោយឡែក។

**១.២.៣. ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរទេទីវ**

ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរវេទីវ ( Derivative Instrument ) គឺជាឧបករណ៍ហិរញ្ញវត្ថុ និងកិច្ចសន្យារវាងភាគីពីរ ឬច្រើនដែលតម្លៃរបស់វាត្រូវបានកំណត់ដោយការប្រែប្រួលនៃទ្រព្យសកម្ម។ ទ្រព្យសកម្មទាំង

[11] https://www.investopedia.com/terms/c/corporatebond.asp#:~:text=A%20corporate%20bond%20is%20debt,trade%20on%20the%20secondary%20market., Investopedia, Corperate Bond ( ចូលទស្សនាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ )

[12] មូលបត្របំណុល “ផលិតផល និងសេវាកម្ម” http://csx.com.kh/kh/product/bond.jsp?MNCD=4040 ( ចូលទស្សនាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ )

នោះជាទូទៅរួមមាន ភាគហ៊ុន សញ្ញាបណ្ណ វត្ថុធាតុ (មាស ប្រេង) រូបិយប័ណ្ណ អត្រាការប្រាក់ និងសន្ទស្សន៍ទីផ្សារ។[13]

## ១.៣. ទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ ត្រូវបានគេទទួលស្គាល់ថាជា កន្លែងសម្រាប់ធ្វើការជួញដូរ ឬទិញ-លក់មូលបត្រ និង ឧបករណ៍ផ្សេងៗដទៃទៀត។ យោងតាមនិយមន័យច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន ទីផ្សារមូលបត្រ សំដៅដល់ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើ សំណើ លក់ ផ្ទេរ ឬស្នីការទិញ-លក់មូលបត្រ ឧបករណ៍ហិរញ្ញវត្ថុដែលតែងតែត្រូវបានជួញដូរលើទីផ្សារនេះ រួមមាន មូលបត្រកម្មសិទ្ធិ មូលបត្របំណុល និងឧបករណ៍និស្សន្ទជាដើម។[14]

ទីផ្សារមូលបត្រ គឺជាពាក្យបន្សំមកពីពាក្យ ទីផ្សារ និងមូលបត្រ។ ទីផ្សារមូលបត្រផ្តល់ទីកន្លែងដែល អ្នកលក់ និងអ្នកទិញជួបគ្នាដើម្បីដោះដូរទំនិញ ឬសេវាកម្មក្នុងតម្លៃកំណត់មួយ។ រីឯមូលបត្រសំដៅដល់គំរូ ប័ណ្ណ ដែលអាចធ្វើការដោះដូរជាសាធារណៈ ឬលើទីផ្សារមូលបត្រ។

ផ្សារមូលបត្រដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចរបស់ប្រទេសមួយ ដោយវាអនុញ្ញាតឱ្យក្រុមហ៊ុនសាជីវកម្ម សហគ្រាសសាធារណៈ និងរដ្ឋាភិបាលអាចប្រមូលទុនដោយផ្ទាល់ពីសាធារណជន មកប្រើប្រាស់ដើម្បីពង្រីកអាជីវកម្ម ឬអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាដើម។ ម៉្យាងវិញទៀត អ្នកដែលមានប្រាក់សល់ពីការចំណាយ មានជម្រើសក្នុងការធ្វើពិពិធកម្មសំណុំវិនិយោគរបស់ខ្លួន ឬធ្វើការសន្សំ(ជាមួយមូលបត្រដែលមានហានិភ័យទាប) នៅក្នុងទីផ្សារមូលបត្រ។ នៅពេលដែលសាច់ប្រាក់'ហូរ'ពីអ្នកមានវាទៅអ្នកដែលត្រូវការវាប្រកបដោយប្រសិទ្ធភាព ពេលនោះសកម្មភាពសេដ្ឋកិច្ចដូចជាផលិតកម្មនិងពាណិជ្ជកម្ម នឹងរីកលូតលាស់ទៅតាមនោះដែរ ព្រមទាំងបង្កើតឱ្យមានការងារ និងទ្រព្យសម្បត្តិសម្រាប់ប្រជាជនទូទៅ។[15]

## ១.៤. អត្ថប្រយោជន៍ទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ គឺជានិយ័តករយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ព្រោះគេអាចចាត់ទុកវាជាឧបករណ៍វាស់ស្ទង់ស្ថានភាពសេដ្ឋកិច្ចជាតិមួយទាំងមូល។ ជាការពិតណាស់ភាពប្រែប្រួលក្នុងបរិបទសេដ្ឋកិច្ចជាតិ និងអន្តរជាតិនឹងធ្វើឱ្យផលប៉ះពាល់ខ្លាំងដល់ស្ថានភាពទីផ្សារមូលបត្រភ្លាម។ ឥទ្ធិពលនេះអាចឆ្លុះបញ្ចាំងបានតាមរយៈសន្ទស្សន៍នៃភាគហ៊ុន ឬការឡើងចុះនៃភាគហ៊ុនរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រនីមួយៗ ដែលធ្វើឱ្យមានការប្រែប្រួលទំនុកចិត្តរបស់វិនិយោគិនគ្រប់រូប។ ហេតុនេះហើយ យើងអាចនិយាយបានថា

[13] អ៊ួន រិទ្ធី(២០១៩), យុទ្ធសាស្ត្រជំរុញទីផ្សារមូលបត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា, សាកលវិទ្យាល័យឥន្ទ្រវិជ្ជា ទំព័រ ២០

[14] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, លេខ នស/រកម/១០០៧/០២៨,១៩ តុលា ២០០៧, មាត្រាទី ៣៨

[15] http://csx.com.kh/news/faq/listPosts.do?MNCD=7060 (ចូលទស្សនាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០)

ទីផ្សារមូលបត្រដើរតួទាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់បណ្តាប្រទេសអភិវឌ្ឍ និងកំពុងអភិវឌ្ឍទាំងអស់។[16]

ជាសង្ខេប ទីផ្សារមូលបត្រផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ច និងវិនិយោគិនដូចតទៅ៖

- ទីផ្សារមូលបត្រ ជួយជំរុញឱ្យមហាជនបង្កើតនូវប្រាក់សន្សំ និងកៀរគរមូលធនដែលមិនមានតម្រូវការ និងនៅសេសសល់ យកទៅប្រើប្រាស់ក្នុងការវិនិយោគនានា។
- ទីផ្សារមូលបត្រ ជាមធ្យោបាយមួយសម្រាប់អាជីវកម្មខ្នាតតូចក្តី ធំក្តីក្នុងការប្រមូលយកមូលធន ដែលនៅសេសសល់យកមកទ្រទ្រង់ និងពង្រីកអាជីវកម្មរបស់ខ្លួន។
- ទីផ្សារមូលបត្រ គឺជាទីផ្សារឧបករណ៍ហិរញ្ញវត្ថុ ដែលជួយសម្រួលដល់រាជរដ្ឋាភិបាល ក្នុងការ អនុវត្តនូវគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម តាមរយៈការបោះផ្សាយមូលបត្រ និងទាក់ទាញនូវវិនិយោគិនទាំងឡាយ។
- ទីផ្សារមូលបត្រ ជាមធ្យោបាយមួយដែលអាចទាញយកមូលធនមិនត្រឹមត្រូវតែក្នុងប្រទេស ប៉ុន្តែ ពីមូលធនបរទេសទៀតផង។
- ទីផ្សារមូលបត្រជំរុញឱ្យប្រភពធនធានក្នុងស្រុកមានដំណើរការ និងចរាចរយ៉ាងរស់រវើកលើទីផ្សារ។
- ទីផ្សារមូលបត្រ ជាកាតាលីករជួញដូរជំរុញឱ្យបណ្តាក្រុមហ៊ុននានា ប្រកបអាជីវកម្មដោយមានប្រសិទ្ធភាព និងមានតម្លាភាព។
- ទីផ្សារមូលបត្រជួយបង្កើតនូវទម្លាប់សន្សំ និងវិនិយោគ។
- ទីផ្សារមូលបត្រ ជាជំហានចម្បងសម្រាប់ប្រទេសកំពុងអភិវឌ្ឍឆក់ឱកាសដើម្បីពង្រីក សេដ្ឋកិច្ចរបស់ខ្លួន។

## ១.៥. គុណវិបត្តិរបស់ទីផ្សារមូលបត្រ

បើទោះជាទីផ្សារមូលបត្រ បានពាំនាំអត្ថប្រយោជន៍ដ៏សំបូរបែបដល់សេដ្ឋកិច្ចជាតិក៏ពិតមែនស្របពេលនេះដែរទីផ្សារក៏មានគុណវិបត្តិមួយចំនួនដែលគួរយល់ដឹង។ ពិសេសចំពោះប្រទេសដែលមានប្រព័ន្ធច្បាប់ទន់ខ្សោយ គឺតែងតែជួបប្រទះនូវបញ្ហាមួយចំនួនដូចខាងក្រោម៖

- ការឆក់ឱកាសកេងចំណេញក្នុងការទិញ-លក់ គឺជាការជួញដូរមួយដែលមានការគិតគូរយ៉ាងម៉ត់ចត់ដើម្បីទទួលបានផលចំណេញ ដោយប្រឈមនឹងហានិភ័យមួយចំនួនដែលវិនិយោគិនអាចនឹងទទួលការខាតបង់។ ការឆក់ឱកាសទិញ លក់មូលបត្រនេះ គឺជាការជួញដូរភាគហ៊ុននាពេលបច្ចុប្បន្ន ដោយ

[16] ការអប់រំពីមូលបត្រ, អត្ថប្រយោជន៍ និងគុណវិបត្តិរបស់ទីផ្សារមូលបត្រ, http://www.secc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០)

រំពឹងថាតម្លៃភាគហ៊ុននឹងកើនឡើងក្នុងពេលអនាគត ហើយទទួលបានប្រាក់ចំណេញក្នុងមួយលើកៗ។ ការឆក់ឱកាសទិញ-លក់របៀបនេះ នឹងជះឥទ្ធិពលដល់តម្លៃភាគហ៊ុន។ ការទិញលក់បែបនេះនឹងធ្វើភាគហ៊ុននៅលើ ទីផ្សារមានភាពខ្វះ ឬលើសនៅពេលដែលមានការត្រូវរ៉ូវគ្នារវាងអ្នកលក់ និងអ្នកទិញច្រើន។ ព្រឹត្តិការណ៍នេះធ្វើឱ្យតម្លៃភាគហ៊ុនលើទីផ្សារមូលបត្រមានចលនាកើនឡើង និងធ្លាក់ចុះផងដែរ។

- ការជួញដូរផ្ទៃក្នុង មានបុគ្គលិករបស់ក្រុមហ៊ុនចុះបញ្ជីមួយចំនួនបានលួចយកព័ត៌មានផ្ទៃក្នុងរបស់ក្រុមហ៊ុន ដើម្បីធ្វើការជួញដូរដើម្បីរកប្រាក់ចំណេញផ្ទាល់ខ្លួន ដែលជាហេតុធ្វើឱ្យតម្លៃនៃ ទីផ្សារភាគហ៊ុនមានការប្រែប្រួល ហើយព័ត៌មាននោះសុទ្ធតែមិនមែនជាព័ត៌មានសាធារណៈ ពោលគឺព័ត៌មានសម្ងាត់។
- ការជួញដូរក្លែងក្លាយ និងប្រើឧបាយកលក្នុងទីផ្សារ គឺជាការធ្វើសកម្មភាពណាមួយ ឬគេចវេសមិនធ្វើសកម្មភាពណាមួយដែលបណ្តាលឱ្យ ឬអាចបណ្តាលឱ្យមានលក្ខណៈ ក្លែងបន្លំ ឆបោក ឬនាំឱ្យយល់ខុស ចំពោះរបៀបនៃការជួញដូរមូលបត្រ ឬការធ្វើប្រតិបត្តិការធ្វើផែនការជួញដូរដែលមានលក្ខណៈសិប្បនិម្មិតទាក់ទិននឹងមូលបត្រនៅលើទីផ្សារមូលបត្រ។
- សេចក្តីថ្លែងការណ៍ ឬផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬដែលនាំឱ្យមានការយល់ខុសទាំងស្រុងទៅលើការជួញដូរមូលបត្រ ដែលធ្វើឱ្យមហាជនខាតបង់ពីការក្លែងបន្លំនេះ ឬ  បណ្តាលឱ្យមានការកើនឡើង ឬថយចុះ ឬនៅថេរចំពោះតម្លៃនៃការជួញដូរមូលបត្រ នៅលើទីផ្សារមូលបត្រ។

ក្រុមហ៊ុនបោះផ្សាយមូលបត្រ តម្រូវឱ្យមានបញ្ជីគណនេយ្យច្បាស់លាស់ មានតម្លាភាព និងអភិបាលកិច្ចសាជីវកម្មល្អ  ដែលអាចជាបន្ទុកមួយដ៏ល្អសម្រាប់វិនិយោគិនបង្កើនការទុកចិត្តក្នុងការបណ្តាក់ទុកទៅលើក្រុមហ៊ុន។ ម្យ៉ាងទៀត ក្រុមហ៊ុននឹងមានផ្លែផ្កាមកវិញនូវទុនរយៈពេលវែងក្នុងតម្លៃថោកសមរម្យសម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួន។

## ១.៦. អ្នកចូលរួមក្នុងទីផ្សារមូលបត្រ

បច្ចុប្បន្ន អ្នកចូលរួមក្នុងទីផ្សារមូលបត្រត្រូវបានធ្វើចំណាត់ថ្នាក់ដូចខាងក្រោម៖

### ១.៦.១ តួអង្គលើទីផ្សារដំបូង

ទីផ្សារដំបូងគឺជាផ្នែកមួយនៃទីផ្សារភាគហ៊ុន ដែលគេធ្វើការជួញដូរមូលបត្រលើកដំបូងចេញពីក្រុមហ៊ុនបោះផ្សាយទៅវិនិយោគិនសាធារណៈពាក់ព័ន្ធនឹងការចេញលក់មូលបត្រដោយវិនិយោគិនធ្វើការទិញមូលបត្រដែលមិនធ្លាប់បានជួញដូរពីមុនមកនៅក្នុងទីផ្សារនេះ ហើយក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវផ្តល់ភាគលាភទៅអ្នកវិនិយោគដោយផ្ទាល់។

ប្រតិបតិបត្តិការនៃដំណើរការលក់មូលបត្រក្នុងទីផ្សារដំបូងចែកជា ២ ប្រភេទ[17]គឺ៖

- ការដាក់លក់ជាសាធារណៈ (Public offering) ការដាក់លក់មូលបត្រគឺធ្វើឡើងជាសាធារណៈដែលតម្រូវអោយមានការចុះបញ្ជីនៅគណៈកម្មការមូលបត្រកម្ពុជា ដើម្បីធ្វើការផ្សព្វផ្សាយពត៌មានមួយចំនួនដូចជារបាយការណ៍ហិរញ្ញវត្ថុ ប្រវត្តិក្រុមហ៊ុន និងថ្លៃមូលបត្រជាដើម។
- ការដាក់លក់ជាលក្ខណៈឯកជន (Private offering) ការដាក់លក់ធ្វើឡើងតាមរយៈការចរចារជាមួយអតិថិជនពិសេសមិនតម្រូវអោយមានការចុះបញ្ជីនៅគណៈកម្មការមូលបត្រកម្ពុជា និងមិនចាំបាច់ធ្វើការផ្សព្វផ្សាយពត៌មាន ជាសាធារណៈនោះទេ។

**១.៦.១.១. ក្រុមហ៊ុនធានាទិញមូលបត្រ**

ជាទូទៅនៅក្នុងទីផ្សារភាគហ៊ុន ក្រុមហ៊ុនធានាទិញមូលបត្រជាក្រុមហ៊ុនសហកម្មសិទ្ធិដែលបានទទួលអាជ្ញាបណ្ណពី គ.ម.ក. ដែលមានតួនាទីក្នុងការត្រួតពិនិត្យរាល់ការបោះផ្សាយជាសាធារណៈ និងការចែកចាយមូលបត្រ (នៅក្នុងទម្រង់ជាបណ្ណភាគហ៊ុនធម្មតា ឬភាគហ៊ុនអាទិភាព) របស់អាជីវកម្ម ឬស្ថាប័នដែលធ្វើការបោះផ្សាយ។ តួនាទីលេចធ្លោបំផុតរបស់ក្រុមហ៊ុនធានាទិញមូលបត្រ គឺការផ្តល់ប្រឹក្សាក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង (Initial Public Offering-IPO)។ IPO គឺជាដំណើរការនៃការលក់ភាគហ៊ុនរបស់ក្រុមហ៊ុនឯកជន នៅលើផ្សារហ៊ុនសាធារណៈជាលើកដំបូង។ ក្រុមហ៊ុនធានាទិញមូលបត្រ គឺជាអ្នកឯកទេសផ្នែកហិរញ្ញវត្ថុដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នបោះផ្សាយដើម្បីកំណត់ថ្លៃលក់មូលបត្រដំបូង (Pricing) ទំហំទឹកប្រាក់នៃមូលបត្រ (Issue Amount) ចំនួនមូលបត្របោះផ្សាយ (Number of Securities Issued) និងពេលវេលានៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ (Distribution Timeline) ទៅវិនិយោគិនតាមរយៈបណ្តាញចែកចាយរបស់ក្រុមហ៊ុនធានាទិញមូលបត្រ។

ក្រុមហ៊ុនធានាទិញមូលបត្រ ជាទូទៅជាធនាគារវិនិយោគ ដែលមានអ្នកឯកទេស IPO។ ធនាគារវិនិយោគទាំងនេះមាន ទំនាក់ទំនងជាមួយបណ្តាអង្គភាពវិនិយោគទុនធំៗជាច្រើន ដូចជា មូលនិធិសង្គម និងក្រុមហ៊ុនធានារ៉ាប់រង ដើម្បីវាស់ស្ទង់ពីផលប្រយោជន៍នៃការវិនិយោគិន។ ចំនួនការប្រាក់ដែលវិនិយោគិនទាំងនេះទទួលបាន ជួយឱ្យក្រុមហ៊ុនធានាទិញមូលបត្រអាចកំណត់តម្លៃ IPO នៃភាគហ៊ុន។ ក្រៅពីនេះ ក្រុមហ៊ុនធានាទិញមូលបត្រមានតួនាទីផ្សេងទៀតដូចជា៖

- ទិញមូលបត្រទាំងអស់ ឬមួយផ្នែកពីក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈដើម្បីធានានូវភាពជោគជ័យរបស់ក្រុមហ៊ុនបោះផ្សាយនោះ។

[17] ស៊ូ សុជា និងអ៊ុង នីតា(២០១៥), «ការវិនិយោគលើមូលបត្រនៅផ្សារមូលបត្រកម្ពុជា និងការវិភាគលើភាគហ៊ុន» សាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច) ទំព័រ ០៨

- ទិញមូលបត្រដែលលក់មិនអស់ នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ ក្នុងគោលដៅធានានូវភាពជោគជ័យនៃការបោះផ្សាយ។
- ចាត់ចែងរៀបចំដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ ឱ្យក្រុមហ៊ុនបោះផ្សាយលក់ មូលបត្រ ឬចូលរួមដោយផ្ទាល់ ឬមិនផ្ទាល់នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- លើសពីនេះក្រុមហ៊ុនធានាទិញមូលបត្រ អាចធ្វើអាជីវកម្មមូលបត្រផ្សេងៗទៀតដូចជា អាជីវកម្ម ជួញដូរមូលបត្រ អាជីវកម្មឈ្មួញជើងសារមូលបត្រ និងអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។ បច្ចុប្បន្នក្រុមហ៊ុនធានាទិញមូលបត្រ (Underwriter) នៅកម្ពុជារួមមាន៖
    - ➢ យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី (Yuanta Securities (Cambodia) Plc.)
    - ➢ អ អេច ប៊ី ឥណ្ឌូឆៃណា ស៊ីឃ្យូរីធី ម.ក. (RHB Indochina Securities PLC.)
    - ➢ កាណា ស៊ីឃ្យូរីធី អិលធីឌី (Cana Securities Plc.)
    - ➢ កម្ពុ សីឃ្យូរីធី ភីអិលស៊ី (Campu Securities Plc.)
    - ➢ អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី (SBI Royal Securities Plc.)
    - ➢ ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី (Phnom Penh Securities Plc.)

### ១.៦.១.២. ក្រុមហ៊ុនបោះផ្សាយមូលបត្រ

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ បានផ្តល់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតដែលបានស្នើសុំ ឬបានបោះផ្សាយលក់មូលបត្រជាសាធារណៈ៖

- ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត សំដៅដល់ក្រុមហ៊ុនដែលបង្កើតឡើង និងចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្នុងគោលបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- នីតិបុគ្គលប្រតិស្រុត (Permitted Entity) សំដៅដល់នីតិបុគ្គលដែលបានអនុញ្ញាតឱ្យបោះផ្សាយ និងធ្វើសំណើលក់មូលបត្រជសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមច្បាប់និងបទប្បញ្ញត្តិផ្សេងៗ។ នីតិបុគ្គលនេះ មិនមែនជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជាទេ។

### ១.៦.១.៣. វិនិយោគិន

វិនិយោគិនសំដៅដល់រូបវន្តបុគ្គល និងនីតិបុគ្គលដែលមានសិទ្ធិធ្វើការទិញ ឬលក់មូលបត្រដែលបានបោះផ្សាយ និងធ្វើសំណើលក់ជាសាធារណៈនៅលើទីផ្សារមូលបត្រ ក្នុងព្រះរាជាណាចក្រកម្ពុជា។ វិនិយោគិនទទួលបានភាគលាភដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយមូលបត្រ។

- វិនិយោគិនជារូបវន្តបុគ្គល ឬ ឯកត្តជន (Individual Investors) គឺសំដៅដល់អ្នកវិនិយោគដែលចាត់ចែង និងគ្រប់គ្រងមូលនិធិផ្ទាល់ខ្លួនរួមមានបុគ្គលធម្មតា ដែលវិនិយោគិនប្រភេទនេះជា

វិនិយោគិនដែលជាទូទៅធ្វើការទិញ ឬលក់មូលបត្រក្នុងទំហំមួយតូច ដែលគេហៅថាជាអ្នកវិនិយោគរាយ។

- វិនិយោគិនជានីតិបុគ្គល ( Institutional Investors ) ជាប្រភេទនៃអ្នកវិនិយោគប្រកបដោយវិជ្ជាជីវៈ ដែលគ្រប់គ្រង និង ចាត់ចែងមូលនិធិសម្រាប់ស្ថាប័នរួមមាន ធនាគារ ក្រុមហ៊ុនធានារ៉ាប់រង មូលនិធិរួម ( Mutual Fund ) និងមូលនិធិសោធននិវត្តន៍( Pension Fund )ដែលវិនិយោគិនប្រភេទនេះធ្វើការវិនិយោគលក្ខណៈទ្រង់ទ្រាយធំ

រូបភាពទី១ តួអង្គលើទីផ្សារដំបូង




### ១.៦.២. តួអង្គក្នុងទីផ្សារបន្ទាប់

#### ១.៦.២.១ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

នៅក្នុងទីផ្សារបន្ទាប់ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាគឺជាកន្លែងសម្រាប់ធ្វើការជួញដូរមូលបត្រ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានតួនាទីជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។[18]

- **ប្រតិបត្តិករទីផ្សារមូលបត្រ**

ប្រតិបត្តិករទីផ្សារមូលបត្រ ជានិយ័តករជួញដូរមុខក្នុងការគ្រប់គ្រងនូវដំណើរការជួញដូរមូលបត្រក្នុងទីផ្សារមូលបត្រ និងធ្វើប្រតិបត្តិការទីផ្សារមូលបត្រដូចជា៖

[18] លឹម វិភា(២០១៨), ដំណើរការទីផ្សារមូលបត្រកម្ពុជា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ទំព័រ ១៦

- ការផ្តល់នូវសេវាសម្រាប់សម្រួលដល់អ្នកចូលរួមក្នុងទីផ្សារ ដើម្បីធ្វើសកម្មភាពជួញដូរមូលបត្រ ឬដើម្បីឱ្យអ្នកចូលរួមក្នុងទីផ្សារ អាចទទួលបាននូវការបន្សុីលើប្រតិបត្តិការបញ្ជាទិញ-លក់មូលបត្ររបស់ខ្លួនតាមរយៈទីកន្លែង ប្រព័ន្ធ ឬមធ្យោបាយសម្រាប់ការជួញដូរមូលបត្រជារូបវន្ត ឬអេឡិចត្រូនិច។
- សកម្មភាពអាជីវកម្មផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

ប្រតិបត្តិករនេះ មានតួនាទីផ្គូផ្គងតម្លៃរវាងអ្នកលក់ និងអ្នកទិញ ដើម្បីកតម្លៃមួយឱ្យត្រូវគ្នា ដោយផ្តល់អាទិភាពដល់អ្នកលក់ដែលដាក់តម្លៃទាបជាងគេ។ អាទិភាពនៃការផ្គូផ្គងនេះ គឺផ្តោតទៅលើតម្លៃពោលគឺចំពោះអ្នកទិញណាដែលហ៊ានឱ្យថ្លៃខ្ពស់ នឹងទទួលបានមុន ហើយអ្នកលក់ណាដែលហ៊ានលក់ក្នុងតម្លៃទាប គេនឹងទទួលបានមុន។ ក្នុងករណីតម្លៃដូចគណនា គេពិនិត្យមើលលើពេលវេលា។ បើពេលដូចគ្នាទៀត គេមើលលើបរិមាណ។ ថ្លៃសេវាដែលយកដោយប្រតិបត្តិករនេះគឺ ០.២៥%។

### ➢ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ

ប្រតិបត្តិករនេះ ជាអ្នកធានាថាមូលបត្របានដល់ដៃអ្នកទិញ ហើយលុយបានដល់ដៃអ្នកលក់ក្នុងពេលតែមួយ ក្រោយពីការផ្គូផ្គងទទួលបានជោគជ័យ។

ប្រតិបត្តិករនេះ ក៏ធ្វើការត្រួតពិនិត្យមូលបត្រខាងអ្នកលក់ (ថាតើមានមូលបត្រគ្រប់គ្រងសម្រាប់ លក់ឬទេ) និងខាងអ្នកទិញ (តើមានសាច់ប្រាក់គ្រប់គ្រាន់ទិញ ឬទេ) ដើម្បីបញ្ចៀសនូវហានិភ័យការទូទាត់។

គេដកសាច់ប្រាក់ពីអ្នកទិញ តាមរយៈភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA) ដែលដូចជា ធនាគារអេសុីលីដា ធនាគារកាណាឌីយ៉ា ធនាគារ ប៊ី អាយ ឌី សុី ។ គេដកមូលបត្រពីអ្នកលក់តាមរយៈប្រតិបត្តិកររក្សាទុកមូលបត្រ។ ការផាត់ទាត់ធ្វើឡើងនៅ ២ ថ្ងៃក្រោយបន្ទាប់ពីថ្ងៃជួញដូរ (T+2)។ ថ្លៃសេវាដែលយកដោយប្រតិបត្តិករនេះគឺ ០.១%។

### ➢ ប្រតិបត្តិកររក្សាទុកមូលបត្រ

ប្រតិបត្តិកររក្សាទុកមូលបត្រ សំដៅដល់បុគ្គលយល់ព្រមជាមួយបុគ្គលមួយទៀតដែលជាអតិថិជនរបស់ខ្លួនថាផ្តល់សេវាកម្ម ដូចខាងក្រោមនេះ ទោះបីជាអតិថិជនធ្វើសកម្មភាពក្នុងនាមខ្លួនឯង ឬធ្វើសកម្មភាពក្នុងនាមបុគ្គលផ្សេងទៀតក៏ដោយ៖

- កាន់កាប់ ឬចុះបញ្ជីសិទ្ធិស្របច្បាប់លើមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដទៃផ្សេងទៀត ក្នុងនាមអតិថជន ឬបុគ្គលផ្សេងដែលអតិថិជនតែងតាំង
- ទទួលរក្សាទុកមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដទៃផ្សេងទៀត ទោះបីមានរូបភាពជា វិញ្ញាបនបត្រកម្មសិទ្ធិ ឬជាទម្រង់អរូបី ដោយស្របទៅតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រ ក្នុងនាមអតិថិជន ឬបុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។

- ផ្តល់សេវាកម្ម និងលក្ខណៈងាយស្រួលផ្សេងទៀត ដែលទាក់ទងនឹងការផ្តល់សេវាកម្មមានចែងក្នុងកថាខណ្ឌ។

ប្រតិបត្តិការនេះ ជាអ្នករក្សាទុកមូលបត្រជូនវិនិយោគិន ព្រោះវិនិយោគិនមិនអាចយកមូលបត្រមករក្សាទុកនៅគេហដ្ឋានរបស់ខ្លួនបានឡើយ។ ថ្លៃសេវាដែលយកដោយប្រតិបត្តិករនេះគឺ ០.១%។

**១.៦.២.២ វិនិយោគិន**

វិនិយោគិននៅក្នុងទីផ្សារបន្ទាប់ក៏ដូចជា វិនិយោគិននៅក្នុងទីផ្សារដំបូង គឺសំដៅដល់លើសាធារណជនទាំងរូបវន្តបុគ្គល និងនីតិបុគ្គល ឬវិនិយោគិនជាបុគ្គល និងវិនិយោគិនជាស្ថាប័នដែលធ្វើការទិញ-លក់មូលបត្រ។

**១.៦.២.៣ ក្រុមហ៊ុនមូលបត្រ**

ក្នុងទីផ្សារបន្ទាប់ ក្រុមហ៊ុនបោះផ្សាយមានតួនាទីជាអ្នកផ្តល់ឧបករណ៍ សម្រាប់ធ្វើការជួញដូរហើយបានលក់ទៅឱ្យវិនិយោគិន និងប្រមូលទុនក្នុងការពង្រីកអាជីវកម្ម។ ដូចនេះ ក្រុមហ៊ុនបោះផ្សាយតែងតាំងភ្នាក់ងារទូទាត់ក្នុងការបែងចែកភាគលាភ (Dividend) សម្រាប់បង់ការប្រាក់ ឬប្រាក់ ដើមសម្រាប់សញ្ញាប័ណ្ណដល់វិនិយោគិនដែលកាន់កាប់មូលបត្រនៅចុងគ្រា។

**១.៦.២.៤ អន្តរការីទីផ្សារ**

អន្តរការីទីផ្សារមូលបត្រកម្ពុជា គឺជាបណ្តុំនៃអង្គភាព ឬបុគ្គលទាំងឡាយដែលធ្វើការណែនាំ ក្រុមហ៊ុនបោះផ្សាយមូលបត្រទៅកាន់ទីផ្សារមូលបត្រ។ អន្តរការីទីផ្សារមូលបត្ររួមមាន ក្រុមហ៊ុនធានាទិញមូលបត្រ (Underwriter) ក្រុមហ៊ុនពាណិជ្ជករមូលបត្រ (Securities Dealer) ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ (Securities Brokers) ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ (Investment Advisors) ក្រុមហ៊ុនចែកចាយលក់មូលបត្រ (Securities Selling Firm) ក្រុមហ៊ុនសមភាគីកណ្តាល (Central Counterparty Companies) និង ក្រុមហ៊ុនឈ្មួញជើងសាឧបករណ៍និស្សន្ទ (Derivatives Brokers) ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ (Fund Management Company) ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស (Trustee) ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង (Ditribution)។ល។ យោងតាមគណៈកម្មការមូលបត្រកម្ពុជា អន្តរការីទីផ្សារចែកជា៖

- ក្រុមហ៊ុនធានាទិញមូលបត្រ (Underwriter) គឺជាស្ថាប័នដែលផ្តល់សេវាកម្ម សម្រាប់ការបោះផ្សាយលក់មូលបត្រ និងមានសិទ្ធិក្នុងការជួញដូរមូលបត្រតាមបញ្ជាអតិថិជន និង ខ្លួនឯងផ្ទាល់។ បច្ចុប្បន្នក្រុមហ៊ុនធានាទិញមូលបត្រនៅកម្ពុជារួមមាន៖

➢ យ៉ាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី Yuanta Securities (Cambodia) Plc.

- ➢ អ អេច ប៊ី ឥណ្ឌូឆៃណា ស៊ីឃ្យួរីធី ម.ក RHB Indochina Securities PLC.
- ➢ កាណា ស៊ីឃ្យួរីធី អិលធីឌី Cana Securities Ltd.
- ➢ កម្ពុ ស៊ីឃ្យួរីធី ភីអិលស៊ី Campu Securities Plc.
- ➢ អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យួរីធី SBI Royal Securities Plc.
- ➢ ភ្នំពេញ ស៊ីឃ្យួរីធី ភីអិលស៊ី Phnom Penh Securities Plc.

- ● ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ( Securities Dealer ) គឺជាអ្នកធ្វើការទិញ-លក់មូលបត្រដោយផ្ទាល់នៅទីផ្សារហិរញ្ញវត្ថុ (ធ្វើការជួញដូរតាមបញ្ជារបស់អតិថិជន និងមានសិទ្ធិក្នុងការជួញដូរផ្ទាល់ខ្លួន )។ បច្ចុប្បន្នក្រុមហ៊ុនពាណិជ្ជករមូលបត្រ នៅកម្ពុជារួមមាន៖

- ➢ ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីឃ្យួរីធី ភីអិលស៊ី Golden Fortune ( Cambodia ) Securities Plc.

- ● ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ ( Securities Brokers ) គឺជាអ្នកសម្របសម្រួលប្រតិបត្តិការទិញ-លក់មូលបត្រដល់អតិថិជន។ ចំណូលរបស់ឈ្មួញជើងសារបានពីកម្រៃជើងសារប្រតិបត្តិការ នៅពេលដែលអតិថិជនធ្វើការបញ្ជាទិញ និងលក់ (មានសិទ្ធិជួញដូរតាមបញ្ជារបស់អតិថិជន)។ បច្ចុប្បន្នក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ នៅកម្ពុជារួមមាន៖

- ➢ អេស៊ីលីដា ស៊ីឃ្យួរីធី ភីអិលស៊ី ACLEDA Securities Plc.
- ➢ ខេប ស៊ីឃ្យួរីធី លីមីធីត CAB Securities Limited.
- ➢ ខេមបូឌា-វៀតណាម ស៊ីឃ្យួរីធី ឯ.ក Cambodia-Vietnam Securities Co., Ltd.

- ● ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ( Investment Advisors ) គឺដើរតួនាទីជាអ្នកផ្តល់យោបល់ក្នុងការវិនិយោគលើវិស័យមូលបត្រនេះ ហើយទទួលបានប្រាក់កម្រៃតាមរយៈការផ្តល់សេវា កម្មនេះ។ បច្ចុប្បន្ន ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ( Investment Advisors ) នៅកម្ពុជារួមមាន៖

- ✓ អេ ភី អិម (ខេមបូឌា) ស៊ីឃ្យូរីធី ឯ.ក APM ( CAMBODIA ) SECURITIES CO., LTD.

- ● ក្រុមហ៊ុនចែកចាយលក់មូលបត្រ ( Securities Selling Firm ) គឺដើរតួនាទីជាអ្នកលក់ដល់វិនិយោគលើវិស័យមូលបត្រនេះ ហើយទទួលបានប្រាក់កម្រៃតាមរយៈការផ្តល់សេវាកម្មនេះ។ បច្ចុប្បន្នក្រុមហ៊ុនចែកចាយលក់មូលបត្រ នៅកម្ពុជារួមមាន៖

- ✓ អេស៊ីលីដា ស៊ីឃ្យួរីធី ភីអិលស៊ី ACLEDA Securities Plc.

- ● ក្រុមហ៊ុនសមភាគីកណ្តាល ( Central Counterparty Companies )។ បច្ចុប្បន្នក្រុមហ៊ុនសមភាគីកណ្តាល នៅកម្ពុជារួមមាន៖

- ✓ ខេមបូឌាន ដេរីវេទីវ អ៊ិចឆេង ឯ.ក * Cambodian Derivatives Exchange Co., LTD. *

- ✓ ភ្នំពេញ ដេរីវេទីវ អ៊ិចឆេង ភីអិលស៊ី Phnom Penh Derivative Exchange Plc.
- ✓ រ៉ូយ៉ាល់ ហ្វាយនែនសល ខបភើរេសិន Royal Financial Corporation
- ✓ ហ្គោល ហ្វាយនេនសល គ្លូប៊ល អ៊ីនវេសម៉ិន Gold Financial Global Investment
- ✓ ក្រុមហ៊ុន គ្លូប៊ល លីឃ្វីឌីធី អ៊ិកឆេង ឯ.ក Global Liquidity Exchange CO.,LTD
  - ឈ្មួញជើងសាឧបករណ៍និស្សន្ទ (Derivatives Brokers) មានចំនួន ៣០ ក្រុមហ៊ុន រួមមាន៖
- ✓ ខេមបូឌាន ដេរីវ៉េទីវ អ៊ីចឆេង ឯ.ក Cambodian Derivatives Exchange Co., LTD.
- ✓ ភ្នំពេញ ស៊ីឃ្យួរីធី ភីអិលស៊ី Phnom Penh Securities Plc.
- ✓ រ៉ូយ៉ាល់ ហ្វាយនែនសល ខបភើរេសិន Royal Financial Corporation
- ✓ ហ្គោល ហ្វាយនេនសល គ្លូប៊ល អ៊ីនវេសម៉ិន Gold Financial Global Investment
- ✓ ហ្គោលអេហ្វអិកស៍ អ៊ីនវេសម៉ិន GoldFx Investment
- ✓ ភ្នំពេញ ដេរីវ៉េទីវ អ៊ីចឆេង ភីអិលស៊ី Phnom Penh Derivative Exchange Plc
- ✓ អាស្កាព អ៊ែសិត មេនិចម៉ិន ឯ.ក Askap Asset Management Co., Ltd
- ✓ ប្លែកវែល គ្លូប៊ល អ៊ីនវេសម៉ិន (ខេមបូឌា) ឯ.ក Blackwell Global Investment (Cambodia) Co., Ltd
- ✓ រីចវីល យេផេន ឯ.ក Richwill Japan Co., Ltd
- ✓ អាល់ហ្វា ហ្គោល ភ្យូឈ័រ ឯ.ក Alpha Gold Futures Co.,Ltd
- ✓ ស្កាយ ប្រេសឹស មេធល Sky Precious Metals Co.,ltd
- ✓ ហ្គោលវែល ខាភីថល ឯ.ក Goldwell Capital Co., Ltd
- ✓ ហ្គោលដេន អេហ្វអិកស៍ លីង ឃែភីថល ឯ.ក Golden Fx Link Capital Co., Ltd
- ✓ ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីឃ្យួរីធី ភីអិលស៊ី Golden Fortune (Cambodia) Securities Plc
- ✓ ប៊ី.អាយ.ស៊ី. ម៉ាឃីត ឯ.ក B.I.C. Markets Co.,ltd
- ✓ ឡាយអិន ឃែភីថល មេនេចម៉ិន ឯ.ក Lion Capital Management Co.,ltd
- ✓ ប្រូកឃើរ ជេត ឯ.ក Broker Jet Co.,ltd
- ✓ ក្រុមហ៊ុន ណាញ ខេបភីថល អ៊ីនធើណេសិនណល ឯ.ក Nine Capital International CO.,LTD
- ✓ អេ អ រូ អិន អ៊ី អិច ឯ.ក ARONEX Co., Ltd.
- ✓ វីមែកស៍ ហ្វាយនែនសល គ្លូប៊ល អ៊ីនវេសម៉ិន ម.ក. Veemax Financial Global Investment Plc
- ✓ ១០០ ហ្វេន តួហ្ស៊ី ឯ.ក 100 Fen Touzi Co., Ltd.
- ✓ ហ័រ ហ្សុង ឌីង សេង អ៊ីនវេសម៉ិន ឯ.ក Hua Zhong Ding Sheng Investment Co., Ltd.

✓ អ៊ឹឡាយដ៏វីន អ៊ីកឆេន ឯ.ក Alliedwin Exchange Co.,ltd

✓ អូផិន ហ្វរិក ឯ.ក Open Forex Co.,ltd

✓ ស៊ីអេហ្វឌី ឃែភីថល ឯ.ក CFD Capital Co., Ltd

✓ ភីភី លីង ស៊ីឃ្យូរីធី ឯ.ក PP Link Securities Co.,ltd

✓ ជីវ៉ាយដាប់បែលយូ គ្លូប៊ល មេនេចម៉ិន ឯ.ក GYW Global Management Co., Ltd

✓ ជីខេអេហ្វអិកស៍ (ខេមបូឌា) ឯ.ក GKFX (Cambodia) Co., Ltd

✓ ក្រុមហ៊ុន ហ្គាណាត្រេឌើរ អ៊ិនថេលីស៊ីស្ទឹម ឯ.ក Ganatrader Intellisystem CO.,LTD

✓ អាយអេហ្វអិកស៍.ម៉ាឃីត.ឯ.ក IFX. MARKETS CO.,LTD

- ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ (Fund Management Company)
- ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស (Trustee)
- ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង (Distribution)

### ១.៦.៣. តួអង្គចូលរួមដទៃទៀត

#### ១.៦.៣.១. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រមានដូចជា[19]

- ធនាគារ អេស៊ីលីដា ភីអិលស៊ី Acleda Bank Plc.
- ធនាគារ កាណាឌីយ៉ា ក.អ Canadia Bank Plc.
- ធនាគារ វិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី Bank for Investment and Development of Cambodia Plc.
- ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី Cambodian Public Bank Plc.
- ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក B.I.C (Cambodia) Bank Plc.

#### ១.៦.៣.២. ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់

ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់មានដូចជាៈ

- ធនាគារ អេស៊ីលីដា ភីអិលស៊ី Acleda Bank Plc.
- ក្រុមហ៊ុន ត្រាយខ័រ ស៊ីឃ្យូរីធី សឺវីស ភីអិលស៊ី Tricor Securities Services PLC.

[19] ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ "អ្នកចូលរួមទីផ្សារ" http://www.secc.gov.kh/khmer/m59.php?pn=6 (ចូលទស្សនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០)

- ក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី Phnom Penh Securities PLC.

### ១.៦.៣.៣.ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ

ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យផ្តល់សេវានៅក្នុងវិស័យមូលបត្រមានដូចជា

- ក្រុមហ៊ុន ប្រាយវ៉តធ័រ ហាវខូភើស៍ (ខេមបូឌា) PricewaterhouseCoopers (Cambodia) Ltd.

សវនករឯករាជ្យ មានចំនួន ០៣ រូប ៖

- លោក គុយ លីម
- លោកស្រី Benilda Fernando
- លោក ឡាង ហ៊ី

- ក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា KPMG CAMBODIA LTD

សវនករឯករាជ្យ មានចំនួន ០៦ រូប ៖

- លោក ង៉ែ ហ៊ុយ
- កញ្ញា តាំង យុគហ្វុង
- លោក សេង ចាន់ថន
- លោក សុង គន្ធុល
- លោកស្រី ហ្គេក ទាវ
- កញ្ញា Lim Chew Teng

- ក្រុមហ៊ុន ប៊ី ឌី អូ (ខេមបូឌា) លីមីធីត BDO CAMBODIA LIMITED

សវនករឯករាជ្យ មានចំនួន ០៥ រូប៖

- លោក Gan Ah Tee
- លោក Tang Seng Choon
- លោក Law Kian Huat
- លោក Lim Seng Siew
- លោក Lee Ken Wai

- ក្រុមហ៊ុន អឺនស្ទ៍ អ៊ែន យ៉ាំង (ខេមបូឌា) ERNST & YOUNG (CAMBODIA) LTD.

សវនករឯករាជ្យ មានចំនួន ០៤ រូប ៖

- លោកស្រី ឡុន ស៊ីនរតនា
- លោកស្រី Maria Cristina Calimbas

- លោក Cuong Dinh Tran

- កញ្ញា Mary Rose S.Romero

- ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត Grant Thornton (Cambodia) Limited.
  សវនករឯករាជ្យ មានចំនួន ០៥ រូប ៖

  - លោក Jasani Narendrakumar
  - លោក Hooi Kok Mun
  - លោក Almera Ronald Coronel
  - លោក Tan Chee Beng
  - លោក Ng Yee Zent

- ក្រុមហ៊ុន ក្រូវ (ខេអេច) ឯ.ក Crowe(KH) Co.,Ltd.
  សវនករឯករាជ្យ មានចំនួន ០៣ រូប ៖

  - លោក Poon Yew Hoe
  - លោក Onn Kien Hoe
  - លោក Chan Kuan Chee

- ក្រុមហ៊ុន ឌីឡូយធ៍ (ខេមបូឌា) ខូ អិលធីឌី DELOITTE (CAMBODIA) CO., LTD
  សវនករឯករាជ្យ មានចំនួន ០៣ រូប ៖

  - លោក ខូយ គឹមលេង
  - លោក អ៊ឹង គឹមសុភ័ក្រ្តា
  - លោក Ho Kok Yong

- ក្រុមហ៊ុន បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក Baker Tilly (Cambodia) Co., Ltd
  សវនករឯករាជ្យ មានចំនួន ០៤ រូប ៖

  - លោក TAN KHEE MENG
  - លោក ANDREW HENG
  - លោក FU JOE HENG
  - លោក LOCK PENG KUAN

### ១.៦.៣.៤.ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ និងអ្នកវាយតម្លៃឯករាជ្យ

ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ និងអ្នកវាយតម្លៃឯករាជ្យផ្តល់សេវានៅក្នុងវិស័យមូលបត្រមានដូចជា

- ក្រុមហ៊ុន វីត្រាស់ អីព្រេហ្សល VTRUST APPRAISAL Co., Ltd.

  អ្នកវាយតម្លៃឯករាជ្យ មានចំនួន ០៣ រូប ៖

  - លោក ភិន សុធារ

  - លោក យឿន វាយោ

  - លោក ជា សារ៉ាក់

- ក្រុមហ៊ុន ស៊ីងឈ័រ ប្រូផឺធី ឯ.ក THINKTURE PROPERTY CO., LTD

  អ្នកវាយតម្លៃឯករាជ្យ មានចំនួន ០២ រូប៖

  - លោក ហេង ពណ្ណរាយ

  - លោក មាច សុខសូដែន

- ក្រុមហ៊ុន ណាយ ហ្វ្រែង (ខេមបូឌា) Knight Frank (Cambodia) Pte., Ltd

  អ្នកវាយតម្លៃឯករាជ្យ មានចំនួន ០២ រូប៖

  - លោក ROSS WHEBLE

  - លោក សាំង វ៉យចិន្តា

**១.៦.៣.៥. ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល**

ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុលមានដូចជា៖

- អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី ACLEDA Securities Plc

# ជំពូកទី ២

# គណៈកម្មការមូលបត្រកម្ពុជា

# ជំពូកទី ២

# គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) ដែលហៅជាភាសាអង់គ្លេសថា Securities and Exchange commission of Cambodia (SECC) ជាស្ថាប័នដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងបណ្តាប្រតិបត្តិករមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងសំដៅការពារអ្នកវិនិយោគមូលបត្រ ព្រមទាំងធានាឲ្យមានការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវនៅក្នុងវិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា។[20]

## ២.១. ប្រវត្តិនៃការបង្កើតគណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជាត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០៧។ ការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ម.ក. ត្រូវបានធ្វើឡើងដោយ អនុលោមតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០៨។

## ២.២ រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជា

### ២.២.១. រូបសញ្ញា

- រូបហង្សពណ៌មាស[21]។
- រូបភាពស្លឹកឈើផ្នែកខាងឆ្វេងមានរំលេចស្រមោលពណ៌មាស ហើយខាងស្តាំរំលេចស្រមោលពណ៌ប្រផេះ។
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ។
- ព័ទ្ធជុំវិញជារង្វង់នៅផ្នែកខាងលើ ដោយអក្សរខ្មែរថា "គណៈកម្មការមូលបត្រកម្ពុជា" និងព័ទ្ធរង្វង់នៅផ្នែក ខាងក្រោមដោយអក្សរអង់គ្លេសថា **"SECURITIES AND EXCHANGE COMMISSION OF CAMBODIA"**។

[20] សំនួរ-ចម្លើយ "ការអប់រំអំពីមូលបត្រ" http://www.secc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០)

[21] រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញា "អំពី គ.ម.ក" http://www.secc.gov.kh/khmer/m11.php?pn=1 (ចូលទស្សនាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០)

រូបភាពទី២ ៖ រូបសញ្ញានៃគ.ម.ក

**២.២.២. អត្ថន័យនៃរូបសញ្ញា**

- រូបហង្សមានពណ៌មាស តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុ ដែលជាអ្នកត្រួតពិនិត្យ និងគ្រប់គ្រងប្រតិបត្តិការ មូលបត្រ និងធានាឱ្យដំណើរការទីផ្សារមូលបត្រប្រកបដោយប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និង តម្លាភាព។

- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ ដែលតំណាងឱ្យ ភាពចំណេញខាត ឬភាពឡើងចុះនៃដំណើរការទីផ្សារ។

- រូបហង្សពណ៌មាសឈរលើរង្វង់ថាសដែលមានជើងម្ខាងជាន់លើផ្ទៃពណ៌មាស និងជើងម្ខាងទៀតជាន់លើផ្ទៃ ពណ៌ប្រផេះ ចង់បង្ហាញថាភាពចំណេញខាត ឬភាពឡើងចុះនៃកិច្ចដំណើរការទីផ្សារស្ថិតនៅក្រោមការត្រួត ពិនិត្យ និងគ្រប់គ្រងរបស់អាជ្ញាធរជាគណៈកម្មការមូលបត្រកម្ពុជាប្រកបដោយប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និង តម្លាភាព។

- រូបស្លឹកឈើ តំណាងឱ្យលទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យមូលបត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ច- ជាតិ។

មូលហេតុនៃជម្រើសយករូបហង្សពណ៌មាសជានិមិត្តសញ្ញា៖

- រូបហង្សពណ៌មាសជាប់ពាក់ព័ន្ធទៅនឹងដំណើរការវិវឌ្ឍនៃរូបិយវត្ថុរបស់ខ្មែរ ដោយរូបនេះត្រូវបានប្រើប្រាស់ ជាលើកដំបូងនៅលើ**ប្រាក់ប្រាសាទ** ក្នុងរជ្ជកាលព្រះបាទអង្គឌួង ដើម្បីរំលឹកដល់លោក **សំអាងហង្ស** ដែល ព្រះបាទអង្គឌួងបញ្ជូនឱ្យទៅសិក្សាវិជ្ជាបោះផ្សាយប្រាក់នៅបរទេស ហើយលោកបានរួមចំណែកយ៉ាងខ្លាំងក្នុង ការធ្វើឱ្យរូបិយវត្ថុខ្មែរមានអត្តសញ្ញាណច្បាស់លាស់ និងដាក់ឱ្យចរាចរក្នុងសេដ្ឋកិច្ច។

- រូបហង្សពណ៌មាសនេះ ជារូបសញ្ញា តំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាសម័យសង្គមរាស្ត្រនិយម សម័យសាធារណរដ្ឋ និងក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី២ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែល ការណ៍នេះ ត្រូវគ្នានឹងគណៈកម្មការមូលបត្រកម្ពុជា ដែលជាអាជ្ញាធរហិរញ្ញវត្ថុមួយ ហើយមានប្រធានជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់។

រូបភាពទី៣. ៖ ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា



ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា មានលក្ខណៈប្រហាក់ប្រហែលនឹងត្រាមូលរបស់អាជ្ញាធរ ឬស្ថាប័នរដ្ឋដទៃទៀតដែរ ដោយនៅកន្លែងរង្វង់មូលផ្នែកខាងលើមានអក្សរសរសេរថា "ព្រះរាជាណាចក្រកម្ពុជា" ផ្នែកកណ្តាលមានសញ្ញា ប្រាសាទអង្គរវត្ត និងផ្នែកខាងក្រោមមានអក្សរសរសេរថា"គណៈកម្មការមូលបត្រកម្ពុជា "។

## ២.៣. ចក្ខុវិស័យ និងបេសកកម្ម

### ២.៣.១ ចក្ខុវិស័យ

គណៈកម្មការមូលត្រកម្ពុជាហៅកាត់ថា គ.ម.ក ត្រូវបានបង្កើតឡើងក្រោយពីច្បាប់មូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយ និង ជួញដូរមូលបត្រមហាជនបានអនុម័តរួច។ គ.ម.ក មានគោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំ ណែក ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និង

សង្គម តាមរយៈការកៀរគរមូលធនពី សាធារណជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅ កម្ពុជា។[22]

### ២.៣.២ បេសកកម្ម

- បង្កើត និងរក្សាឲ្យមានទំនុកចិត្តពីអ្នកវិនិយោគ នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការ ការពារសិទ្ធិស្របច្បាប់ របស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយ និងការជួញដូរ មូលបត្រប្រកបដោយសណ្តាប់ ធ្នាប់ និង ត្រឹមត្រូវ។
- លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឲ្យមានប្រសិទ្ធភាព និងជំរុញការអភិវឌ្ឍទីផ្សារនេះឲ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ។
- ជំរុញឲ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ញ័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ ហិរញ្ញវត្ថុផ្សេងទៀត។
- ជំរុញឲ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រ នៅក្នុងព្រះរា ជាណាចក្រកម្ពុជា។
- ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ នៅក្នុងព្រះរាជាណា ចក្រកម្ពុជា។

## ២.៤. គោលដៅ និងគោលបំណង

គណៈកម្មការមូលបត្រកម្ពុជា( គ.ម.ក. )មានគោលដៅ និងគោលបំណង[23]ដូចខាងក្រោម៖

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ រួមទាំងទីផ្សារមូលបត្ររដ្ឋនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។
- កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ
- លើកកម្ពស់ និងជម្រុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនានា

[22] ចក្ខុវិស័យ និងបេសកកម្ម “អំពី គ.ម.ក” http://www.secc.gov.kh/khmer/m11.php ( ចូលទស្សនាថ្ងៃទី២០ ខែកក្កដា ឆ្នា ២០២០ )

[23] គោលដៅ និងគោលបំណង, ការអប់រំពីមូលបត្រ http://www.secc.gov.kh/khmer/faq.php?pn=2 ( ចូលទស្សនាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ )

- បង្កើត និងរក្សាទំនុកចិត្តអ្នកវិនិយោគដោយការពារសិទ្ធិរបស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ។
- ជម្រុញការអភិវឌ្ឍន៍ទីផ្សារមូលបត្រ
- ដោះស្រាយវិវាទនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- បង្ការ និងដាក់ទណ្ឌកម្មចំពោះបទល្មើសនានាដែលផ្តល់ផលប៉ះពាល់ដល់ទីផ្សារមូលបត្រ និងអ្នកវិនិយោគ។

## ២.៥. រចនាសម្ព័ន្ធ

គ.ម.ក មានរចនាសម្ព័ន្ធចាត់តាំងដូចខាងក្រោម[24] ៖

រូបភាពទី៤ ៖ រចនាសម្ព័ន្ធចាត់តាំងរបស់គណៈកម្មការមូលបត្រកម្ពុជា




## ២.៦. សមាជិករបស់គណៈកម្មការមូលបត្រកម្ពុជា អាណត្តិទី២ (២០១៣-២០១៨)

គណៈកម្មការមូលបត្រកម្ពុជាដែលមានឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធាន មានសមាជិកចំនួន០៨រូបដែលមានអាណត្តិរយៈពេល០៥ឆ្នាំ។ សមាជិកទាំងនោះរួមមាន:

- ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន គ.ម.ក
- លោកជំទាវ ងួន សុខា រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាសមាជិក គ.ម.ក.

[24] គេហទំព័រគណៈកម្មការមូលបត្រកម្ពុជា ( http://www.secc.gov.kh ) (ចូលទស្សនាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០)

- លោកជំទាវ នាវ ច័ន្ទថាណា អគ្គទេសាភិបាលរងនៃធនាគារជាតិកម្ពុជា និងជាសមាជិក គ.ម.ក.
- លោកជំទាវ តឹកម៉េត កំរង រដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម និងជាសមាជិក គ.ម.ក.
- ឯកឧត្តម កើត រិទ្ធ រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាសមាជិក គ.ម.ក.
- ឯកឧត្តម គឹម រ័ត្នវិសិដ្ឋ ទីប្រឹក្សា និងជានាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាសមាជិក គ.ម.ក.
- ឯកឧត្តម ស៊ូ សុជាតិ អគ្គនាយកនៃ គ.ម.ក និងជាសមាជិក គ.ម.ក.
- លោកសាស្ត្រាចារ្យបណ្ឌិត សំ យង្ស៊ី អ្នកជំនាញមកពីវិស័យឯកជនដែលមានបទពិសោធន៍វិស័យមូលបត្រ និងជាសមាជិក គ.ម.ក.
- លោកសាស្ត្រាចារ្យបណ្ឌិត សំ សុខុម អ្នកជំនាញមកពីវិស័យឯកជនដែលមានបទពិសោធន៍វិស័យមូលបត្រ និងជាសមាជិក គ.ម.ក

## ២.៧. មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា

មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជាមានដូចជា៖

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជារួមទាំងទីផ្សារមូលបត្ររដ្ឋ។
- ដាក់ឱ្យអនុវត្តនូវគោលនយោបាយ ដែលពាក់ព័ន្ធទីផ្សារមូលបត្រ។
- កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។
- លើកកម្ពស់ និងជំរុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់។
- ក្នុងអនុក្រឹត្យដើរតួនាទីជាស្ថាប័នពិនិត្យ និងដោះស្រាយលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់នីតិបុគ្គលមានអាជ្ញាបណ្ណ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សមាជិក អ្នកចូលរួម និងវិនិយោគិន។
- ពិគ្រោះយោបល់ជាមួយបុគ្គលដែលមានលក្ខណៈសម្បត្តិសមស្របដើម្បីបង្កើតការគោលនយោបាយសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រនៅក្នុងប្រទេសកម្ពុជា។
- បំពេញការងារផ្សេងៗទៀតដែលមាននៅចែង។[25]

[25] ច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន, លេខ ៣រល.០០៧១០.៥៥៥, ១៩ តុលា ២០០៧, ប្រការ៧

## ២.៨. មុខងារ និងតួនាទីនាយកដ្ឋានរបស់គណៈកម្មការមូលបត្រកម្ពុជា

គ.ម.ក មាននាយកដ្ឋានចំណុះចំនួន ០៦(ប្រាំមួយ)ដែលត្រូវគ្រប់គ្រងដោយអគ្គនាយកនៃ គ.ម. ក មានដូចជា:

### ២.៨.១ នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ មានមុខងារតួនាទីដូចតទៅ៖

- រៀបចំផែនការ និងថវិការបស់ គ.ម.ក.
- គ្រប់គ្រងកិច្ចការរដ្ឋបាល
- ផ្គង់ផ្គង់ និងជួសជុលសំភារៈបរិក្ខារការិយាល័យ
- ចាត់ចែងការងារពិធីការ
- ធ្វើទំនាក់ទំនងជាមួយស្ថាប័នរដ្ឋ និងឯកជននានា
- រៀបចំគោលនយោបាយ គ្រប់គ្រង និងជ្រើសរើសបុគ្គលិក
- រៀបចំតារាងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភនានាដល់មន្ត្រីនៃ គ.ម.ក.
- គ្រប់គ្រង និងផ្តល់សេវាកម្មបច្ចេកវិទ្យាព័ត៌មាន[26]

### ២.៨.២ នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ

នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ មានមុខងារ និងតួនាទីដូចតទៅ៖

- រៀបចំលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់ការអនុញ្ញាតឲ្យក្រុមហ៊ុននានាបោះផ្សាយលក់មូលបត្រជាសាធារណៈ
- រៀបចំលក្ខខណ្ឌតម្រូវនានា ទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយមូលបត្រជា សាធារណៈ
- ត្រួតពិនិត្យលក្ខខណ្ឌតម្រូវនានា ទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ជាសាធារណៈ ជាប្រចាំ
- ត្រួតពិនិត្យការអនុវត្តតាមស្តង់ដាគណនេយ្យ និងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ត្រួតពិនិត្យ និងផ្តល់យោបល់លើការស្នើសុំបោះផ្សាយមូលបត្រលក់ជាសាធារណៈ

---

[26] អំពីគ.ម.ក, អង្គការចាត់តាំង http://www.secc.gov.kh/khmer/m14.php?pn=1 (ចូលទស្សនាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០)

- ពិនិត្យ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជី ឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារ ផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ
- ចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែង នានារបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ និងផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និង សេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ តាមប្រព័ន្ធអេឡិចត្រូនិក ឬ/និង តាមប្រព័ន្ធផ្សព្វផ្សាយ សាធារណៈ
- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ឬ/និង របាយការណ៍អាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រលក់ ជាសាធារណៈ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែង របស់ក្រុមហ៊ុនស្នើសុំបោះផ្សាយមូលបត្រជាសាធារណៈ ប្រសិនបើមាន ការចាំបាច់ស្របតាមក្របខ័ណ្ឌការងារ
- គ្រប់គ្រងយន្តការបោះផ្សាយលក់មូលបត្រជាសាធារណៈ
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងការបោះផ្សាយលក់ មូលបត្រជាសាធារណៈ ទៅនាយកដ្ឋានកិច្ចការគតិយុត្ត ដើម្បីធ្វើការស៊ើបអង្កេតបន្ត

### ២.៨.៣. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ

នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ មានមុខងារ និងតួនាទីដូចតទៅ៖

- រៀបចំបទបញ្ញត្តិ និងលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុមមូលបត្រ ភ្នាក់ងារក្រុមហ៊ុន មូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូល រួមដ៏នៃនៅក្នុងទីផ្សារ ដើម្បីដាក់សុំការពិនិត្យ និងអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក.
- ពិនិត្យ និងផ្តល់យោបល់ដល់ការស្នើសុំអាជ្ញាប័ណ្ណ ដើម្បីធ្វើជាក្រុមហ៊ុនមូលបត្រ ភ្នាក់ងាររបស់ក្រុមហ៊ុន មូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូល រួមដ៏ទៃទៀតនៅក្នុងទីផ្សារ
- ត្រួតពិនិត្យ និងតាមដាននូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដ៏ទៃទៀតនៅ ក្នុងទីផ្សារ

- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងតាមការចាំបាច់ នូវប្រតិបត្តិការរបស់ ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុន មូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូល រួមដ៏ទៃទៀតនៅក្នុងទីផ្សារ
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធក្រុមហ៊ុនមូលបត្រ ភ្នាក់ងារ ក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដ៏ទៃទៀតនៅក្នុងទីផ្សារ

### ២.៨.៤. នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ

នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រមានមុខងារនិងតួនាទីដូចតទៅះ

- រៀបចំបទបញ្ញត្តិ និងលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុញ្ញាតឲ្យធ្វើប្រតិបត្តិការជាមួយ ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីដាក់សុំការ

  ពិនិត្យ និងអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក.
- ពិនិត្យ និងផ្តល់យោបល់លើពាក្យស្នើសុំការអនុញ្ញាត ដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធទូទាត់ និងជាត់ទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើការផ្គត់ផ្គង់ប្រព័ន្ធជួញដូរមូលបត្រ និងប្រតិបត្តិការផ្សេងៗទៀតរបស់ប្រតិបត្តិករទីផ្សារមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការនៃប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការនៃប្រតិបត្តិកររក្សាទុកមូលបត្រ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងតាមការចាំបាច់ ចំពោះប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធ ជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងប្រតិបត្តិករទីផ្សារ។ មូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ទៅនាយកដ្ឋានកិច្ចការ គតិយុត្តដើគតិយុត្តដើម្បីធ្វើការស៊ើបអង្កេតបន្ត

### ២.៨.៥ នាយកដ្ឋានកិច្ចការគតិយុត្ត

នាយកដ្ឋានកិច្ចការគតិយុត្ត មានមុខងារនិងតួនាទីដូចតទៅៈ

- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីដាក់សុំការត្រួតពិនិត្យ និងសម្រេចពីអគ្គនាយកនៃ គ.ម.ក
- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការដែលស្នើដោយស្ថាប័ននិយ័តករ
- រៀបចំបទប្បញ្ញត្តិចាំបាច់នានា និងលើកសំណើធ្វើវិសោធនកម្មច្បាប់ និងបទបញ្ញត្តិផ្សេងៗដើម្បីគាំទ្រដល់ ការអភិវឌ្ឍវិស័យមូលបត្រ
- ពង្រឹងការអនុវត្តច្បាប់ ឫបទប្បញ្ញត្តិពាក់ព័ន្ធវិស័យមូលបត្រ
- ទទួលពាក្យបណ្តឹង និងធ្វើការស៊ើបអង្កេតពាក់ព័ន្ធនឹងប្រតិបត្តិការបោះផ្សាយ និងជួញដូរមូលបត្រដែល ល្មើសច្បាប់ ឫមិនប្រក្រតី ទាំងនៅក្នុងទីផ្សារដំបូង និងនៅក្នុងទីផ្សារបន្ទាប់
- ពិនិត្យ និងផ្តល់យោបល់ដើម្បីចាត់វិធានការដាក់ពិន័យនានា ពាក់ព័ន្ធនឹងបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- សម្រុះសម្រួលដោះស្រាយវិវាទអ្នកចូលរួមក្នុងទីផ្សារមូលបត្រ
- ចាត់វិធានការជាកពិន័យអន្តរការណ៍ លើបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ពាព័ន្ធនឹង វិស័យមូលបត្រ
- រៀបចំសំណុំរឿងពាក់ព័ន្ធដើម្បីដាក់ពាក្យបណ្តឹងទៅតុលាការ
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ អគ្គនាយកនៃគ.ម.ក

### ២.៨.៦ នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិមានមុខងារតួនាទីដូចតទៅៈ

- សិក្សាស្រាវជ្រាវពីយុទ្ធសាស្ត្រនានាដើម្បីអភិវឌ្ឍវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា សិក្សាស្រាវជ្រាវលើការអភិវឌ្ឍ
- គ្រប់គ្រង និង ការអភិវឌ្ឍវិស័យមូលបត្រ រៀបចំយុទ្ធសាស្ត្រដើម្បីជំរុញឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ សិក្សាវាយតម្លៃ និងផ្តល់យោបល
- រៀបចំយុទ្ធសាស្ត្រ ដើម្បីជំរុញឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ

- សិក្សាវាយតម្លៃ និងផ្តល់យោបល់លើការបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មី មុននឹងអនុញ្ញាតឲ្យបោះផ្សាយនៅលើទីផ្សារ
- រៀបចំកម្មវិធីបណ្តុះបណ្តាលដល់សាធារណជន និងអ្នកចូលរួមនានាក្នុងវិស័យមូលបត្រ
- ធ្វើទំនាក់ទំនងជាមួយនិយ័តករមូលបត្រនៃបណ្តាប្រទេសក្នុងតំបន់ និងនៅក្នុងពិភពលោក
- ចូលរួមក្នុងវេទិកាជាតិ និងអន្តរជាតិពាក់ព័ន្ធនានា

**២.៨.៧. អង្គភាពសវនកម្មផ្ទៃក្នុង**

គ.ម.ក មានអង្គភាពសវនកម្មផ្ទៃក្នុងមួយដែលឋិតនៅក្រោមការដឹកនាំផ្ទាល់របស់ ប្រធានគ.ម.ក។ អង្គភាពសវនកម្មផ្ទៃក្នុងមានមុខងារ និងតួនាទីដូចតទៅៈ

- ត្រួតពិនិត្យលើមុខងារ សកម្មភាព កម្មវិធី និងប្រតិបត្តិការនានារបស់ គ.ម.ក. ក្នុងការិយបរិច្ឆេតសមស្រប ដើម្បីកំនត់ការអនុវត្តអោយបានសមស្របតាមការរៀបចំផែនការ ការចេញបទបញ្ជា និងបទបញ្ញត្តិផ្សេងៗ ការចាត់តាំងការងារ និងការត្រួតពិនិត្យ ដោយផ្អែកតាមគោលនយោបាយ ការណែនាំរបស់ថ្នាក់ដឹកនាំ និង នីតិវិធីជាធរមាន និងស្របតាមគោលដៅរបស់ គ.ម.ក.
- កំនត់ភាពសមស្រប និងប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រង់ផ្ទៃក្នុង ផ្អែកគណនេយ្យ រដ្ឋបាល និងប្រតិបត្តិការនានារបស់ គ.ម.ក.
- ពិនិត្យលើភាពដែលអាចជឿជាក់បាន និងភាពពេញលេញនៃព័ត៌មាន ទិន្នន័យ និងវិធីសាស្ត្រនៃការរៀបចំរបាយការណ៍ អំពីព័ត៌មាន និងទិន្នន័យទាំងនេះក្នុងការិយបរិច្ឆេតសមស្រប
- ពិនិត្យលើប្រព័ន្ធដែលបង្កើតរួច ដើម្បីធានាភាពត្រឹមត្រូវតាមគោលនយោបាយ ផែនការ នីតិវិធីច្បាប់ និងបទបញ្ញត្តិនានា ហើយលើកសំណើកែតម្រូវ និងកែលំអ ប្រសិនបើមានកំហុស
- ពិនិត្យលើមធ្យោបាយក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ គ.ម.ក.
- វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធភាពសេដ្ឋកិច្ច នៃការប្រើប្រាស់ធនធានរបស់ គ.ម.ក. ហើយលើកសំណើដោះស្រាយ និងកែលំអការអនុវត្តិប្រតិបត្តិការ
- ធ្វើសវនកម្មលើកិច្ចប្រតិបត្តិការចំណាយ ចំណូលថវិការបស់ គ.ម.ក. ដើម្បីបញ្ជាក់ភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍សវនកម្មជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ និងជាប្រធាននៃ គ.ម.ក. អំពីការប្រព្រឹត្តិទៅរបស់នាយកដ្ឋាន ឫអង្គភាពដែលបានធ្វើសវនកម្មរួចហើយ

- ធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួន ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដើម្បីផ្ញើជូនប្រធាន និងសមាជិកនៃគ.ម.ក. ពិនិត្យ និងផ្តល់ការណែនាំ
- ធ្វើសវនកម្មផ្ទៃក្នុង នៅពេលដែលមានការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃគ.ម.ក.
- រៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ដើម្បីដាក់ជូនប្រធាន និងសមាជិកនៃ គ.ម.ក. ពិនិត្យ និងសម្រេច
- សម្របសម្រួលការងារសវនកម្មផ្ទៃក្នុង ជាមួយនឹងអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាដំណើរការឲ្យបានគ្រប់ គ្រាន់ និងសមស្រប ជាពិសេសកាត់បន្ថយការងារស្ទួនគ្នា។

# ជំពូកទី៣

# ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

# ជំពូកទី៣
# ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

## ៣.១ ប្រវត្តិផ្សារមូលបត្រកម្ពុជា

ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រទេសកម្ពុជាដោយឈរលើគោលដៅក្នុងការជំរុញកំនើនសេដ្ឋកិច្ចតាមរយៈលំហូរមូលធន ការវិនិយោគ និង ការវិភាជន៍ជាថ្មីនូវមូលធនតាមយន្តការទីផ្សារមូលធន នៅខែ វិច្ឆិកា ឆ្នាំ ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីអំពី "ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា"។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ សម្តេចអគ្គសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានប្រកាសបើកអោយដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជា នៅ ខែកញ្ញា ឆ្នាំ ២០០៧។ នៅឆ្នាំ ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្តីអំពី "ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃ ព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារ មូលបត្រកូរ៉េ។ នៅខែ មីនា ឆ្នាំ ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះកិច្ចព្រមព្រៀង ក្រុមហ៊ុនចំរុះ (Joint Venture) ដើម្បីបង្កើតផ្សារមូលបត្រ ( "ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា" )ស្របតាមច្បាប់ស្តីអំពីសហគ្រាសសាធារណៈ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១០។ ស្របតាមកិច្ចព្រមព្រៀង ក្រុមហ៊ុន ចំរុះ (Joint Venture) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាន់កាប់ភាគហ៊ុនចំនួន ៥៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហើយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុនចំនួន ៤៥%នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានទទួលអាជ្ញាបណ្ណជា ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រ ពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ស្របតាមច្បាប់ស្តីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។[27]

## ៣.២ ចក្ខុវិស័យ និងបេសកកម្ម

- ➢ ចក្ខុវិស័យ[28]
- ដើម្បីកសាងនូវ “មហាវិថី” ហិរញ្ញវត្ថុសម្រាប់កម្ពុជា

[27] ទិដ្ឋភាពទូទៅរបស់ផ.ម.ក “អំពីផ.ម.ក” http://csx.com.kh/kh/about/profile.jsp (ចូលទស្សនាថ្ងៃទី ខែ ឆ្នាំ២០២០)
[28] ចក្ខុវិស័យ និងបេសកកម្ម, “អំពី ផ.ម.ក.” http://csx.com.kh/kh/about/mission.jsp (ចូលទស្សនាថ្ងៃទី ខែ ឆ្នាំ២០២០)

➢ បេសកកម្ម

- ដើម្បីសម្រួលក្នុងការកៀរគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា
- ដើម្បីបង្កើតនូវបរិយាកាសជួញដូរមូលបត្រដែលអំណោយផលដល់អ្នកវិនិយោគិនទាំងក្នុងនិងក្រៅប្រទេស
- ដើម្បីបង្កើតនូវផលិតផលនិងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទសម្រាប់អ្នកចូលរួមទីផ្សារទាំងអស់
- ដើម្បីដាក់ឲ្យដំណើរការនូវសហគ្រាសសាធារណៈមួយដែលមានស្វ័យចិរភាពក្រោមមគ្គុទេសក៍ដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា

## ៣.៣. រចនាសម្ព័ន្ធគ្រប់គ្រង

រូបភាពទី៥៖ រចនាសម្ព័ន្ធគ្រប់គ្រង ផ.ម.ក.




## ៣.៤.ក្រុមប្រឹក្សាភិបាល

រូបភាពទី៦៖ ក្រុមប្រឹក្សាភិបាល ផ.ម.ក.




- ក្រុមប្រឹក្សាភិបាលនៃផ.ម.ក.រួមមានសមាជិកចំនួន ៧រូប ដោយរាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាល(ដែលជាអគ្គនាយករងផងដែរ) និងអគ្គនាយក។ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកជាតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា។ចំណែកឯអនុប្រធានក្រុមប្រឹក្សាភិបាល គឺជាតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។
- សមាជិកចំនួន ៤រូបផ្សេងទៀតគឺជាអភិបាលមិនអចិន្ត្រៃយ៍ ដោយក្នុងនោះ២រូបត្រូវបានតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង២រូបទៀតត្រូវបានតែងតាំងដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

## ៣.៥.សមាជិក

- **បញ្ជីក្រុមហ៊ុនធានាទិញមូលបត្រ**
  - ក្រុមហ៊ុន ភ្នំពេញ ស៊ីយូរីធី ភី អិល ស៊ី
  - អ អេច បី ស៊ីយូរីធី ម.ក
  - កាណា ស៊ីយូរីធី អិល ធី ឌី
  - កម្ពុ ស៊ីយូរីធី អិល ធី ឌី
  - យ៉ាន់តា ស៊ីយូរីធី(ខេមបូឌា) ភី អិល ស៊ី
  - អេស បី អាយ រ៉ូយ៉ាល់ ស៊ីយូរីធី
- **ក្រុមហ៊ុនពាណិជ្ជករមូលបត្រ**
  - ហ្គោលដេន ហ្វ័រឈូន(ខេមបូឌា) ស៊ីយូរីធី ភី អិល ស៊ី
- **ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ**
  - ខេមបូឌា-វៀតណាម ស៊ីយូរីធី ភី អិល ស៊ី
  - អេស៊ីលីដា ស៊ីយូរីធី ភី អិល ស៊ី
  - ខេប ស៊ីយូរីធី លីមីតធី

# ជំពូកទី ៤
# ការវិនិយោគមូលបត្រនៅកម្ពុជា

# ជំពូកទី៤

# ការវិនិយោគមូលបត្រនៅកម្ពុជា

## ៤.១. ការដួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រកម្ពុជា

គិតមកដល់ឆ្នាំ២០១៩នេះ ទីផ្សារមូលបត្រដំណើរការបានជិតមួយទសវត្សហើយ ដោយមានការវិវឌ្ឍខ្លួនពីមួយឆ្នាំទៅមួយឆ្នាំដោយសំរបខ្លួនទៅតាមសេដ្ឋកិច្ចពិភពលោកដើម្បីធ្វើជាប្រភពចំណូលមួយផ្នែកទៀតជូនក្រុមហ៊ុនក្នុងស្រុកក្នុងការស្វែងទុនបន្ថែមដើម្បីធ្វើអោយមានភាពប្រសើរឡើងនៃប្រតិបត្តិការ និងការពង្រីកអាជីវកម្មជាដើម។ នៅក្នុងទីផ្សារមូលបត្រនៅកម្ពុជា មានវិនិយោគិនចំនួន ១៧% ជាវិនិយោគិនក្នុងស្រុក និង ៨៣% ជាវិនិយោគិនបរទេស។

បច្ចុប្បន្នមានក្រុមហ៊ុនចំនួន ៨ ដែលបានចុះបញ្ជីក្នុងការលក់មូលបត្រ ហើលយក្រុមហ៊ុនទាំងនោះបានប្រមូលទុនបន្ថែមរួមគ្នាចំនួន ១៥១ លានដុល្លារដែលក្នុងនោះមាន ៧១ លានដុល្លារបានពីការលក់មូលបត្របំណុល និង ៨០ លានដុល្លារបានពីការលក់មូលបត្រកម្មសិទ្ធ។

ក្រុមហ៊ុនដែលបានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធមានចំនួន ៥ ដូចជា៖ ក្រុមហ៊ុន ភ្នំពេញអេស ស៊ីហ្សិត ភីអិលស៊ី, កំពង់ផែស្វយ័តក្រុងព្រះសីហនុ, ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ីនធើណេសិនណល ( ខេមបូឌា ) ភីអិលស៊ី និង រដ្ឋាករស្វយ័តក្រុងភ្នំពេញ។ ចំពោះមូលបត្របំណុល មានក្រុមហ៊ុនចំនួន ៣ ដែលបានចុះបញ្ជីដូចជា៖ ធនាគារវឌ្ឍន:អាស៊ីចំកាត់, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី( ខេមបូឌា ) ភីអិលស៊ី។

ក្រុមហ៊ុនដែលបានចុះបញ្ជីនៅផ្សារមូលបត្រក្នុងស្រុកក៏បានទទូលការអនុគ្រោះពីពន្ធដារជាច្រើនមានទាំងការអនុគ្រោះលើបំណុលពន្ធ និងការកាត់បន្ថយពន្ធលើប្រាក់ចំណូល ៥០% រយៈពេល ៣ ឆ្នាំផងដែរ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីជាសាធារណៈលើកដំបូង។

មិនត្រឹមតែមានការលើកទឹកចិត្តពីពន្ធដារប៉ុណ្ណោះទេ ក្រុមហ៊ុនដែលលបានចុះបញ្ជីលក់មូលបត្រក៏បានការលើកទឹកចិត្តពីភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដូចជា៖ ធនាគារកាណាឌីយ៉ា ក.អ, ធនាគារ សាធារណៈ ភីអិលស៊ី, ធនាគារ អេស៊ីលីដា ភីអិលស៊ី។ ការលើកទឹកចិត្តរួមមាន៖ ការផ្តល់កម្ចីឥណទានក្នុងអត្រាការប្រាក់ពិសេស និងការផ្តល់អត្រាការប្រាក់ពិសេសសម្រាប់ការដាក់ប្រាក់បញ្ញើរមានកាលកំណត់។

## ៤.២. ការវិនិយោគមូលបត្រកម្មសិទ្ធិ

### ៤.២.១. ដំណាក់កាលទី១ ការត្រៀមខ្លួនមុននឹងជួញដូរ[29]

#### ៤.២.១.១. ការជ្រើសរើសក្រុមហ៊ុនមូលបត្រ

- វិនិយោគិនជ្រើសរើសក្រុមហ៊ុនមូលបត្រ ដែលទទួលបានអាជ្ញាប័ណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ធ្វើអាជីវកម្មឈ្មួញជើងសារមូលបត្រ និងជាសមាជិករបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)។
- វិនិយោគិនត្រូវពិចារណាអំពីកម្រៃជើងសា (Commission Fee) និងសេវាកម្ម។

#### ៤.២.១.២. ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន (Investor ID)

- ដាក់ពាក្យស្នើសុំមក គ.ម.ក. ដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក.។[30]
- វិនិយោគិនត្រូវបំពេញបែបបទ និងភ្ជាប់មកជាមួយនៅឯកសារដូចខាងក្រោម៖
  - សម្រាប់វិនិយោគិនជារូបវន្តបុគ្គល

    - បំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន (ទម្រង់ ក) ដោយមានបិត រូបថតចំពីមុខ ទំហំ ៤ x ៦ ចំនួន ១ សន្លឹក។

    - ភ្ជាប់មកជាមួយនូវឯកសារ៖

    + អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរសម្រាប់វិនិយោគិនសញ្ជាតិខ្មែរ។

    + លិខិតឆ្លងដែនសម្រាប់វិនិយោគិនមិនមែនសញ្ជាតិខ្មែរ។

    + ប្រវត្តិរូបសង្ខេបដោយមានព័ត៌មានស្តីពីប្រវត្តិសិក្សា និងបទពិសោធន៍ការងារ។

    + ២០០០០ រ និងមានសុពលភាពរយៈពេល ១០ ឆ្នាំ។
  - សម្រាប់វិនិយោគិនជានីតិបុគ្គល៖

    - បំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន (ទម្រង់ ខ) ដោយមានបិត រូបថតចំពីមុខ ទំហំ ៤ x ៦ ចំនួន ១ សន្លឹក របស់បុគ្គលមានសិទ្ធិចុះហត្ថលេខាក្នុងនាមនីតិបុគ្គល។

    - ភ្ជាប់មកជាមួយនូវឯកសារ៖

    + វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម

---

[29] កែប សំភី,២០២០, ការត្រៀមខ្លួនមុនជួញដូរ, (អត្ថបទបង្ហាញដល់និស្សិតឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)

[30] គ.ម.ក, គោលការណ៍ណែនាំស្តីពីការផ្តល់អត្តសញ្ញាណវិនិយោគិន , លេខ ០០១/គ.ម.ក./គ.ណ.ន., ៦ ខែ កុម្ភៈ ២០១២

+ វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ប្រសិនបើមាន

+ ឈ្មោះអភិបាល ដោយបញ្ជាក់ពីសញ្ជាតិ (អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន)

+ លិខិតផ្ទេរសិទ្ធិដល់បុគ្គលតំណាងចុះហត្ថលេខាក្នុងនាមនីតិបុគ្គល និងប្រវត្តិរូបសង្ខេបរបស់បុគ្គលតំណាងចុះហត្ថលេខាក្នុងនាមនីតិបុគ្គល ដោយមានព័ត៌មានស្ដីពីប្រវត្តិសិក្សា និងបទពិសោធន៍ការងារ។

+ បញ្ជីឈ្មោះអ្នកដែលមានសិទ្ធ ឬចូលរួមក្នុងការសម្រេចចិត្តវិនិយោគក្នុងវិស័យមូលបត្រ

+ ៥០០០០ រ និងមានសុពលភាពរយៈពេល ១០ ឆ្នាំ។

❖ ការផ្ដល់លេខអត្តសញ្ញាណវិនិយោគិន

- **គ.ម.ក.** នឹងផ្ដល់ជូនលេខអត្តសញ្ញាណវិនិយោគិនក្នុងរយៈពេល ០៥ ថ្ងៃនៃថ្ងៃធ្វើការដោយគិតចាប់ពីថ្ងៃទទួលបានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវក្នុងទម្រង់អេឡិចត្រូនិច (Soft Copy) និងទម្រង់បោះពុម្ព (Hard Copy)។
- វិនិយោគិនមួយទទួលបានលេខអត្តសញ្ញាណវិនិយោគិនតែមួយគត់។
- វិនិយោគិនអាចស្នើសុំបន្តលេខអត្តសញ្ញាណវិនិយោគិន មុនពេលអស់សុពលភាព ៣ ខែ។

#### ៤.២.១.៣. ការបើកគណនីជួញដូរ

- បើកគណនីជួញដូរនៅក្រុមហ៊ុនមូលបត្រដែលបានជ្រើសរើស

❖ វិនិយោគិន អាចបើកគណនីជួញដូរបានតែមួយគត់ជាមួយក្រុមហ៊ុនមូលបត្រនីមួយៗ

❖ ក្រុមហ៊ុនមូលបត្រ ត្រូវយកសាច់ប្រាក់ដែលអតិថិជនដាក់តម្កល់ ដាក់នៅក្នុងគណនីសាច់ប្រាក់អតិថិជន (Client Money Account) នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA) ដាច់ដោយឡែកពីគណនីសាច់ប្រាក់ផ្ទាល់ខ្លួនរបស់ក្រុមហ៊ុនមូលបត្រ។ ចំពោះមូលបត្រ ត្រូវដាក់តម្កល់នៅប្រតិបត្តិកររក្សាទុកមូលបត្រ។

❖ យ៉ាងហោចណាស់មួយថ្ងៃបន្ទាប់ពីបើកគណនីជួញដូររួច ទើបវិនិយោគិនអាចដាក់បញ្ជាទៅក្នុងប្រព័ន្ធជួញដូររបស់ **ផ.ម.ក.** បាន។[31]

### ៤.២.២. ការទិញភាគហ៊ុននៅទីផ្សារដំបូង

❖ **ដំណាក់កាលប៊ុកបៀលឌីង**

- ភាគហ៊ុនដែលត្រូវដាក់ឱ្យធ្វើប៊ុកបៀលឌីង មានចំនួន ៧០% នៃភាគហ៊ុនសរុប។

[31] ស៊ូ សុជា និងអ៊ុង នីតា(២០១៥), «ការវិនិយោគលើមូលបត្រនៅផ្សារមូលបត្រកម្ពុជា និងការវិភាគលើភាគហ៊ុន» សាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច) ទំព័រ ៣១

- វិនិយោគិនដែលចូលរួមក្នុងដំណើរការធ្វើប៊ុកបៀលឌីង ត្រូវបំពេញពាក្យស្នើសុំដែលកំណត់ដោយ គ.ម.ក.។
- វិនិយោគិន ត្រូវជ្រើសរើសថ្លៃមួយក្នុងចន្លោះថ្លៃ (Price Range) នៃថ្លៃមូលបត្រកម្មសិទ្ធិ ក្នុងឯកសារផ្តល់ព័ត៌មាន។
- វិនិយោគិន ត្រូវតម្កល់ប្រាក់ ១០% នៃថ្លៃមូលបត្រកម្មសិទ្ធិសរុប។
- ដាក់ពាក្យស្នើសុំទៅកាន់ ក្រុមហ៊ុនធានាទិញមូលបត្រ។
- ពុំមានកម្រៃជើងសានោះទេ។[32]

❖ **ដំណាក់កាលបរិវិសកម្ម**

- ភាគហ៊ុនដែលត្រូវដាក់ឱ្យធ្វើបរិវិសកម្ម មានចំនួន ៣០% នៃភាគហ៊ុនសរុប។
- វិនិយោគិនដែលចូលរួមក្នុងដំណើរការធ្វើបរិវិសកម្ម ត្រូវបំពេញពាក្យស្នើសុំដែលកំណត់ដោយ គ.ម.ក.។
- ថ្លៃសម្រាប់ធ្វើបរិវិសកម្ម គឺជាថ្លៃទទួលបានពីការធ្វើ Book Building។
- វិនិយោគិន ត្រូវតម្កល់ប្រាក់ ១០០% នៃថ្លៃមូលបត្រកម្មសិទ្ធិសរុប។
- ដាក់ពាក្យស្នើសុំទៅកាន់ ក្រុមហ៊ុនធានាទិញមូលបត្រ។
- ពុំមានកម្រៃជើងសានោះទេ។

### ៤.២.៣ ការជួញដូរ (ទិញ-លក់) ភាគហ៊ុននៅទីផ្សារបន្ទាប់

#### ៤.២.៣.១. ការដាក់បញ្ជា និងនីតិវិធីក្នុងការជួញដូរ

- វិនិយោគិនអាចដាក់បញ្ជាបានលុះត្រាតែមានសាច់ប្រាក់យ៉ាងហោច ១០០% (សម្រាប់បញ្ជាទិញ) ) ដែលរួមបញ្ចូលទាំងថ្លៃសេវាឈ្មួញជើងសារមូលបត្រ ឬបរិមាណមូលបត្រយ៉ាងហោច ១០០% (សម្រាប់បញ្ជាលក់)។
- ពេលបញ្ជាត្រូវបានបញ្ជូនចេញ សាច់ប្រាក់និងមូលបត្រទាំងនេះ នឹងត្រូវបានបង្កកទុកដោយសមាជិកក្នុងគោលបំណងដើម្បីទូទាត់ ឬបង្កកទុករហូតដល់ពេលបញ្ជានោះអស់សុពលភាព។

[32] គោលការណ៍ណែនាំស្តីពី ការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ, លេខ០០២/១២គ.ម.ក/គណន ០៩ កុម្ភៈ ២០១២

## រូបភាពទី ៧ ៖ ការដាក់បញ្ជា និងនីតិវិធីក្នុងការជួញដូរ




- ( ១ ) វិនិយោគិនបើកគណនីជួញដូរ ( គណនីមូលបត្រ និងគណនីសាច់ប្រាក់ ) នៅក្រុមហ៊ុនមូលបត្រនៅថ្ងៃ T-1។ ក្រុមហ៊ុនមូលបត្រនឹងធ្វើការស្នើសុំលេខអត្តសញ្ញាណវិនិយោគិនជូនអតិថិជនរបស់ខ្លួនពីគណៈកម្មការមូលបត្រកម្ពុជា។
- ( ២ ) វិនិយោគិន ផ្តល់សេចក្តីបង្គាប់ឲ្យដាក់បញ្ជាទិញ ឬលក់នៅថ្ងៃ T+0 ទៅកាន់ក្រុមហ៊ុនមូលបត្រជាលាយលក្ខណ៍អក្សរ ជាពាក្យសម្តី ( ត្រូវបានថតទុកដោយអ្នកតំណាងនៅក្នុងទីផ្សារ ) ឬមធ្យោបាយអេឡិចត្រូនិចនានា។
- ( ៣ ) ក្រោយពីត្រួតពិនិត្យមូលបត្រ និងសាច់ប្រាក់នៅក្នុងគណនីរបស់វិនិយោគិន ( សាច់ប្រាក់ ឬបរិមាណមូលបត្រមួយរយភាគរយដែលពាក់ព័ន្ធនឹងបញ្ជានោះ ) អ្នកតំណាងនៅក្នុងទីផ្សារដាក់បញ្ជាតាមការបង្គាប់មកក្នុងប្រព័ន្ធជួញដូររបស់ **ផ.ម.ក.** នៅថ្ងៃ T+0។ សាច់ប្រាក់ ឬមូលបត្រនឹងត្រូវបានបង្កកទុកសម្រាប់ទូទាត់នៅថ្ងៃ

  T+2។
- ( ៤ )ការបញ្ជាទាំងឡាយត្រូវបានផ្គូរផ្គងនៅក្នុងប្រព័ន្ធជួញដូររបស់ **ផ.ម.ក.** ទៅតាមគោលការណ៍ដេញថ្លៃដែលបានកំណត់ទុកជាមុន។
- ( ៥ ) **ផ.ម.ក.** ជូនដំណឹងអំពីលទ្ធផលនៃការជួញដូរទៅកាន់ក្រុមហ៊ុនមូលបត្រ នៅថ្ងៃ T+0។[33]

[33] ការបើកគណនី និង នីតិវិធីក្នុងការជួញដូរ, ប្រតិបត្តិការរបស់ ផ.ម.ក http://csx.com.kh/operation/market/listPosts.do?MNCD=30201 ( ចូលទស្សនាថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ )

- (៦) ក្រុមហ៊ុនមូលបត្របញ្ជាក់លទ្ធផលនៃការជួញដូរដែលពាក់ព័ន្ធជាមួយ អតិថិជននីមួយៗរបស់ខ្លួននៅថ្ងៃ T+0។[34]
- (៧) ក្នុងករណីមានកំហុសឆ្គងដែលបង្កឡើងដោយក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនមូលបត្រនោះត្រូវដាក់ពាក្យស្នើសុំមកកាន់ **ផ.ម.ក.** ដើម្បីកែតម្រូវអោយបានមុនពេលថ្ងៃត្រង់នៃថ្ងៃ T+1។ បន្ទាប់ពីកំហុសឆ្គងត្រូវបានកែតម្រូវហើយ ដំណើរការក្នុងចំនុចទី៥ និងទី៦ នឹងត្រូវអនុវត្តម្តងទៀត។
- (៨) វិនិយោគិនបង់ប្រាក់ ឬបញ្ជូនមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រនៅថ្ងៃ T+2។
- (៩) ក្រុមហ៊ុនមូលបត្រទូទាត់ការជួញដូរក្នុងនាមជាវិនិយោគិននៅ **ផ.ម.ក.** ។

**៤.២.៣.២. ម៉ោងជួញដូរ**

ផ្សារមូលបត្រកម្ពុជា អនុវត្តការជួញដូរមូលបត្រកម្មសិទ្ធដូចខាងក្រោម៖

- ថ្ងៃជួញដូរចាប់ផ្តើមពីថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ លើកលែងតែថ្ងៃឈប់សម្រាកជាសាធារណៈ។
- ម៉ោងជួញដូរចាប់ផ្តើមពីម៉ោង ០៨:០០ ព្រឹក រហូតដល់ ១៥:០០ រសៀល។
- ការអនុវត្តការជួញដូរ ឬ ការផ្គូផ្គងធ្វើឡើង ០៣ (បី) ដងក្នុងមួយថ្ងៃគឺ៖
  - ការផ្គូរផ្គងលើកទី១ នៅម៉ោង ៩:០០ ព្រឹក
  - ការផ្គូរផ្គងលើកទិ២ នៅម៉ោង ១៤:៥០ រសៀល
  - ការផ្គូរផ្គងលើកទី៣ នៅម៉ោង ១៥:៣០ រសៀល[35]

រូបភាពទី ៨ ៖ ពេលវេលានៃការជួញដូរនៅទីផ្សារមូលបត្រកម្ពុជា




- ចំពោះរូបិយបណ្ណបរទេសត្រូវប្តូរទៅជារូបិយបណ្ណជាតិ

**៤.២.៣.៣. ប្រភេទនៃបញ្ជា**

[34] ទិដ្ឋភាពទូទៅនៃការជួញដូរ, ប្រតិបត្តិការរបស់ ផ.ម.ក. http://csx.com.kh/operation/market/listPosts.do?MNCD=30201 (ចូលទស្សនាថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០)

[35] គេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ប្រតិបត្តិការទីផ្សារ៖ ម៉ោងជួញដូរ

នៅលើផ្សារមូលបត្រកម្ពុជាមានបញ្ជា ៣ប្រភេទដែលត្រូវបានដាក់ដំណើរការ៖

- **បញ្ជាដែនកំណត់** គឺជាប្រភេទបញ្ជាដែលថ្លៃបញ្ជាទិញជាថ្លៃដែលហ៊ានអោយតម្លៃខ្ពស់បំផុត ហើយថ្លៃបញ្ជាលក់មានតម្លៃទាបបំផុត។
- **បញ្ជាទីផ្សារ** គឺជាបញ្ជាដែលគេប្រើប្រាស់ដើម្បីទិញលក់មូលបត្រកម្មសិទ្ធិមួយភ្លាមៗ ក្នុងតម្លៃមួយដែលល្អបំផុតនៅលើទីផ្សារ។ បញ្ជាទីផ្សារត្រូវប្រកាន់ខ្ជាប់នូវលក្ខខណ្ឌ ២ គឺ លក្ខខណ្ឌជួញដូរទាំងស្រុង រឺ លុបចោល និងលក្ខខណ្ឌដេញថ្លៃហើយលុបចោល។ លក្ខខណ្ឌទាំងពីរនេះអាចប្រើប្រាស់បានតែក្នុងវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើននៅពេលដែលមានបញ្ជាផ្ទុយគ្នានៅផ្នែកម្ខាងទៀត។ បញ្ជាទីផ្សារមិនត្រូវបានអនុញ្ញាតិអោយមានប្រតិបត្តិការផ្តល់សន្ទនីយភាពមូលបត្រ និងការជួញដូរលើកដំបូងនៃមូលបត្រចុះបញ្ជីលក់លើកដំបូងឡើយ។
- **បញ្ជាតាមការចរចារ** គឺជាបញ្ជានៅពេលទិញ រឺ លក់មូលបត្រដោយប្រើវិធីសាស្ត្រជួញដូរតាមការចរចា។ បញ្ជាប្រភេទនេះធានាដល់ការជួញដូររបស់វិនិយោគិនតែក្នុងប្រតិបត្តិការធំប៉ុណ្ណោះ និងជួយរក្សាការសម្ងាត់ដល់បញ្ជា និងការជួញដូររបស់វិនិយោគិននៅអំឡុងពេលម៉ោងជួញដូរ។[36]

**៤.២.៣.៤. ឯកតាជួញដូរ/ឯកតាថ្លៃ**

- ឯកតានៃរាល់ការដាក់បញ្ជាទិញ/លក់ មូលបត្រកម្មសិទ្ធិ គឺ ០១ (មួយ) ភាគហ៊ុន។

- ឯកតា នៃការជួញដូរ មូលបត្រកម្មសិទ្ធិអប្បបរមា ចាប់ពី ០១ (មួយ) ភាគហ៊ុន។

- ចលនានៃថ្លៃ ត្រូវបានផ្អែកលើ ថ្លៃឯកតា (គម្លាតថ្លៃ) នៃតារាងតម្លៃ ដូចខាងក្រោម: (ទឹកប្រាក់ទាំងអស់គឺ ជាប្រាក់រៀល)។

| ថ្លៃ (P) | ឯកតាគម្លាតថ្លៃ | ឧទាហរណ៍ថ្លៃបញ្ជាដែលខុស | ឧទាហរណ៍ថ្លៃបញ្ជាដែលត្រឹមត្រូវ |
|---|---|---|---|
| ]0 – ៤.000[ | ១០ | ២.៥៥៥; ៣.០១២; ៣.៩៩៩ | ២.៥៥០; ២.៥៦០; ៣.០១០; ៣.០២០; ៣.៩៩០ |
| [៤.000 – ២0.000[ | ២០ | ៤.២១០; ១៩.៥២៥ | ៤.២០០; ៤.២២០; ១៩.៥២០; ១៩.៥៤០ |

[36] http://csx.com.kh/operation/market/listPosts.do?MNCD=30201 (ចូលទស្សនាថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០)

| | | | |
|---|---|---|---|
| [២០.០០០ – ៥០.០០០[ | ៥០ | ២០.១១០; ៣៥.៥៣០ | ២០.១០០; ២០.១៥០; ៣៥.៥០០; ៣៥.៥៥០ |
| [៥០.០០០ – ១០០,០០០[ | ១០០ | ៥០.៧២០; ៩០.៤៥០ | ៥០.៧០០; ៥០.៨០០; ៩០.៤០០; ៩០.៥០០ |
| [១០០.០០០ – ២០០.០០០[ | ២០០ | ១៥០.៥០០; ១២៥.៣០០ | ១៥០.៤០០; ១៥០.៦០០; ១២៥.២០០; ១២៥.៤០០ |
| [២០០.០០០ – ៥០០.០០០[ | ៥០០ | ៣០០.១០០; ៣៥០.២០០ | ៣០០.០០០; ៣០០.៥០០; ៣៥០.០០០; ៣៥០.៥០០ |
| [៥០០.០០០ – [ | ១.០០០ | ៦២០.៥០០; ៨៥២.១០០ | ៦២០.០០០; ៦២១.០០០; ៨៥២.០០០; ៨៥៣.០០០ |

### ៤.២.៣.៥. ដែនប្រែប្រួលថ្លៃប្រចាំថ្ងៃ

ថ្លៃបម្រែបម្រួលប្រចាំថ្ងៃគឺមិនលើស និងមិនក្រោម ៥%នៃថ្លៃមូលដ្ឋានឡើយ។

- រូបិយប័ណ្ណជួញដូរៈ ប្រាក់រៀល
- ការជួញដូរមុន ការទូទាត់: បន្ទាប់ពី ការជួញដូរត្រូវបានបញ្ចប់ នៅ T + 0 ថ្ងៃមូលបត្រ ឬ ការទូរទាត់សាច់ប្រាក់ត្រូវបានទូទាត់ និងផ្ទេរ ទៅគណនីរបស់អ្នកនៅ ថ្ងៃ T + 2 ថ្ងៃ។ ទោះយ៉ាងណា ផ្សារមូលបត្រកម្ពុជា បានអនុញ្ញាតឱ្យ វិនិយោគិន ប្រើប្រាស់ ធនធានទាំងនោះ ដើម្បីលក់ឬ ទិញមូលបត្រម្តងទៀត នៅថ្ងៃដដែល (T + 0) ដោយមិនចាំបាច់ រង់ចាំរហូតដល់ អ្នកបានទទួលការទូទាត់ជាផ្លូវការនោះទេ។

### ៤.២.៣.៦. វិធីសាស្ត្រជួញដូរ

➢ **វិធីសាស្ត្រដេញថ្លៃ (Auction Trading Method)**

- **<u>វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ</u>**៖ បញ្ជាទិញនិងបញ្ជាលក់ទាំងអស់ ត្រូវផ្គូផ្គងព្រមគ្នានិងជួញដូរនៅថ្លៃតែមួយ និង ថ្លៃផ្គូផ្គងជាថ្លៃដែលអាចផ្គូផ្គងនៅបរិមាណច្រើនបំផុត។

| បញ្ជាលក់Ask | ថ្លៃ Price | បញ្ជាទិញBid |
|---|---|---|
| | 10,500 | |
| | 10,400 | |
| | 10,300 | |
| | 10,200 | |
| | 10,100 | |
| 600 | សរុប Total | 700 |

ដល់ម៉ោងជួញដូរ At executed time (ម៉ោង 09:00 AM ឬ 3:00 PM)

600 x 10,400 ៛ = 6,240,000 ៛

- <u>**វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន**</u>៖ បញ្ជាទិញឬបញ្ជាលក់មួយត្រូវបានផ្គូផ្គង និងអាចជួញដូរនៅថ្លៃច្រើនផ្សេងៗគ្នា និងនៅពេលបញ្ជាទិញនិងលក់ត្រូវគ្នា ថ្លៃផ្គូផ្គងត្រូវជ្រើសយកថ្លៃរបស់បញ្ជាដែលទទួលបានមុន។

| បញ្ជាលក់Ask | ថ្លៃ Price | បញ្ជាទិញBid |
|---|---|---|
| | 10,500 | |
| | 10,400 | |
| | 10,300 | |
| | 10,200 | |
| | 10,100 | |
| 600 | សរុប Total | 700 |

ម៉ោងជួញដូរ At executed time

(09:00 AM - 02:50 PM)

1. 200 x 10,300 ៛ = 2,060,000 ៛ (ភ្លាមៗ)
2. 300 x 10,400 ៛ = 3,120,000 ៛ (ភ្លាមៗ)
3. 100 x 10,400 ៛ = 1,040,000 ៛ (ភ្លាមៗ)

6,220,000 ៛

➢ **វិធីសាស្ត្រជួញដូរតាមការចរចា** (**Negotiated Trading Method**) គឺជាវិធីសាស្ត្រផ្គូផ្គងបញ្ជាតាមការចរចាទិញនិងលក់មួយគូ បន្ទាប់ពីភាគីទាំងពីរបានចរចា និងព្រមព្រៀងលើលក្ខខណ្ឌទាំងឡាយនៃការជួញដូរ។ ដើម្បីផ្គូផ្គងបញ្ជាទិញ និងលក់តាមការចរចាមួយគូបាន ចាំបាច់ត្រូវមានព័ត៌មានលម្អិតដូចគ្នាទាំងស្រុងចំនួន ៤ គឺ ឈ្មោះមូលបត្រ, ថ្លៃ, បរិមាណ និងលេខកូដជួញដូរតាមការចរចា។

- លក្ខណៈសំខាន់ៗនៃវិធីសាស្ត្រជួញដូរតាមការចរចារៈ

- **បញ្ជាអប្បបរមា៖** បញ្ជាតាមការចរចាត្រូវមានបរិមាណយ៉ាងហោច ៥០.០០០ ភាគហ៊ុន ឬតម្លៃជួញដូរ ២០០.០០០.០០០រៀល (យកមួយណាដែលតូចជាង)។

- **ឯកតាគម្លាតថ្លៃ៖** ១រៀល។

- **ដែនកំណត់ថ្លៃប្រចាំថ្ងៃ៖** មិនអនុវត្តចំពោះការជួញដូរតាមវិធីសាស្ត្រជួញដូរតាមការចរចា។

- **ការលុបចោលបញ្ជា៖** ដរាបណាបញ្ជា មិនទាន់អនុវត្តការជួញដូរ នោះបញ្ជាតាមការចរចាអាចលុបបាន តែពុំអាចកែប្រែបានឡើយ។

**៤.២.៣.៧. យន្តការនៃការផាត់ទាត់ និងការទូទាត់**

ដើម្បីផ្តល់ភាពងាយស្រួលក្នុងការទូទាត់សាច់ប្រាក់ និងទូទាត់មូលបត្រនៅក្នុងដំណើរការនៃការផាត់ទាត់និងទូទាត់ និងទូទាត់មូលបត្រកម្មសិទ្ធិ សមាជិក (សំដៅដល់ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក. ដោយមានសិទ្ធិ ប្រើប្រាស់នូវប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្ររបស់ ផ.ម.ក.) នៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ តម្រូវឱ្យបើកគណនី ០២(ពីរ) ប្រភេទ គឺបើកគណនីទូទាត់សាច់ប្រាក់ និងគណនីមូលបត្រសម្រាប់ការទូទាត់មូលបត្រ។

➢ **ការផាត់ទាត់**

នៅពេលព័ត៌មានជួញដូរត្រូវបានបញ្ជាក់ដោយអតិថិជននិងបានផ្ទៀងផ្ទាត់ដោយសមាជិកទាំងអស់ដែលតំណាងឲ្យអតិថិជនរួចហើយក្រុមហ៊ុនមូលបត្រត្រូវតាំងនាមឲ្យអតិថិជនក្នុងការទូទាត់សាច់ប្រាក់សម្រាប់មូលបត្រដែលបានទិញឬបញ្ជូនមូលបត្រដែលបានលក់ទៅកាន់ភាគីម្ខាងទៀតដែលជាសមាជិកនិងជាអន្តរការីរបស់អ្នកលក់មូលបត្រឬអ្នកទទួលមូលបត្រដោយប្រើប្រាស់ប្រាក់ឬមូលបត្រដែលបានបង្កកទុករួចហើយក្នុងភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA)។[37]

ការផាត់ទាត់គឺជាលំដាប់នៃដំណើរការដែល Central Counter-party (CCP) ចាត់ចែងធានាលើការទូទាត់ដោយការបន្សុទ្ធ ឬកាត់កង netting ឥណទាន និងបំណុលទាំងឡាយរវាងអ្នកលក់ និងអ្នកទិញ។

[37] កែប សំភី, ប្រតិបត្តិការផាត់ទាត់ ទូទាត់មូលបត្រ និងការរក្សាទុក, (អត្ថបទបង្ហាញដល់សម្រាប់ឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)

- **Central Counter- party ( CCP )**:សំដៅលើអង្គភាពដែលទទួលយកកាតព្វកិច្ចជាអ្នកទិញចំពោះអ្នកលក់ទាំងអស់ និងជាអ្នកលក់ចំពោះអ្នកទិញទាំងអស់។ តាមវិធីនេះ អ្នកទិញ និងអ្នកលក់មិនមានកាតព្វកិច្ចហិរញ្ញវត្ថុចំពោះគ្នាទៅវិញទៅមកទេ ផ្ទុយទៅវិញត្រូវមានកាតព្វកិច្ចហិរញ្ញវត្ថុចំពោះ CCP។ ក្នុងករណីនេះផ្សារមូលបត្រកម្ពុជា (ផ.ម.ក)មានតួនាទីជា CCPនៅក្នុងផ្សារមូលបត្រកម្ពុជា។

រូបភាពទី ៩ ៖ យន្តការនៃការជាត់ទាត់ និងការទូទាត់




- **ការទូទាត់**

ការទូទាត់គឺជាការបញ្ចប់ប្រតិបត្តិការដែលអ្នកលក់ផ្ទេរមូលបត្រឬឧបករណ៍ហិរញ្ញវត្ថុទៅឲ្យអ្នកទិញ ចំណែកអ្នកទិញបានផ្ទេរសាច់ប្រាក់ទៅអ្នកលក់វិញ។ការទូទាត់សាច់ប្រាក់ត្រូវបានធ្វើឡើងតាមរយៈការផ្ទេរសាច់ប្រាក់ពីគណនីមូលបត្ររបស់សមាជិកទៅគណនីទូទាត់មូលបត្ររបស់ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ។ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ត្រូវផ្ទេរមូលបត្រដែលទទួលបាននេះ ទៅសមាជិកដែលត្រូវទទួលបានការទូទាត់មូលបត្រ។




ការទូទាត់គឺជាការបញ្ចប់ប្រតិបត្តិការ ដែលអ្នកលក់ផ្ទេរមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុទៅឲ្យអ្នកទិញ ហើយអ្នកទិញផ្ទេរសាច់ប្រាក់ទៅឲ្យអ្នកលក់។

- លក្ខណៈនៃការទូទាត់របស់ ផ.ម.ក.:

+ **វិធីសាស្ត្រនៃការទូទាត់៖ DVP**3 (ការប្រគល់មូលបត្រ ផ្ទុះនឹងសាច់ប្រាក់គំរូទី៣)

**DVP**3 ជាដំណើរការនៃការប្រគល់មូលបត្រ ដែលត្រូវបានធ្វើឡើងក្នុងពេលដំណាលគ្នានៃការប្រគល់សាច់ប្រាក់ ដោយផ្អែកលើមូលដ្ឋានបន្សុទ្ធ (បន្សុទ្ធមូលបត្រ និង បន្សុទ្ធសាច់ប្រាក់) ។ វាត្រូវបានកើតឡើងនៅចុងគ្រានៃវដ្តដំណើរការប្រតិបត្តិការ

+**ពេលវេលានៃការទូទាត់៖** ម៉ោង៨ និង៣០ នាទីព្រឹក (**T**+2) សមាជិកត្រូវផ្ទេរមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ទៅគណនីរបស់ **ផ.ម.ក.** នៅមុនម៉ោង ៨:៣០ ព្រឹក នៅកាលបរិច្ឆេទទូទាត់ ហើយ**ផ.ម.ក.** ត្រូវទូទាត់មូលបត្រ និងសាច់ប្រាក់បន្តទៅឲ្យសមាជិកដែលត្រូវទទួលការទូទាត់ បន្ទាប់ពីម៉ោង ៨:៣០ព្រឹក នៅថ្ងៃដដែលនៃកាលបរិច្ឆេទទូទាត់។

+**ភ្នាក់ងារទូទាត់សាច់ប្រាក់** (ធនាគារអេស៊ីលីដា ធនាគារកាណាឌីយ៉ា និង ធនាគារ **BIDC**) មានតួនាទីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

### ៤.២.៣.៨. យន្តការនៃការរក្សាទុកមូលបត្រ

ប្រតិបត្តិកររក្សាទុកមូលបត្រសំដៅដល់កន្លែងសម្រាប់ដាក់ផ្ញើមូលបត្រ។ ការដាក់ផ្ញើមូលបត្រគឺជាដំណើរការនៃការផ្ទេរកម្មសិទ្ធិករមូលបត្រ តាមរយៈការផ្ទេររវាងគណនី (Book Entry) (ការកត់ត្រាឥណទាន/ឥណពន្ធ ក្នុងសៀវភៅគណនីរបស់សមាជិក និងអ្នកចូលរួម) ដោយគ្មានចរន្តនៃការផ្ទេរមូលបត្ររូបវ័ន្ត។

នៅពេលមូលបត្រមានការជួញដូររវាងវិនិយោគិន ប្រតិបត្តិកររក្សាទុកមូលបត្រធ្វើការទូទាត់នូវប្រតិបត្តិការទាំងនោះតាមរយៈការផ្ទេររវាងគណនី (Book Entry)ដោយគ្មានការផ្ទេរមូលបត្ររូបវ័ន្ត។ ដូច្នេះហានិភ័យ

ចំពោះការបាត់និងការលួចមូលបត្រត្រូវបានជៀសវាងទាំងស្រុង។

សមាជិក អ្នកចូលរួម និងអតិថិជន ដែលបានដាក់ផ្ញើមូលបត្រនៅ ផ.ម.ក. មិនចាំបាច់ដកមូលបត្រទៅវិញ នៅពេលដែលត្រូវអនុវត្តសិទ្ធិកម្មសិទ្ធិករឡើយ។

- **ការបើកគណនី**

បុគ្គលដែលអាចបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្ររួមមាន ក្រុមហ៊ុនមូលបត្រ និង ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ។ បុគ្គលដែលមានបំណងបើកគណនីមូលបត្រត្រូវបំពេញបែបបទបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។ គ្រប់គណនីមូលបត្រទាំងអស់ រួមមានគណនីមូលបត្ររបស់សមាជិក ឬ អតិថិជនត្រូវបានបង្កើតឡើងក្នុង ប្រព័ន្ធ Ledger ( ledger system ) របស់ ផ.ម.ក. ដែលផ្ទុកផងដែរនូវទិន្នន័យលម្អិតនៃប្រតិបត្តិការរបស់សមាជិក និងអតិថិជន ព្រមទាំងទិន្នន័យលម្អិតនៃបញ្ជីភាគហ៊ុនិក។

- **ការដាក់ផ្ញើមូលបត្រ**

ដើម្បីដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ បុគ្គលដែលដាក់ផ្ញើត្រូវផ្តល់ព័ត៌មានដូចខាងក្រោមដល់ប្រតិបត្តិកររក្សាទុកមូលបត្រ :

- ប្រភេទមូលបត្រ
- ចំនួននៃការបោះផ្សាយ
- ឈ្មោះមូលបត្រ
- អក្សរកូដ
- ចំនួនមូលបត្រសរុប
- កាលបរិច្ឆេទបោះផ្សាយ
- កាលបរិច្ឆេទចុះបញ្ជី
- ព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងកម្មសិទ្ធិភាពមូលបត្រ

### ៤.២.៣.៩.ការលើកទឹកចិត្តផ្នែកពន្ធ

ដើម្បីលើកកម្ពស់ការអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ។[38] ខាងក្រោមនេះជាតារាងបង្ហាញអំពីការអនុគ្រោះលើប្រភេទពន្ធក្នុងវិស័យមូលបត្រ សម្រាប់វិនិយោគិនះ

① សម្រាប់អ្នកជាប់ពន្ធនិវាសនជន[39]

[38] http://csx.com.kh/operation/market/listPosts.do?MNCD=30201 ( ចូលទស្សនាថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០២០ )

[39] ច្បាប់ស្តីពីសារពើពន្ធ

| | អត្រាពន្ធ | អត្រាអនុគ្រោះ * | អត្រាដែលត្រូវបង់ |
|---|---|---|---|
| ពន្ធលើប្រាក់ចំណេញមូលធន | គ្មាន | គ្មាន | គ្មាន |
| ពន្ធប្រថាប់ត្រា | គ្មាន | គ្មាន | គ្មាន |
| ពន្ធកាត់ទុកលើភាគលាភ | គ្មាន | ៥០% | គ្មាន |
| ពន្ធកាត់ទុកលើការប្រាក់នៃមូលបត្របំណុល | ៦% | ៥០% | ៣% |

② សម្រាប់អ្នកជាប់ពន្ធអនិវាសនជន[40]

| | អត្រាពន្ធ | អត្រាអនុគ្រោះ * | អត្រាដែលត្រូវបង់ |
|---|---|---|---|
| ពន្ធលើប្រាក់ចំណេញមូលធន | គ្មាន | គ្មាន | គ្មាន |
| ពន្ធប្រថាប់ត្រា | គ្មាន | គ្មាន | គ្មាន |
| ពន្ធកាត់ទុកលើភាគលាភ | ១៤% | ៥០% | ៧% |
| ពន្ធកាត់ទុកលើការប្រាក់នៃមូលបត្របំណុល | ១៤% | ៥០% | ៧% |

* មានសុពលភាពដល់ថ្ងៃទី ៣ ខែមករា ឆ្នាំ២០២២

➢ មិនចាំបាច់មានប្រាក់តម្កល់អប្បបរិមា

- វិនិយោគិនមិនចាំបាច់មានប្រាក់តម្កល់ក្នុងគណនីជួញដូរទេ ពោលគឺត្រូវមានប្រាក់គ្រប់គ្រាន់ ត្រឹមចំនួនដែលត្រូវទិញនៅពេលដែលដាក់បញ្ជាតែប៉ុណ្ណោះ។

➢ មិនកំណត់បរិមាណបញ្ជាអប្បបរិមា

- វិនិយោគិនអាចដាក់បញ្ជាក្នុងបរិមាណតាមតម្រូវការរបស់ខ្លួន ដោយមិនមានកំណត់ចំនួនអប្បបរិមានោះទេ។

➢ មិនកំណត់លើកាន់កាប់ដោយរបស់ជនបរទេស

- វិនិយោគិនបរទេសអាចកាន់កាប់ភាគហ៊ុនដែលចុះបញ្ជីនៅ ផ.ម.ក. ដោយគ្មានបរិមាណកំណត់។

[40] អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

➢ អនុញ្ញាតឱ្យបង្វិលទុនត្រលប់ទៅប្រទេសដើម

- វិនិយោគិនបរទេសអាចធ្វើការបង្វិលដើមទុនដែលវិនិយោគិនក្នុង ផ.ម.ក.ត្រលប់ទៅប្រទេសដើមវិញ ដោយគ្មានការកំណត់។

## ៤.៣. ការវិនិយោគមូលបត្របំណុល

### ៤.៣.១. និយមន័យ

មូលបត្របំណុល (សញ្ញាបណ្ណ) គឺជាប្រភេទមូលបត្របំណុលដែលតំណាងឱ្យកិច្ចសន្យាខ្ចីប្រាក់រវាងបុគ្គលបោះផ្សាយមូលបត្របំណុល (រួមមានសាជីវកម្ម សហ-គ្រាសរដ្ឋ ឬរាជរដ្ឋាភិបាល) និងវិនិយោគិន (ម្ចាស់មូលបត្របំណុល) ។ តាមរយៈកិច្ចសន្យានេះ បុគ្គលបោះផ្សាយមូលបត្របំណុលមានកាតព្វកិច្ចបង់ឱ្យវិនិយោគិននូវទឹកប្រាក់ជាក់លាក់មួយជាទៀងទាត់ដែលហៅថា "គូប៉ុង" ឬ "ការប្រាក់" (លើកលែងសម្រាប់សញ្ញាបណ្ណគ្មានការប្រាក់) ព្រមទាំងបង់ប្រាក់ដើមនៅពេលដែលសញ្ញាបណ្ណនោះដល់កាលកំណត់សង ដែលហៅថា "តណប្រទិទាន"។ ជំនួសឱ្យការខ្ចីប្រាក់ពីធនាគារក្រុមហ៊ុនឬអង្គភាពមួយអាចបោះផ្សាយសញ្ញាបណ្ណទៅឲ្យវិនិយោគិនដោយផ្ទាល់ នៅពេលដែលក្រុមហ៊ុននោះត្រូវការសាច់ប្រាក់ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងថ្មីៗ, បន្តប្រតិបត្តិការក្រុមហ៊ុន ឬដើម្បីទូទាត់បំណុល។[41]

### ៤.៣.២.អំពីទីផ្សារសញ្ញាបណ្ណ

- ដើម្បីជួញដូរសញ្ញាបណ្ណនៅផ.ម.ក. វិនិយោគិនមិនតម្រូវឲ្យបើកគណនីមួយផ្សេងទៀត ក្រៅពីគណនីដែលប្រើសម្រាប់ជួញដូរភាគហ៊ុនឡើយ។[42]
- មានតែបញ្ជាដែនកំណត់ និងបញ្ជាតាមការចរចាប៉ុណ្ណោះ ដែលអនុញ្ញាតសម្រាប់ការជួញដូរសញ្ញាបណ្ណនៅផ.ម.ក.។ បញ្ជាទីផ្សារមិនត្រូវបានអនុញ្ញាតទេ។
- ពុំមានដែនកំណត់ថ្លៃប្រចាំថ្ងៃសម្រាប់ការជួញដូរសញ្ញាបណ្ណនៅផ.ម.ក.ទេ។
- ថ្លៃបញ្ជានិងថ្លៃជួញដូរនៃសញ្ញាបណ្ណ គឺជាថ្លៃដុលដែលគិតបញ្ចូលនូវការប្រាក់បង្គរ។
- ការជួញដូរភាគហ៊ុននិងសញ្ញាបណ្ណតាមវិធីសាស្រ្តជួញដូរតាមការចរចារ មានលក្ខណៈដូចគ្នាស្ទើរទាំងស្រុងដូចជា៖ ម៉ោងជួញដូរ ឯកតា(គម្លាត)ថ្លៃ គ្មានបញ្ជាអតិបរមា គ្មានដែនកំណត់ថ្លៃ គ្មានការកែប្រែបញ្ជានិងកំហុសប្រតិបត្តិការជួញដូរ លើកលែងតែបញ្ជាអប្បបរមា ដែលសម្រាប់សញ្ញាបណ្ណគឺ ១ឯកតាសញ្ញាបណ្ណ ហើយសម្រាប់ភាគហ៊ុនគឺ ៥០.០០០ភាគហ៊ុន ឬ២០០លានរៀល (យកមួយណាដែលតូចជាង)។
- គោលការណ៍នៃការផ្គូផ្គងសញ្ញាបណ្ណនិងភាគហ៊ុន ត្រូវបានអនុវត្តដូចគ្នាតាមវិធីសាស្រ្តដេញថ្លៃដូចមានចែងនៅក្នុងវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា លើកលែងតែករណីមានថ្លៃផ្គូផ្គងចាប់ពីពីរឡើងទៅនៅក្នុងការដេញថ្លៃដោយយកថ្លៃតែមួយនៃសញ្ញាបណ្ណ នោះថ្លៃជួញដូរគឺជាមធ្យមនព្វន្តនៃថ្លៃផ្គូផ្គង

[41] http://csx.com.kh/kh/product/bond.jsp?MNCD=4040 (ចូលទស្សនាថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០)

[42] គេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ៖ សំនួរ- ចម្លើយ

ខ្ពស់បំផុតនិងថ្លៃផ្គូផ្គងទាបបំផុត។ ក្នុងករណីថ្លៃទទួលបានពីការគណនានេះមិនចំនឹងឯកតាគម្លាតថ្លៃ នោះថ្លៃជួញដូរត្រូវបង្គត់ឡើងតាមឯកតាគម្លាតថ្លៃ។

- ជាមួយគ្នានេះផងដែរ បរិមាណបញ្ជាអប្បបរមារបស់សញ្ញាបណ្ណនិងភាគហ៊ុនមានចំនួនដូចគ្នា គឺមួយឯកតាសញ្ញាបណ្ណ និងមួយភាគហ៊ុន។ ប៉ុន្តែបរិមាណបញ្ជាអតិបរមារបស់សញ្ញាបណ្ណគឺ ១០.០០០ (មួយម៉ឺន) ឯកតាសញ្ញាបណ្ណ ខណៈដែលបរិមាណបញ្ជាអតិបរិមារបស់ភាគហ៊ុនមិនត្រូវបានកំណត់នោះទេ។

## ៤.៣.៣. វិធីសាស្ត្រជួញដូរ

- **វិធីសាស្ត្រជួញដូរតាមការដេញថ្លៃ៖** ការជួញដូរមូលបត្របំណុលតាមការដេញថ្លៃ ត្រូវអនុវត្តតាមវិធីសាស្ត្រដេញថ្លៃសម្រាប់ភាគហ៊ុន លើកលែងតែករណីមានថ្លៃផ្គូផ្គងចាប់ពីពីរឡើងទៅនៅក្នុងការដេញថ្លៃដោយយកថ្លៃតែមួយ ដែលថ្លៃជួញដូរគឺជាមធ្យមនព្វន្តនៃថ្លៃផ្គូផ្គងខ្ពស់បំផុត និងថ្លៃផ្គូផ្គងទាបបំផុត។

ឧទាហរណ៍៖ ករណីមានថ្លៃផ្គូផ្គងចាប់ពីពីរឡើងនៅក្នុងការដេញថ្លៃដោយយកថ្លៃតែមួយ សម្រាប់ការជួញដូរមូលបត្របំណុល។

| បរិមាណលក់ | ថ្លៃ | បរិមាណទិញ |
|---|---|---|
| | ៩០.៤០០ | ២.០០០ |
| | **៩០.២០០ (ថ្លៃជួញដូរ)** | |
| | ៩០.០៥០ (ថ្លៃដែលបានជួញដូរកាលពី១ខែមុន) | |
| ២.០០០ | ៩០.០០០ | |

ក្នុងឧទាហរណ៍នេះ ថ្លៃដែលអាចផ្គូផ្គងបានមានច្រើន គឺពី ៩០.០០០ ដល់ ៩០.៤០០ ប៉ុន្តែថ្លៃជួញដូរគឺ (៩០.៤០០ + ៩០.០០០)/២ = ៩០.២០០ រៀល។

ក្នុងករណីថ្លៃទទួលបានពីការគណនានេះមិនចំនឹងឯកតាគម្លាតថ្លៃ នោះថ្លៃជួញដូរត្រូវបង្គត់ឡើងតាមឯកតាគម្លាតថ្លៃ។

- **វិធីសាស្ត្រជួញដូរតាមការចរចា៖** ការជួញដូរមូលបត្របំណុលតាមការចរចា ត្រូវអនុវត្តតាមវិធីសាស្ត្រជួញដូរតាមការចរចាសម្រាប់ភាគហ៊ុន ។

### ៤.៣.៤. វិធានផ្សេងៗទៀតទាក់ទងនឹងការជួញដូរមូលបត្របំណុល

- ឯកតាគម្លាតថ្លៃ៖ ឯកតាគម្លាតថ្លៃគឺ ១ (មួយ) រៀល សម្រាប់ការជួញដូរមូលបត្របំណុលដែលមានតម្លៃចារិក ១០០.០០០ រៀល។
- ប្រភេទនៃបញ្ជា៖ ប្រភេទនៃបញ្ជាសម្រាប់មូលបត្របំណុលគឺ បញ្ជាដែនកំណត់ និងបញ្ជាតាមការចរចា។ បញ្ជាទីផ្សារមិនត្រូវបានអនុញ្ញាតឡើយ។ឯកតាបញ្ជា៖ ឯកតាបញ្ជានៃមូលបត្របំណុលគឺ ១ (មួយ) ឯកតាមូលបត្របំណុល។
- បញ្ជាអតិបរមា៖ បញ្ជាអតិបរមាសម្រាប់ការជួញដូរតាមវិធីសាស្ត្រដេញថ្លៃគឺ ១០.០០០ (មួយម៉ឺន) ឯកតាមូល បត្របំណុល។ មិនមានបរិមាណបញ្ជាអតិបរមាសម្រាប់ការជួញដូរតាមការចរចាឡើយ។
- ដែនកំណត់ថ្លៃប្រចាំថ្ងៃ៖ មិនអនុវត្តចំពោះការជួញដូរមូលបត្របំណុលឡើយ។
- ថ្លៃពិសេស៖ មិនមានថ្លៃពិសេសនៅក្នុងការជួញដូរមូលបត្របំណុលឡើយ។
- ថ្លៃបញ្ជា៖ ថ្លៃបញ្ជា និងថ្លៃជួញដូរមូលបត្របំណុល គឺជាថ្លៃដុល ដែលគិតបញ្ចូលនូវការប្រាក់បង្គរ។

### ៤.៣.៥. ភាពខុសគ្នារវាងការវិនិយោគលើភាគហ៊ុន និងសញ្ញាបណ្ណ

| សញ្ញាបណ្ណ | ភាគហ៊ុន |
|---|---|
| • ក្លាយជាម្ចាស់បំណុល | • ក្លាយជាម្ចាស់កម្មសិទ្ធិ |
| • សិទ្ធិទាមទារទ្រព្យសម្បត្តិខ្ពស់ជាង | • សិទ្ធិទាមទារទ្រព្យសម្បត្តិទាបជាង |
| • ការវិនិយោគមានរយៈពេលកំណត់ (maturity) | • ការវិនិយោគគ្មានកាលកំណត់ លើកលែងក្រុមហ៊ុនត្រូវបិទទ្វារជម្រះបញ្ជី |
| • ចំណូលការប្រាក់ថេរនិងទៀងទាត់ បង់ដោយអ្នកបោះផ្សាយ | • ការទូទាត់ភាគលាភផ្អែកលើគោលនយោបាយនិងទិន្នផលអាជីវកម្មរបស់ក្រុមហ៊ុន |
| • ថ្លៃមានបម្រែបម្រួលតិចតួច | • ថ្លៃមានបម្រែបម្រួលខ្ពស់ជាង |
| • មិនសូវមានសន្ទនីយភាព | • មានសន្ទនីយភាពខ្ពស់ជាង |
| • ឯកតាបញ្ជាអប្បបរមាគឺ ១ឯកតានៃសញ្ញាបណ្ណ (មានតម្លៃចារឹកស្មង់ជា១០០.០០០រៀល) | • ឯកតាបញ្ជាអប្បបរមាគឺ ១ភាគហ៊ុន |

## ៤.៤. សកម្មភាពជួញដូរសញ្ញាបណ្ណរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រចំណុល

### ៤.៤.១.គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត (HKL)

នៅថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១៨ ផ.ម.ក បានទទួលនូវការចុះបញ្ជីដាក់អោយជួញដូរនូវសញ្ញាប័ណ្ណដំបូងបំផុត ដោយគ្រឹះស្ថានក្រូហិរញ្ញវត្ថុហត្ថាកសិករលីមីតធីត(HKL) ដែលមានឈ្មោះថា "សញ្ញាប័ណ្ណសាជីវកម្មដំបូងបំផុតនៅកម្ពុជាលេខ១"(HKL21A)។ ការបោះផ្សាយសញ្ញាប័ណ្ណ (HKL21A) ត្រូវបានធ្វើឡើងក្នុងបរិមាណ ១,២លានសញ្ញាប័ណ្ណ ដែលគិតជាទឹកប្រាក់សរុបចំនួន ១២០ពាន់លានរៀល។ វិនិយោគិននឹងទទួលបាននូវគូប៉ុង (ការប្រាក់) ដែលបង់ប្រចាំឆមាសក្នុងអត្រា ៨,៥០% ក្នុងមួយឆ្នាំ។ ក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ នេះ សញ្ញាប័ណ្ណសាជីវកម្ម (Corporate Bond) របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត (HKL) ពុំមានការជួញដូរទេ។[43]

### ៤.៤.២. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូ ស៊ិ (LOLC)

នៅថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១៩ ផ.ម.ក បានសម្រេចចុះបញ្ជីសាជីវកម្ម របស់គ្រឹះស្ថានមីគ្រូហិរញ្ញវត្ថុ អិល អូ ស៊ិ។ សញ្ញាប័ណ្ណសាជីវកម្មដែលបានចុះបញ្ជីលក់នោះ មានឈ្មោះថា "សញ្ញាប័ណ្ណសាជីវកម្ម អិល អូ ស៊ិ មានការការពារហានិភ័យអត្រាដប្តូរប្រាក់" -Fx-indexed Bond 2019-2022 No.1" ដែលមានអត្រាគូប៉ុង ៨% ក្នុមួយឆ្នាំ និង "សញ្ញាប័ណ្ណសាជីវកម្ម អិល អូ ស៊ិ មិនមានការការពារហានិភ័យអត្រាដប្តូរប្រាក់" ដែលមានអត្រាគូប៉ុង៩% ក្នុងមួយឆ្នាំ។ សញ្ញាប័ណ្ណសាជីវកម្មនេះ មានឥណប្រតិទានរយះពេល ៣ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២។ ក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ នេះ សញ្ញាប័ណ្ណសាជីវកម្ម (Corporate Bond) របស់គ្រឹះស្ថានមីគ្រូហិរញ្ញវត្ថុ អិល អូ ស៊ិ (LOLC) ពុំមានការជួញដូរទេ។

### ៤.៤.៣. ធនាគារវឌ្ឍនះ អាស៊ីចំកាត់ (ABA)

ធនាគារវឌ្ឍនះ អាស៊ីចំកាត់ (ABA) ជាធនាគារពាណិជ្ជដំបូងគេបង្អស់ដែលបានបោះផ្សាយសញ្ញាប័ណសម្រាប់វិនិយោគិន និងរូបវន្តបុគ្គល ដែលមានអត្រាគូប៉ុងចំនួន ៧,៧៥% ក្នុងមួយឆ្នាំ គឺជាអត្រាដែលខ្ពស់ជាងអត្រាដាក់ប្រាក់បញ្ញើមានកាលកំណត់របស់ធនាគារពាណិជ្ជ។ គួរឲ្យបញ្ជាក់ផងដែរ សញ្ញាប័ណ្ណនេះទទួលបានចំណាត់ថ្នាក់លទ្ធភាពសង "B" ដែលត្រូវបានចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង S&P Global Rating។ នៅថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១៩ សញ្ញាប័ណ្ណសាជីវកម្មរបស់ធនាគារវឌ្ឍនះ អាស៊ីចំកាត់ (ABA) ត្រូវបានសម្រេចអោយចុះបញ្ជីជាផ្លូវការនៅផ.ម.ក។ សញ្ញាប័ណ្ណសាជីវកម្មដែលបានចុះបញ្ជីលក់នោះ មានឈ្មោះថា "សញ្ញាប័ណ្ណសាជីវកម្ម អេ ប៊ី អេ" ដែលមានអត្រាគូប៉ុងចំនួន ៧,៧៥% ក្នុងមួយឆ្នាំ ព្រមជាមួយ

[43] សៀវភៅព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រ ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៩

ឥណទានប្រតិទានរយៈពេល ៣ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២២។

ក្នុងត្រីមាសទី៤ ឆ្នាំ២០១៩នេះ សញ្ញាប័ណ្ណសាជីវកម្ម(Corporate Bond) របស់ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ (ABA) មានសកម្មភាពជួញដូរយ៉ាងសកម្មជាមួយនឹងអត្រាទិន្នផលជាមធ្យមចំនួន៧,៧៨% នៅថ្លៃជាមធ្យមចំនួន ១០០.០៣៣រៀល រួមមាន ការដាក់បញ្ជាទិញចំនួន២៦៥ កតា ការដាក់បញ្ជាលក់ចំនួន ៩៣១ ឯកតា ពីសំណាក់វិនិយោគិនរូបវន្តបុគ្គល។ សរុបសេចក្ដីមក សញ្ញាប័ណ្ណត្រូវបានជួញដូរចំនួន ១៨០ កតា នៅថ្លៃជាមធ្យមចំនួន ១០០.០៣៣ រៀល ជាមួយនឹងអត្រាទិន្នផលជាមធ្យមចំនួន ៨,៨៦%។

## ៤.៥. ជួញដូរភាគហ៊ុនរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ឆមាសទី៤ ២០១៩[44]

### ៤.៥.១.ភាគហ៊ុនរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PWSA)

តារាងទី ១ ៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PWSA

| ទិដ្ឋភាពទូទៅ (GTI) | ត្រីមាសទី៣ | ត្រីមាសទី៤ | បម្រែបម្រួល |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ(លានរៀល) | 535,755 | 521,839 | -3% |
| មូលធនូបនីយកម្មទីផ្សារ(លានដុល្លារអាមេរិក) | 133,94 | 130.46 | |
| ទំហំជួញដូរ (ភាគហ៊ុន) | 224,156 | 251,530 | 12% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 3,558 | 4,263 | |
| តម្លៃជួញដូរ (រៀល) | 1,352,977,840 | 1,509,898,280 | 12% |
| តម្លៃជួញដូរ (ដុល្លារអាមេរិក) | 338,244 | 377,475 | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (រៀល) | 21,475,839 | 25,591,496 | 19% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក) | 5,369 | 6,398 | |

ក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ ថ្លៃបិទភាគហ៊ុន PWAS ប្រែប្រួលក្នុងចន្លោះពី ៥.៨៨០រៀល ដល់៦.២៨០រៀល។ ចំពោះការជួញដូរមានការកើនឡើង បើធៀបជាមួយត្រីមាសទី៣ ឆ្នាំ២០១៩ ដោយទំហំជួញដូរកើនឡើងពី ២២៤.១៥៦ ភាគហ៊ុន នៅក្នុងត្រីមាសទី៣ ២០១៩ ដល់ ២៥១.៥៣០ ភាគហ៊ុន នៅក្នុងត្រីមាសទី៤ ឆ្នាំ២០១៩។ តម្លៃជួញដូរសរុបរបស់សម្រាប់ភាគហ៊ុន PWAS នៅក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ មានតម្លៃប្រហែល ១.៥០៩,៩ លានរៀល (ប្រហែល ៣៧៧ ពាន់ដុល្លារសហរដ្ឋអាមេរិក។

[44] សៀវភៅព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រ ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៩

### ៤.៥.២.-ភាគហ៊ុនរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភី អិល ស៊ី (GTI)

តារាងទី ២ ៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន GTI

| ទិដ្ឋភាពទូទៅ (GTI) | ត្រីមាសទី៣ | ត្រីមាសទី៤ | បម្រែបម្រួល |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ(លានរៀល) | 176,000 | 176,00 | 0% |
| មូលធនូបនីយកម្មទីផ្សារ(លានដុល្លារអាមេរិក) | 44.00 | 44.00 | |
| ទំហំជួញដូរ (ភាគហ៊ុន) | 47,951 | 45,174 | -6% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 761 | 766 | |
| តម្លៃជួញដូរ (រៀល) | 209,815,420 | 198,775,760 | -5% |
| តម្លៃជួញដូរ (ដុល្លារអាមេរិក) | 52,454 | 49,694 | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (រៀល) | 3,330,403 | 3,369,081 | 1% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក) | 833 | 842 | |

ក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ ថ្លៃបិទភាគហ៊ុន GTI ប្រែប្រួលក្នុងចន្លោះពី 4.300រៀលដល់ ៤.៨០០រៀល។ ចំពោះការជួញដូរមានការថយចុះបន្តិច បើធៀបជាមួយត្រីមាសទី៣ ឆ្នាំ២០១៩ ដោយទំហំជួញដូរថយចុះពី ៤៧.៩៥១ ភាគហ៊ុន នៅក្នុងត្រីមាសទី៣ ២០១៩ មកត្រឹម ៤៥.១៧៤ ភាគហ៊ុន នៅក្នុងត្រីមាសទី ៤ ឆ្នាំ២០១៩ នោះមានន័យថាទំហំជួញដូរថយចុះប្រមាណ ៦%។ តម្លៃជួញដូរសរុបរបស់សម្រាប់ភាគហ៊ុន GTI នៅក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ មានតម្លៃប្រហែល ១៨៨,៧ លានរៀល (ប្រហែល ៤៩,៦ ពាន់ដុល្លារសហរដ្ឋអាមេរិក។

### ៤.៥.៣.-ភាគហ៊ុនរបស់កំពង់ផែស្វយ័តភ្នំពេញ (PPAP)

តារាងទី ៣ ៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PPAP

| ទិដ្ឋភាពទូទៅ (PPAP) | ត្រីមាសទី៣ | ត្រីមាសទី៤ | បម្រែបម្រួល |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ(លានរៀល) | 264,346 | 258,555 | -2% |
| មូលធនូបនីយកម្មទីផ្សារ(លានដុល្លារអាមេរិក) | 66.09 | 64.04 | |
| ទំហំជួញដូរ (ភាគហ៊ុន) | 102,125 | 65,123 | -36% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 1,621 | 1,104 | |
| តម្លៃជួញដូរ (រៀល) | 1,048,022,380 | 809,063,180 | -23% |

| | | | |
|---|---|---|---|
| តម្លៃជួញដូរ (ដុល្លារអាមេរិក) | 262,006 | 202,266 | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (រៀល) | 16,635,276 | 13,712,935 | -18% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក) | 4,159 | 3,428 | |

ក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ ថ្លៃបិទភាគហ៊ុន PPAP ប្រែប្រួលក្នុងចន្លោះពី ១១.៥០០រៀល ដល់ ១១.៥០០រៀល។ ចំពោះសកម្មភាពជួញដូរមានការថយចុះបន្តិច បើធៀបជាមួយត្រីមាសទី៣ ឆ្នាំ២០១៩ ដោយទំហំជួញដូរថយចុះពី ១០២.១២៥ ភាគហ៊ុន នៅក្នុងត្រីមាសទី៣ ២០១៩ មកត្រឹម ៦៥.១២៣ ភាគហ៊ុន នៅក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ នោះមានន័យថាទំហំជួញដូរថយចុះប្រមាណ ៣៦%។ តម្លៃជួញដូរសរុបរបស់សម្រាប់ភាគហ៊ុន PPAP នៅក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ មានតម្លៃប្រហែល ៨០៩ លានរៀល (ប្រហែល ២០២ ពាន់ដុល្លារសហរដ្ឋអាមេរិក។

**៤.៥.៤.-ភាគហ៊ុនរបស់ភ្នំពេញអេសអ៊ីហ្សិត គីអិលស៊ី** (PPSP)

តារាងទី ៤ ៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PPSP

| **ទិដ្ឋភាពទូទៅ (PPSP)** | **ត្រីមាសទី៣** | **ត្រីមាសទី៤** | **បម្រែបម្រួល** |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ(លានរៀល) | 196,938 | 185,438 | -5.84% |
| មូលធនូបនីយកម្មទីផ្សារ(លានដុល្លារអាមេរិក) | 49.23 | 46.36 | |
| ទំហំជួញដូរ (ភាគហ៊ុន) | 100,672 | 178,750 | 77.56% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 1,598 | 3,030 | |
| តម្លៃជួញដូរ (រៀល) | 276,578,140 | 479,830,520 | 73.49% |
| តម្លៃជួញដូរ (ដុល្លារអាមេរិក) | 69,145 | 119,958 | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (រៀល) | 4,390,129 | 8,132,721 | 85.25% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក) | 1,098 | 2,033 | |

ក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ ថ្លៃបិទភាគហ៊ុន PPSP ប្រែប្រួលក្នុងចន្លោះពី ២.៥០០រៀល ដល់២.៨២០រៀល។ ចំណែសកម្មភាពជួញដូរមានការកើនឡើង បើធៀបជាមួយត្រីមាសទី៣ ឆ្នាំ២០១៩ ដោយទំហំជួញដូរកើនឡើងពី ១០០.៦៧២ ភាគហ៊ុន នៅក្នុងត្រីមាសទី៣ ២០១៩ ដល់ ១៧៨.៧៥០ ភាគហ៊ុន នៅក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ នោះមានន័យថាទំហំជួញដូរកើនឡើងប្រមាណ ៧៧,៥៦%។ តម្លៃជួញដូរសរុបរបស់សម្រាប់ភាគហ៊ុន PWAS មានតម្លៃប្រហែល ៤៧៩,៨ លានរៀល (ប្រហែល ១១៩,៩ ពាន់ដុល្លារសហរដ្ឋអាមេរិក)។

### ៤.៥.៥.-ភាគហ៊ុនរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS)

តារាងទី ៥ ៖ ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PAS

| **ទិដ្ឋភាពទូទៅ (PAS)** | **ត្រីមាសទី៣** | **ត្រីមាសទី៤** | **បម្រែបម្រួល** |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ(លានរៀល) | 2,028,507 | 1,663,976 | -18% |
| មូលធនូបនីយកម្មទីផ្សារ(លានដុល្លារអាមេរិក) | 507 | 416 | |
| ទំហំជួញដូរ (ភាគហ៊ុន) | 315,039 | 138,029 | -56% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 5,001 | 2,339 | |
| តម្លៃជួញដូរ (រៀល) | 3,947,021,550 | 2,809,185,180 | -29% |
| តម្លៃជួញដូរ (ដុល្លារអាមេរិក) | 986,755 | 702,296 | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (រៀល) | 62,651,136 | 47,613,308 | -24% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក) | 15,663 | 11,903 | |

ក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ ថ្លៃបិទភាគហ៊ុន PAS ប្រែប្រួលក្នុងចន្លោះពី ១៩.៤០០រៀល ដល់២៣.៥០០រៀល។ ចំពោះសកម្មភាពជួញដូរមានការថយចុះ បើធៀបជាមួយត្រីមាសទី៣ ឆ្នាំ ២០១៩ ដោយទំហំជួញដូរថយចុះពី ៣១៥.០៣៩ ភាគហ៊ុន នៅក្នុងត្រីមាសទី៣ ២០១៩ មកត្រឹម ១៣៨.០២៩ ភាគហ៊ុន នៅក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ នោះមានន័យថាទំហំជួញដូរថយចុះប្រមាណ ៥៦%។ តម្លៃជួញដូរសរុបរបស់សម្រាប់ភាគហ៊ុន PAS នៅក្នុងត្រីមាសទី៤ ឆ្នាំ ២០១៩ មានតម្លៃប្រហែល ២.៨០៩ លានរៀល (ប្រហែល ១១.៨០០ ពាន់ដុល្លារសហរដ្ឋអាមេរិក)។ ទន្ទឹមនឹងនេះផងដែរ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ មានការជួញដូរតាមរយៈការចរចារចំនួន ១១.៨០០ ភាគហ៊ុន។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីធ្វើការស្រាវជ្រាវអំពីប្រធានបទ តាមរយៈការដកស្រង់ព័ត៌មានដែលបានមកពីប្រព័ន្ធអ៊ីនធើណេត បណ្ណាល័យ គេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា គេហទំព័ររបស់ផ្សារមូលបត្រកម្ពុជា ឯកសារយោងពីសាស្ត្រាចារ្យកន្លងមក និងការចុះកម្មសិក្សានៅគណៈកម្មការមូលបត្រកម្ពុជា(SECC)អស់រយៈពេលមួយខែរួចមក យើងខ្ញុំសង្កេតឃើញថាវិស័យមូលបត្រពិតជាដើរតួរយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍វិស័យផ្សេងៗ និង ធ្វើឲ្យសេដ្ឋកិច្ចជាតិមានការរីកចម្រើន ជាពិសេសគឺវិស័យហិរញ្ញវត្ថុ។ ក្នុងពេលបច្ចុប្បន្ននេះ យើងសង្កេតឃើញថាវិស័យមូលបត្រមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ដោយមានការកើនឡើងនូវក្រុមហ៊ុនដែលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ មានដូចជារដ្ឋាករទឹកស្វយ័ត(PWSA)ក្រុមហ៊ុន ហ្រ្គេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (GTI) កំពង់ផែស្វយ័តភ្នំពេញ (PPAP) ភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី (PPSP) និងកំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS)។ ចំណែកឯក្រុមហ៊ុនដែលចុះបញ្ជីលក់មូលបត្របំណុលមានដូចជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត (HKL) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូ ស៊ិ (LOLC) ធនាគារវឌ្ឍនៈ អាស៊ីចំកាត់ (ABA)។ ទន្ទឹមនឹងនេះផងដែរក៏មានការជួញដូរមូលបត្របំណុល ក្នុងត្រីមាសទី៤ ឆ្នាំ២០១៩នេះ សញ្ញាប័ណ្ណសាជីវកម្ម(Corporate Bond) របស់ធនាគារវឌ្ឍនៈ អាស៊ីចំកាត់ (ABA) មានសកម្មភាពជួញដូរយ៉ាងសកម្មជាមួយនឹងអត្រាទិន្នផលជាមធ្យមចំនួន ៧,៧៨% នៅថ្លៃជាមធ្យមចំនួន ១០០.០៣៣រៀល រួមមាន ការដាក់បញ្ជាទិញចំនួន២៦៥ ឯកតា ការដាក់បញ្ជាលក់ចំនួន ៩៣១ ឯកតា ពីសំណាក់វិនិយោគិនរូបវន្តបុគ្គល។ សរុបសេចក្តីមក សញ្ញាប័ណ្ណត្រូវបានជួញដូរចំនួន ១៨០ ឯកតា នៅថ្លៃជាមធ្យមចំនួន ១០០.០៣៣ រៀល ជាមួយនឹងអត្រាទិន្នផលជាមធ្យមចំនួន ៨,៨៦%។

យ៉ាងណាមិញ យើងយល់ឃើញថាក្នុងពេលបច្ចុប្បន្នទីផ្សារមូលបត្រមានបញ្ហាចោទជាច្រើន ដែលមានដូចជា កង្វះនូវចំណេះដឹងផ្នែកវិស័យមូលបត្រ ការធ្លាក់ចុះនៃថ្លៃភាគហ៊ុន ចំនួនក្រុមហ៊ុនមូលបត្រនៅលើទីផ្សារ និងទំនុកចិត្តត្រូវបានលើកឡើងមកពិភាក្សាដើម្បីរកដំណោះស្រាយ។

គណៈកម្មការមូលបត្រកម្ពុជានិងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានដាក់ឱ្យអនុវត្តនូវច្បាប់និងបទបញ្ញត្តិផ្សេងៗដែលទាក់ទងនឹងវិស័យមូលបត្រនេះ ក្នុងគោលបំណងធានាដល់ដំណើរការប្រព្រឹត្តប្រកបដោយភាពត្រឹមត្រូវរបស់ទីផ្សារទាំងមូល ដើម្បីចូលរួមផ្តល់ជាដំណោះស្រាយចំពោះបញ្ហាប្រឈមទាំងនេះ។ ទន្ទឹមនឹងនេះផងដែរ យើងសង្កេតឃើញថាមានការដាក់បង្ហាញនូវព័ត៌មាន ដែលទាក់ទងនឹងមូលបត្រ អ្នកចូលរួមក្នុងទីផ្សារ និងទិន្នន័យទីផ្សារតាមរយៈគេហទំព័រយ៉ាងក្បោះក្បាយ ដើម្បីឲ្យសាធារណៈជនទទួលបានចំណេះដឹង និងព័ត៌មានបន្ថែម។ ចំពោះការផាត់ទាត់ និងទូទាត់ ព្រមទាំងរក្សាទុកមូលបត្រ ក៏ត្រូវបានធ្វើឡើងដោយ

ប្រព័ន្ធបច្ចេកវិទ្យាត្រឹមត្រូវដែរ។ បន្ថែមពីនេះ ក៏មានការរៀបចំឡើងនូវសិក្ខាសាលាអប់រំ និងវគ្គបំប៉នខ្លីដើម្បីបណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្តល់នូវចំណេះដឹង ដែលទាក់ទងនឹងមូលបត្រ។

សរុបសេចក្តីមក ទីផ្សារមូលបត្រកម្ពុជាអាចចាត់ទុកបានជាកត្តាមួយដ៏សំខាន់ក្នុងការជម្រុញនូវការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុដូចជា មូលបត្រកម្មសិទ្ធ មូលបត្របំណុលឱ្យបានទូលំទូលាយជាងមុន និងរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

# អនុសាសន៍

# អនុសាសន៍

ទោះបីជាវិស័យមូលបត្រនៅប្រទេសកម្ពុជាមានការីកចម្រើនក៏ដោយ ប្រជាជនកម្ពុជាយើងមិនសូវមានចំណេះដឹងទូលំទូលាយអំពីដំណើរការនៃការជួញដូរមូលបត្រនៅឡើយទេ។ ដើម្បីជាជំនួយដល់ប្រសិទ្ធិភាពនៃទីផ្សារមូលបត្រ គឺចាំបាច់ត្រូវមានការចូលរួមនិងសហការពីសំណាក់ស្ថាប័នឯកជន ស្ថាប័នសាធារណៈ និងស្ថាប័នពាក់ព័ន្ធទាំងអស់ក្នុងការផ្សព្វផ្សាយពីទូលំទូលាយជាងនេះ។ ដូច្នេះយើងខ្ញុំសូមចូលរួមចំណែកផ្តល់ជាអនុសាសន៏មួយចំនួនដូចខាងក្រោម៖

- ដើម្បីជំរុញនូវការកើនឡើងនូវចំនួនក្រុមហ៊ុនចុះបញ្ជី និងការវិនិយោគនៅលើទីផ្សារកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គួរតែបង្កើនការលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនចុះបញ្ជីដំបូង និងវិនិយោគិនដែលបានជួញដូរច្រើន។
- ដោយសារតែក្រុមហ៊ុន ដែលមានបំណងបោះផ្សាយមូលបត្រមួយចំនួនមានការយល់ឃើញថានីតិវិធីក្នុងការចុះបញ្ជីជាក្រុមហ៊ុនបោះផ្សាយមូលបត្រមានភាពស្មុគស្មាញច្រើន និងចំណាយពេលវេលាច្រើន ពួកគាត់មួយចំនួនបានបោះបង់នូវបំណងដែលចង់បោះផ្សាយមូលបត្រនេះចោល។ ដូច្នេះហើយរាជរដ្ឋាភិបាលកម្ពុជាគួរតែធ្វើការផ្សព្វផ្សាយច្បាប់នៃការវិនិយោគដល់វិនិយោគិនអោយបានច្បាស់លាស់។
- បច្ចុប្បន្ននេះម៉ោងជួញដូរមានចាប់ពីម៉ោង៨ព្រឹក ដល់ម៉ោង៣រសៀលចាប់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រតែប៉ុណ្ណោះ។ ដូច្នេះហើយ ក្រុមហ៊ុនផ្សារមូលបត្រគួរតែបន្ថែមម៉ោងជួញដូរអោយកាន់តែច្រើន ដើម្បីផ្តល់ភាពងាយស្រួលដល់វិនិយោគិនក្នុងការជ្រើសរើសម៉ោងជួញដូរ។
- គណៈកម្មការមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាគួរតែផ្តល់ជាចំណេះដឹងដល់សាធារណៈបង្កើនចំនួនសិក្ខាសិលាជាសាធារណៈ និងការតាំងពិព័រណ៍ព័ត៏មានស្តីពីមូលបត្រ ដោយមានការចូលរួមពីអ្នកជំនាញពាក់ព័ន្ធនឹងការជួញដូរមូលបត្រលើផ្សារមូលបត្រកម្ពុជា។
- គណៈកម្មការមូលបត្រកម្ពុជា គួររៀបរៀងសៀវភៅណែនាំខ្លីៗស្តីពីយន្តការ ឬ ដំណើរការនៃការជួញដូរមូលបត្រ ដោយធ្វើការសម្រាយពីច្បាប់បញ្ញត្តិ អនុក្រឹត្យ និងគោលការណ៏ណែនាំផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ ដើម្បីចែកដល់វិនិយោគិនក្រុមហ៊ុនមូលបត្រស្រួលដល់វិនិយោគិន និង បងប្អូនប្រជាពលរដ្ឋក្នុងការស្វែងយល់ពីមូលបត្រ។
- ក្រុមហ៊ុនមូលបត្រកម្ពុជាគួរតែសិក្សាស្វែងយល់បន្ថែមពីយុទ្ធសាស្ត្រ និងនីតិវិធីក្នុងការជួញប្តូរពីប្រទេសអភិវឌ្ឍដែលមានភាពជោគជ័យលើវិស័យនេះ។

# ឯកសារយោង

## ឯកសារយោង

- **ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ**

- ប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ, លេខ០០៩/១៧គ.ម.ក/ប្រក
- ប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥គ.ម.ក/ប្រក ១០ កញ្ញា ២០១៥
- ប្រកាសស្តីពី ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ, លេខ០១៨/១៧គ.ម.ក/ប្រក ២៤ កញ្ញា ២០១៣
- ប្រកាសស្តីពី ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ, លេខ០១៩/១៧គ.ម.ក/ប្រក ២៤ កញ្ញា ២០១៣
- ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, លេខ នស/រកម/១០០៧/០២៨,១៩ តុលា ២០០៧, មាត្រាទី ៣៨។
- ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ, លេខ ០០៥/១១ គ.ម.ក./ប្រ.ក., ២៧ មិថុនា ២០១១, ប្រការ៧។
- ប្រកាសស្តីពីការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា លេខ ០០១/១៤គ.ម.ក./ប្រ.ក.,២២ មករា ២០១៤, ប្រការ១៤ថ្មី។
- ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ,លេខ ០០២/១១គ.ម.ក./ប្រ.ក., ០៣ ឧសភា ២០១១, ប្រការ៥
- ច្បាប់ស្តីពីសារពើពន្ធ
- អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

- **គោលការណ៍ណែនាំ**

- គោលការណ៍ណែនាំស្តីពី ការធ្វើប៊ុកបៀលឌីង និងការធ្វើបរិសកម្មមូលបត្រកម្មសិទ្ធិ, លេខ០០២/១២ គ.ម.ក/គណន ០៩ កុម្ភះ ២០១២
- គោលការណ៍ណែនាំស្តីពីយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង លេខ០០១/គ.ម.ក/គ.ណ.ន ០៨ កញ្ញា ២០១១
- គោលការណ៍ណែនាំស្តីពី ការផ្តល់លេខអត្តសញ្ញាណវិនិយោគិន លេខ០០១/គ.ម.ក/គ.ណ.ន ០៦ កម្ភុះ ២០១២

- គោលការណ៍ណែនាំស្តីពីការផ្តល់លេខអត្តសញ្ញាណវិនិយោគិន, លេខ ០០១/គ.ម.ក./គ.ណ.ន., ៦ ខែ កុម្ភៈ ២០១២។
- គោលការណ៍ណែនាំស្តីពីយន្តការទទួលបញ្ជាជួញដូរមូលបត្រ, លេខ ១៥២គ.ម.ក./គ.ណ.ន., ១៧ មីនា ២០១៤។
- គោលការណ៍ណែនាំស្តីពីនីតិវិធីនៃការទូទាត់សាច់ប្រាក់នៅក្នុងទីផ្សារមូលបត្រ,លេខ ០០៣/១២ គ.ម .ក.ស.ជ.ណ., ១៤ កុម្ភៈ ២០១៤។


➢ **សៀវភៅស្រាវជ្រាវ និងអត្ថបទផ្សេងៗ**


- សៀវភៅព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រ ប្រចាំត្រីមាសទី៣ និងទី៤ ឆ្នាំ២០១៩
- កែប សំភី, ការត្រៀមខ្លួនមុនជួញដូរ, (មេរៀនសម្រាប់ឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)
- កែប សំភី, ប្រភេទមូលបត្រ, (មេរៀនសម្រាប់ឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)
- កែប សំភី, ប្រតិបតិការផាត់ទាត់ ទូទាត់មូលបត្រ និងការរក្សាទុក, (មេរៀនសម្រាប់ឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)


➢ **ឯកសារសារណា និងរបាយការណ៍បញ្ចប់ការសិក្សារ**


- ម៉ន ម៉ារ៉ាឌី(២០១៩), ប្រតិបតិការទីផ្សារមូលបត្រកម្ពុជា, សាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ចិត្ត ជានិត និងវង្ស ស្រីលុច្ប(២០១៩),ការអភិវឌ្ឍន៏ទីផ្សារមូលបត្របំណុលនៅកម្ពុជា , សាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- លឹម វិភា(២០១៨), ដំណើរការទីផ្សារមូលបត្រកម្ពុជា, សាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- អ៊ួន រិទ្ធី(២០១៩), យុទ្ធសាស្ត្រជំរុញទីផ្សារមូលបត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា, សាកលវិទ្យាល័យតន្ត្រីវិជ្ជា
- ស៊ូ សុជា និងអ៊ុង នីតា(២០១៥), «ការវិនិយោគលើមូលបត្រនៅផ្សារមូលបត្រកម្ពុជា និងការវិភាគលើភាគហ៊ុន» សាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)


➢ **គេហទំព័រ**

- សុន្ទានុក្រម "ការអប់រំអំពីមូលបត្រ" http://www.secc.gov.kh/khmer/m75.php?pn=2 (ចូលទស្សនាថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២០)
- ទិដ្ឋភាពទូទៅមូលបត្រអាចជួញដូរ(NCD) "គោលនយោបាយរូបិយវត្ថុ https://www.nbc.org.kh/monetary_policy/ncds_overview.php (ចូលទស្សនាថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០)
- National Bank to Begin LPCO (October 17, 2016) https://www.khmertimeskh.com/61232/national-bank-to-begin-lpco/ (ចូលទស្សនាថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២០)
- https://www.nbc.org.kh/english/news_and_events/news_info.php?id=230 (ចូលទស្សនាថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២០)
- https://www.investopedia.com/terms/c/corporatebond.asp#:~:text=A%20corporate%20bond%20is%20debt,trade%20on%20the%20secondary%20market.,Investopedia , Corporate Bond (ចូលទស្សនាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០)
- សំនួរ-ចម្លើយ "ការអប់រំអំពីមូលបត្រ" http://www.secc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០)
- រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញា "អំពី គ.ម.ក" http://www.secc.gov.kh/khmer/m11.php?pn=1 (ចូលទស្សនាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០)
- មូលបត្របំណុល "ផលិតផល និងសេវាកម្ម" http://csx.com.kh/kh/product/bond.jsp?MNCD=4040 (ចូលទស្សនាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០)
- http://csx.com.kh/news/faq/listPosts.do?MNCD=7060 (ចូលទស្សនាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០)
- ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ "អ្នកចូលរួមទីផ្សារ" http://www.secc.gov.kh/khmer/m59.php?pn=6 (ចូលទស្សនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០)
- ចក្ខុវិស័យ និងបេសកកម្ម "អំពី គ.ម.ក" http://www.secc.gov.kh/khmer/m11.php?pn=1 (ចូលទស្សនាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០)

- គោលដៅ និងគោលបំណង, ការអប់រំពីមូលបត្រ
  http://www.secc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០)
- គេហទំព័រគណៈកម្មការមូលបត្រកម្ពុជា ( http://www.secc.gov.kh ) (ចូលទស្សនាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០)
- ទិដ្ឋភាពទូទៅរបស់ផ.ម.ក "អំពីផ.ម.ក"
  http://csx.com.kh/kh/about/profile.jsp?MNCD=10301 (ចូលទស្សនាថ្ងៃទី ខែ ឆ្នាំ២០២០)
- ចក្ខុវិស័យ និងបេសកកម្ម, "អំពី ផ.ម.ក."
  http://csx.com.kh/kh/about/mission.jsp?MNCD=1020 (ចូលទស្សនាថ្ងៃទី ខែ ឆ្នាំ២០២០)
- ការបើកគណនី និង នីតិវិធីក្នុងការជួញដូរ, ប្រតិបត្តិការរបស់ ផ.ម.ក
  http://csx.com.kh/operation/market/listPosts.do?MNCD=30201 (ចូលទស្សនាថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០)
- ទិដ្ឋភាពទូទៅនៃការជួញដូរ, ប្រតិបត្តិការរបស់ ផ.ម.ក.
  http://csx.com.kh/operation/market/listPosts.do?MNCD=30201 (ចូលទស្សនាថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០)
- គេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ប្រតិបត្តិការទីផ្សារ៖ ម៉ោងជួញដូរ
- http://csx.com.kh/operation/market/listPosts.do?MNCD=30201 (ចូលទស្សនាថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០)

# ឧបសម្ព័ន្ធទី១៖

# អនុក្រឹត្យស្តីពី ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...០១...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-** គោលបំណង

អនុក្រឹត្យនេះមានគោលបំណងលើកទឹកចិត្តពន្ធដារ ដើម្បីអភិវឌ្ឍវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-** គោលដៅ

អនុក្រឹត្យនេះមានគោលដៅកំណត់ពីប្រភេទ សកម្មភាព និងលក្ខខណ្ឌនានា ដែលជាកម្មវត្ថុនៃការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដូចមានចែងក្នុងមាត្រា១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩។

**មាត្រា៣.-** វិសាលភាព

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះ÷

១. ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**) និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។

២. អ្នកវិនិយោគសាធារណៈ ដែលកាន់កាប់ និង/ឬ ទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលដែលបានបោះផ្សាយលក់ជាសាធារណៈ និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។ សម្រាប់គោលដៅនៃអនុក្រឹត្យនេះ អ្នកវិនិយោគសាធារណៈរួមបញ្ចូលទាំងអ្នកវិនិយោគនិវាសនជន និងអនិវាសនជន។

## ជំពូកទី២
## សកម្មភាព និងលក្ខខណ្ឌនៃការលើកទឹកចិត្តពន្ធដារ

**មាត្រា៤.-** ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលចំពោះក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ៣(បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវបំពេញបែបបទជូនអគ្គនាយកដ្ឋានពន្ធដារតាមរយៈ **គ.ម.ក.** នៅរាល់មុនការិយបរិច្ឆេទបង់ពន្ធសម្រាប់ឆ្នាំសារពើពន្ធនីមួយៗ ដើម្បីទទួលបាននូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូលចំនួន ៥០ (ហាសិប) ភាគរយ នៃពន្ធលើប្រាក់ចំណូលត្រូវបង់ក្នុងរយៈពេលនៃការទទួលបានការលើកទឹកចិត្តពន្ធដារ ដូចមានកំណត់ក្នុងកថាខណ្ឌទី២ នៃមាត្រា៤ នៃអនុក្រឹត្យនេះ។

ការលើកទឹកចិត្តពន្ធដារមានរយៈពេល ៣ (បី) ឆ្នាំ និងត្រូវគិតចាប់ផ្តើមពី÷

១- ដើមឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ដើមឆ្នាំជាប់ពន្ធនោះ។

២- ដើមឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ចុងឆ្នាំជាប់ពន្ធ។

៣- អំឡុងពេលណាមួយដែលទទួលបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៥.-** **ការអនុគ្រោះបំណុលពន្ធចំពោះក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ**

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវទទួលបានការអនុគ្រោះបំណុលពន្ធដែលរួមបញ្ចូលពន្ធលើប្រាក់ចំណូលទាំងស្រុង ពន្ធកាត់ទុក អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករស្នាក់នៅ អាករបំភ្លឺសាធារណៈ។ ការអនុគ្រោះបំណុលពន្ធទាំងស្រុងត្រូវអនុវត្តដូចខាងក្រោម÷

១- បំណុលពន្ធចាប់ពីកាលបរិច្ឆេទN-3 ដល់N-10 សម្រាប់ក្រុមហ៊ុន/ សហគ្រាសដែលបានបំពេញលក្ខខណ្ឌក្នុងការចុះបញ្ជីនៅទីផ្សារគោល។

២- បំណុលពន្ធចាប់ពីកាលបរិច្ឆេទ N-2 ដល់ N-10 សម្រាប់សហគ្រាសធុនតូច និងមធ្យមដែលបានបំពេញលក្ខខណ្ឌក្នុងការចុះបញ្ជីនៅទីផ្សារកំណើន។ (ឆ្នាំ N គឺជាឆ្នាំដែលក្រុមហ៊ុន/ សហគ្រាសធ្វើការបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលជាសាធារណៈជាលើកដំបូង។)

ការបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ និងចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត មិនតម្រូវឱ្យមានការធ្វើសវនកម្មពេញលេញជាមុនពីអគ្គនាយកដ្ឋានពន្ធដារនោះទេ។ សម្រាប់ការស្នើសុំបោះផ្សាយ ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ត្រូវផ្ដល់ជូន **គ.ម.ក.** នូវវិញ្ញាបនបត្របញ្ជាក់កាតព្វកិច្ចពន្ធ ចេញដោយអគ្គនាយកដ្ឋានពន្ធដារ ដែលជាលិខិតសម្រាប់បញ្ជាក់ពីការប្រកាស និងបង់ពន្ធជាប្រចាំដោយមិនទាន់រង់ការធ្វើសវនកម្មពីអគ្គនាយកដ្ឋានពន្ធដារ។

**មាត្រា៦.-** ការលើកទឹកចិត្តពន្ធកាត់ទុកដល់អ្នកវិនិយោគមូលបត្រ

អ្នកវិនិយោគសាធារណៈត្រូវទទួលបានការបន្ថយពន្ធកាត់ទុក ៥០ (ហាសិប) ភាគរយ លើការប្រាក់ និង/ ឬ ភាគលាភ ដែលបានមកពីការកាន់កាប់ និង/ ឬ ការទិញ- លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលសម្រាប់រយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។

បុគ្គលជាភ្នាក់ងារកាត់ទុកដែលធ្វើការបើកការប្រាក់ និង/ ឬ ភាគលាភ ត្រូវធ្វើការគណនាប្រាក់ពន្ធកាត់ទុកដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ មុនការបើកប្រាក់ និងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធ ទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ (ម្ភៃ) នៃខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុក។

**គ.ម.ក.** និងអគ្គនាយកដ្ឋានពន្ធដារ ត្រូវពិនិត្យជាមួយគ្នាលើអត្រាពន្ធកំណត់លើការប្រាក់នៃមូលបត្របំណុលនេះ និងស្នើសុំការពិនិត្យសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៧.-** ក្រុមហ៊ុន/ សហគ្រាសដែលមិនត្រូវបានទទួលការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល

ក្រុមហ៊ុន/ សហគ្រាសមិនត្រូវទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងមាត្រា ៤ និងមាត្រា៥ នៃអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុននោះជាសហគ្រាសវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលកំពុងស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៨.-** ការបញ្ឈប់ការលើកទឹកចិត្តពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារអាចស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈ **គ.ម.ក.** ដើម្បីបញ្ឈប់ការលើកទឹកចិត្តពន្ធដារដូចមានចែងក្នុងមាត្រា៤ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ ក្នុងករណីក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត÷

- មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ និងបង់ប្រាក់ពន្ធ តាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ។

- មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធ និងបង់ប្រាក់ពន្ធតាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ។ លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ ត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ដោយក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវានៅក្នុងវិស័យមូលបត្រ រួមមាន តារាងតុល្យការ គណនីលទ្ធផល តារាងចលនាសាច់ប្រាក់ និងកំណត់សម្គាល់ដោយមិនឱ្យហួសពីរយៈពេល ៣ (បី) ខែ ក្រោយពីដំណាច់ឆ្នាំសារពើពន្ធ។
- មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើសវនកម្មលើបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ។
- មិនបានបង់ពន្ធអាករទាំងអស់ ពន្ធបន្ថែម និងការប្រាក់ ដែលបានកំណត់សម្រាប់រយៈពេលជាប់ពន្ធដែលបានធ្វើសវនកម្មរួចដោយរដ្ឋបាលសារពើពន្ធ។

ក្នុងករណីក្រុមហ៊ុន/ សហគ្រាសដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងអនុក្រឹត្យនេះ មិនបានអនុវត្តតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងវិស័យមូលបត្រ**គ.ម.ក.** អាចស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីបញ្ឈប់ការលើកទឹកចិត្ត ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៤ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ។

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត មិនត្រូវទទួលបាននូវការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុន/ សហគ្រាសនោះបានដកខ្លួនចេញពីការចុះបញ្ជីជួញដូរមូលបត្រ ឬត្រូវបានដកពីការចុះបញ្ជីជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រប្រតិស្រុត។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា៩.-** ការលើកទឹកចិត្តពន្ធដារចំពោះក្រុមហ៊ុន/ សហគ្រាសដែលបានបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈរួច

ក្រុមហ៊ុន/ សហគ្រាសដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** ធ្វើការបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ និងដែលបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុតរួចហើយ តែមិនទាន់ទទួលបាននូវការលើកទឹកចិត្តពន្ធដារនោះ ត្រូវបានផ្តល់ការលើកទឹកចិត្តពន្ធដារ ដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ។

**មាត្រា១០.-** ការជំនួស

បញ្ញត្តិទាំងឡាយដែលចេញឡើងស្របតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ ២០១៥ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យមូលបត្រ នឹងត្រូវបន្តអនុវត្តអនុលោមតាមអនុក្រឹត្យនេះ។

**មាត្រា១១..** ការអនុវត្ត

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មការមូលបត្រកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកអគ្គនាយកដ្ឋានពន្ធដារ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១៣កើតខែមិគសិរឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែមករា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
  នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា ១១ "ដើម្បីអនុវត្ត"
- គ្រប់ក្រសួង-ស្ថាប័ន
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី២៖ ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់សារពើពន្ធ

ព្រះរាជក្រម

នស/រកម/០៣០៣/០១០

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឱ្យប្រើ

ច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីសារពើពន្ធ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាល ទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ១ ដែលមានសេចក្ដីទាំងស្រុងដូចតទៅ :



មាត្រាមួយ .—

មាត្រា ៣ មាត្រា ៩ មាត្រា ១៣ មាត្រា ២០ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៥ មាត្រា ២៦ មាត្រា ២៧ មាត្រា ២៨ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៧ មាត្រា ៤២ មាត្រា ៤៩ មាត្រា ៩៥ និងមាត្រា ១០៤ នៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ :

មាត្រា ៣ .— ថ្មី

សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីសារពើពន្ធ :

១-ពាក្យ "អ្នកជាប់ពន្ធនិវាសនជន" សំដៅដល់ :

ក-រូបវន្តបុគ្គលដែលមានទីលំនៅអចិន្ត្រៃយ៍ ឬមានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ថ្ងៃ នៅក្នុងរយៈពេល ១២ ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្ត

ខ-នីតិបុគ្គលឬក្រុមអាជីវកម្ម ដែលត្រូវបានបង្កើតឬត្រូវបានគ្រប់គ្រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានកន្លែងប្រកបអាជីវកម្ម ជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-ពាក្យ "អ្នកជាប់ពន្ធអនិវាសនជន" មានន័យថា បុគ្គលណាមួយដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជនតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ និងទទួលប្រាក់ចំណូលប្រភពកម្ពុជា ។

៣-ពាក្យ "នីតិបុគ្គល" សំដៅដល់សហគ្រាសឬអង្គការនានា ដែលប្រកបអាជីវកម្មទោះបីជាបានឬមិនទាន់បានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្តី ។ ពាក្យ "នីតិបុគ្គល" រួមបញ្ចូលផងដែរនូវស្ថាប័នរដ្ឋាភិបាលអង្គការសាសនា អង្គការសប្បុរសធម៌ឬអង្គការមិនស្វែងរកចំណេញ ។ ចំពោះបុគ្គលអនិវាសនជនពាក្យ "នីតិបុគ្គល" សំដៅដល់គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ពាក្យ "នីតិបុគ្គល" ពុំរាប់បញ្ចូលនូវក្រុមអាជីវកម្មឬសហគ្រាសឯកបុគ្គល ។

៤-ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" សំដៅដល់ទីកន្លែងប្រកបអាជីវកម្មជាប់លាប់នៅព្រះរាជាណាចក្រកម្ពុជា សាខារបស់ក្រុមហ៊ុនបរទេស ឬភ្នាក់ងារនិវាសនជននៅព្រះរាជាណាចក្រកម្ពុជា ដែលតាមរយៈនេះ បុគ្គលអនិវាសនជនប្រកបអាជីវកម្មរបស់ខ្លួន ។ ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" រួមបញ្ចូលផងដែរនូវសមាគម ឬរូបភាពទំនាក់ទំនងផ្សេងទៀតដែលតាមរយៈនេះបុគ្គលអនិវាសនជនធ្វើសកម្មភាពសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ។

៥-ពាក្យ "ក្រុមអាជីវកម្ម" សំដៅដល់ក្រុមសមូហនាមដែលមានម្ចាស់ភាគទុនជារូបវន្តបុគ្គលនិវាសនជនយ៉ាងច្រើន ១០នាក់ ហើយក្នុងនោះចំណែកសមាមាត្ររបស់ម្ចាស់ភាគទុននៅក្នុងខ្ទង់មូលធន ប្រាក់ចំណេញនិងការខាតបង់ត្រូវស្របតាមលក្ខណៈវិនិច្ឆ័យដែលត្រូវកំណត់ដោយអនុក្រឹត្យ ។ ក្នុងនិយមន័យនេះ "ក្រុមអាជីវកម្ម" មិនអាចជាសមាជិករបស់ក្រុមហ៊ុនបុគ្គលណាមួយ ហើយក៏មិនរាប់បញ្ចូលផងនូវក្រុមហ៊ុនដើមទុនគ្រឹះស្ថានអចិន្ត្រៃយ៍ឬសហគ្រាសឯកបុគ្គល ។

៦-ពាក្យ "សហគ្រាសឯកបុគ្គល" សំដៅដល់សហគ្រាសអាជីវកម្មដែលជាកម្មសិទ្ធិ ១០០ ភាគរយ របស់រូបវន្តបុគ្គលណាម្នាក់ ។ ក្នុងនិយមន័យនេះ ប្ដី ប្រពន្ធនិងកូនក្នុងបន្ទុកត្រូវចាត់ទុកថាជារូបវន្តបុគ្គលតែម្នាក់ ។

៧-ពាក្យ "អាជីវកម្ម" សំដៅដល់សកម្មភាពសេដ្ឋកិច្ចរបស់បុគ្គលដែលមានគោលដៅទាញយកប្រាក់ចំណូលអំពីការផលិតនិងលក់ទំនិញ ការផ្គត់ផ្គង់សេវាកម្មការជួលឬការលក់ទ្រព្យសម្បត្តិឬសកម្មភាពផ្សេងទៀត ។

៨-ពាក្យ "ភាគលាភ" សំដៅដល់ចំណែកជាសាច់ប្រាក់ឬជាទ្រព្យដែលនីតិ-បុគ្គលបានចែកឱ្យអ្នកចូលហ៊ុនទៅតាមកម្រិតនៃភាគកម្មរបស់ខ្លួន នៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល លើកលែងតែភាគលាភជាប័ណ្ណភាគហ៊ុននិងការបែងចែកនានាក្នុងពេលជំរះបញ្ជីរំលាយក្រុមហ៊ុនទាំងស្រុង ។ ចំណែកណាមួយដែលចាត់ទុកថាជាភាគលាភឬមិនមែនជាភាគលាភត្រូវផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះ ដោយពុំគិតថានីតិបុគ្គលមានឬគ្មានប្រាក់ចំណូល ឬប្រាក់ចំណេញចរន្ត ឬលទ្ធផលយោងសាជាថ្មីឡើយ ។



៩-ពាក្យ "អ្នកចូលហ៊ុន" សំដៅដល់បុគ្គលដែលមានចំណែកភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល ។ សម្រាប់គោលដៅនៃពន្ធនេះ នីតិបុគ្គលណាមួយ ទោះបីមិនមែនជាក្រុមហ៊ុនដើមទុនក្តីត្រូវចាត់ទុកដូចជាក្រុមហ៊ុនដើមទុន ហើយបុគ្គលដែលមានចំណែកភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល ឬក៏បុគ្គលអាចបានទទួលប្រាក់ចំណូល ឬប្រាក់ចំណេញក្នុងឋានៈជាអ្នកបានចូលរួមក្នុងនីតិបុគ្គលនោះ ត្រូវចាត់ទុកថាជាអ្នកចូលហ៊ុនរបស់នីតិបុគ្គលដែរ ។

១០-ពាក្យ "បុគ្គលទាក់ទិន" សំដៅដល់ :

ក-សមាជិកណាម្នាក់ក្នុងគ្រួសារអ្នកជាប់ពន្ធ

ខ-សហគ្រាសដែលគ្រប់គ្រងលើអ្នកជាប់ពន្ធ ឬសហគ្រាសត្រូវបានអ្នកជាប់ពន្ធគ្រប់គ្រង ឬក៏សហគ្រាសនោះនិងអ្នកជាប់ពន្ធស្ថិតនៅក្រោមការគ្រប់គ្រងរួមគ្នា ។ ពាក្យ "គ្រប់គ្រង" មានន័យថាមានកម្មសិទ្ធិ ចាប់ពី ៥១ ភាគរយ ឡើងទៅលើតម្លៃ ឬសិទ្ធិបោះឆ្នោតនៃភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់សហគ្រាស ។ ដើម្បីកំណត់ទំហំនៃការគ្រប់គ្រងរបស់អ្នកជាប់ពន្ធជារូបវន្តបុគ្គលណាម្នាក់ ត្រូវគិតបញ្ចូលទាំងអស់នូវកម្មសិទ្ធិលើភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់រូបវន្តបុគ្គលនោះ និងកម្មសិទ្ធិផ្ទាល់ឬប្រយោលរបស់សហព័ទ្ធអ្នកជាប់ពន្ធ។

១១-ពាក្យ "អ្នកវិនិយោគ" មានន័យថា បុគ្គលណាមួយដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

១២-ពាក្យ "គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់" មានន័យថា គម្រោងវិនិយោគដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទទួលស្គាល់ថាជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

**មាត្រា ៩ — ថ្មី**

ប្រាក់ចំណូលលើកលែងពន្ធត្រូវបានកំណត់ដូចតទៅ :

១-វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយនិងលើកលែងតែប្រាក់ចំណូលដែលត្រូវជាប់ពន្ធតាមមាត្រា ២២ នៃច្បាប់នេះ ពន្ធលើប្រាក់ចំណេញមិនត្រូវអនុវត្តចំពោះ

ក-ប្រាក់ចំណូលរបស់រាជរដ្ឋាភិបាល ឬប្រាក់ចំណូលស្ថាប័នរាជរដ្ឋា-ភិបាល

ខ-ប្រាក់ចំណូលរបស់អង្គការណាមួយដែល :

-ត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅតែមួយគត់ខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬអប់រំ

-គ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន

គ-ប្រាក់ចំណូលរបស់អង្គការពលករ ឬសភាពាណិជ្ជកម្ម ឧស្សាហកម្ម ឬកសិកម្ម ក្នុងករណីដែលប្រាក់ចំណូលរបស់អង្គការទាំងនោះមិនត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុនឬរូបវន្តបុគ្គល

ឃ-ប្រាក់ចំណេញដែលបានមកពីការលក់ផលិតផលកសិកម្ម ដែលបុគ្គលមិនមែនជាអ្នកជាប់ពន្ធតាមរបបពិតផលិតបានដោយខ្លួនឯង ទោះបីផលិតផលនោះមិនទាន់កែច្នៃឬកែច្នៃហើយក៏ដោយ ទៅតាមទម្លាប់នៃការងារកសិកម្ម ។ ប្រតិបត្តិការតាមមធ្យោបាយឧស្សាហកម្មរួមទាំងការកែច្នៃ ការរក្សាគុណភាព ការវេចខ្ចប់សម្រាប់លក់ពុំត្រូវបានចាត់ទុកជាទម្លាប់នៃការងារកសិកម្មឡើយ

ង-ភាគលាភដែលបានទទួលមកពីសហគ្រាសនិវាសនជន ក្នុងករណីដែលប្រាក់ពន្ធត្រូវបង់តាមមាត្រា ២០ថ្មី មាត្រា ២៣ថ្មី និងមាត្រា ២៦ថ្មី នៃច្បាប់នេះត្រូវបានបង់រួចរាល់ ។

២-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវកំណត់ដោយប្រកាសអំពីនីតិវិធីនៃការស្នើសុំលើកលែងពន្ធ ភាពបាត់បង់លក្ខណៈលើកលែងពន្ធ ការប្រកាសសារពើពន្ធ និងការចុះបញ្ជី ។

**មាត្រា ១៣ _ ថ្មី**

១-លក្ខខណ្ឌនៃរំលស់ធម្មតានៃទ្រព្យរូបីមានដូចតទៅ :

# ឧបសម្ព័ន្ធទី៣៖ ប្រកាសស្តីពី គោលការណ៍ណែនាំស្តីពី ការធ្វើប៊ិកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ:.....០០២/១២...គ.ម.ក/គ.ល.ន.

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១២

# គោលការណ៍ណែនាំ
# ស្តីពី
# ការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ

អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០០៧, អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសរបស់គណៈកម្មការមូលបត្រកម្ពុជា លេខ ០០១ គ.ម.ក. ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ព្រមទាំងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធដទៃទៀត និងដើម្បីសម្រួលដល់ការយល់ដឹង ធានាឱ្យការអនុវត្តប្រកបដោយរលូន និងមានប្រសិទ្ធិភាពក្នុងដំណើការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង គណៈកម្មការមូល-បត្រកម្ពុជា **(គ.ម.ក.)** សូមចេញនូវគោលការណ៍ណែនាំស្តីពីការធ្វើប៊ុកបៀលឌីង (Book-Building) និងការធ្វើបរិវិសកម្ម (Subscription) មូលបត្រកម្មសិទ្ធិ ដូចខាងក្រោម÷

## ក.ដំណាក់កាលប៊ុកបៀលឌីង:

**១)** បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ពីគណៈកម្មការមូលបត្រកម្ពុជា លើសំណើសុំបោះ-ផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើប៊ុកបៀលឌីង ដោយត្រូវធ្វើការប្រកាសផ្សព្វផ្សាយជាសាធារណៈ ដើម្បីអញ្ជើញវិនិយោគិន ឱ្យចូលរួម។

**២)** ដើម្បីជំរុញឱ្យវិនិយោគិន ចូលរួមយ៉ាងសកម្មក្នុងដំណើរការប៊ុកបៀលឌីង ក្នុងគោលដៅធានាថាថ្លៃមូលបត្រកម្មសិទ្ធិ បានឆ្លុះបញ្ចាំងតម្រូវការទីផ្សារ មូលបត្រកម្មសិទ្ធិដែលត្រូវដាក់ឱ្យធ្វើប៊ុកបៀលឌីងមានចំនួន ៧០ (ចិតសិប) ភាគរយ នៃមូលបត្រកម្មសិទ្ធិសរុប ដែលនៅសល់បន្ទាប់ពីការលៃបំរុងទុកសម្រាប់លក់ជូនបុគ្គលិក ករណីក្រុមហ៊ុនបោះផ្សាយមានគោលនយោបាយលើកទឹកចិត្ត តាមរយៈការលក់មូលបត្រកម្មសិទ្ធិជូនបុគ្គលិក។ ដោយឡែកចំណែកនៃមូលបត្រកម្មសិទ្ធិដែលនៅសល់ចំនួន ៣០

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

(សាមសិប) ភាគរយ ទៀត គឺត្រូវលៃបំរុងទុកសម្រាប់ការធ្វើបរិវិសកម្ម ដោយវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង។

៣) វិនិយោគិន ដែលបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង ត្រូវបំពេញពាក្យស្នើសុំចូលរួមប៊ុក-បៀលឌីង (Book-Building Form) ដែលកំណត់ដោយគណៈកម្មការមូលបត្រកម្ពុជា។ វិនិយោគិនត្រូវជ្រើសរើសថ្លៃមួយក្នុងចន្លោះថ្លៃ (Price Range) នៃថ្លៃមូលបត្រកម្មសិទ្ធិ ក្នុងឯកសារផ្ដល់ព័ត៌មានដែលទទួលបានការអនុញ្ញាតជាគោលការណ៍ពីគណៈកម្មការមូលបត្រកម្ពុជា ព្រមទាំងចំនួនមូលបត្រកម្មសិទ្ធិដែលមានបំណងចង់ធ្វើបរិវិសកម្ម បន្ទាប់ពីបញ្ចប់ដំណាក់កាលនៃការធ្វើប៊ុកបៀលឌីងនេះ។

៤) វិនិយោគិន ដែលបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង ត្រូវតម្កល់ប្រាក់កក់ស្មើនឹង ១០ (ដប់) ភាគរយនៃថ្លៃមូលបត្រកម្មសិទ្ធិសរុប ដែលបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង។

៥) ក្រោយដំណើរការប៊ុកបៀលឌីងត្រូវបានបញ្ចប់ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវកំណត់ថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ (Offering Price) ដើម្បីស្នើសុំការសម្រេចពីគណៈកម្មការមូលបត្រកម្ពុជា និងភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យ។

៦) វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង សំដៅដល់វិនិយោគិនដែលបានដាក់ថ្លៃខ្ពស់ជាង ឬស្មើ ថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ (Offering Price)។ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវគណនាថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ដោយប្រើប្រាស់បច្ចេកទេសថ្លឹងរកមធ្យមភាគ (Weighted-Average) លើមូលដ្ឋានថ្លៃ និងចំនួនមូលបត្រកម្មសិទ្ធិ ដែលវិនិយោគិនបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង។

៧) ថ្លៃមូលបត្រកម្មសិទ្ធិដែលបានគណនាក្នុងកថាខណ្ឌទី ៦ ខាងលើ អាចត្រូវបានធ្វើការកែតម្រូវ (Adjustment) ដើម្បីឱ្យឆ្លើយតបទៅនឹងស្ថានភាពទីផ្សារ ដោយមានការសម្រេចពីគណៈកម្មការមូល-បត្រកម្ពុជា។

៨) ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវធ្វើការជូនដំណឹងភ្លាមដល់វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យ បន្ទាប់ពីគណៈកម្មការមូលបត្រកម្ពុជា បានផ្ដល់ការអនុញ្ញាត និងចុះបញ្ជីឯកសារផ្ដល់ព័ត៌មាន។ ជាមួយគ្នានេះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្ទេរប្រាក់កក់ ១០ (ដប់) ភាគរយ ជូនវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងវិញ ឬរក្សាទុកក្នុងករណីវិនិយោ-គិនមិនទទួលបានជោគជ័យក្នុងការធ្វើប៊ុកបៀលឌីង មានបំណងបន្តធ្វើបរិវិសកម្ម។

## ខ.ដំណាក់កាលនៃការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ:

**៩)** វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង អាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ លើសពីចំនួនដែលមានដាក់ក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង ដោយត្រូវធ្វើការតម្កល់ប្រាក់បន្ថែម ដើម្បីបង្គ្រប់ទៅតាមទំហំនៃបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលបានធ្វើ។

**១០)** វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ដែលមានបំណងបន្តធ្វើបរិវិសកម្ម អាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដោយត្រូវធ្វើការតម្កល់ប្រាក់បន្ថែម ដើម្បីបង្គ្រប់ទៅតាមទំហំនៃបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើ។

**១១)** វិនិយោគិនដែលមិនបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង អាចចូលរួមធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដោយត្រូវតម្កល់ប្រាក់កក់យ៉ាងតិច ១០០ (មួយរយ) ភាគរយ នៃទំហំមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្ម។

**១២)** វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ត្រូវដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ ក្នុងរយៈពេលធ្វើបរិវិសកម្ម ករណីមានវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង បានធ្វើបរិវិ-សកម្មលើសពីចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបំរុងសម្រាប់ធ្វើប៊ុកបៀលឌីង ហើយមានវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ប៉ុន្តែមិនទាន់ដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម វិនិយោគិននោះអាចមិនដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម និងអាចដកប្រាក់កក់ ១០ (ដប់) ភាគរយវិញបាន។

**១៣)** ករណីការធ្វើបរិវិសកម្មដោយវិនិយោគិនដែលបានទទួលជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនលើសពីចំនួននៃមូលបត្រកម្មសិទ្ធិដែលបានលៃបំរុងសម្រាប់ធ្វើប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនដែលដាក់ពាក្យធ្វើបរិវិសកម្ម តាមវិធានប្រូរ៉ាតា (Pro Rata)។

**១៤)** ករណីវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងមានចំនួនច្រើនលើសលុប ដោយមានទាំង វិនិយោគិនជានីតិបុគ្គល ឬ/និង វិនិយោគិនជារូបវន្តបុគ្គល ហើយបានដាក់ពាក្យធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិក្នុងចំនួនច្រើនលើសលុប លើសពីចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបំរុងសម្រាប់ធ្វើប៊ុកបៀលឌីង នោះគណៈកម្មការមូលបត្រកម្ពុជា អាចពិនិត្យធ្វើការបែងចែកក្នុងចំនួនមិនលើសពី ពីរភាគបី (២/៣) នៃមូលបត្រកម្មសិទ្ធិដែលត្រូវបានលៃបំរុងសម្រាប់វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង ហើយផ្ទេរទៅបន្ថែមក្នុងចំណែកនៃមូលបត្រកម្មសិទ្ធិ ដែលត្រូវបានលៃបំរុងសម្រាប់ធ្វើប៊ុកបៀលឌីង ដើម្បីបែងចែកជូនដល់វិនិយោគិនដែលបានដាក់ពាក្យធ្វើបរិវិសកម្មក្នុងចំនួនដ៏ច្រើនលើសលុបនោះ។

**១៥)** បន្ទាប់ពីការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ ក្នុងករណីមានអ្នកធ្វើបរិវិសកម្មមិនទទួលបានមូលបត្រកម្មសិទ្ធិតាមការដាក់ពាក្យស្នើសុំ នោះក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវធ្វើការផ្ទេរសាច់ប្រាក់ ដែលនៅសល់ពីការធ្វើបរិវិសកម្ម ជូនអ្នកធ្វើបរិវិសកម្មពាក់ព័ន្ធនោះវិញ។

**១៦)** ករណីវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង បានដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម ហើយការធ្វើបរិវិសកម្មនេះ មានចំនួនតិចជាងចំនួននៃមូលបត្រកម្មសិទ្ធិដែលបានលៃបំរុងសម្រាប់ធ្វើប៊ុកបៀលឌីង វិនិយោគិនទាំងអស់ដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ត្រូវធ្វើបរិវិសកម្មមូល-បត្រកម្មសិទ្ធិយ៉ាងតិចស្មើនឹងប្រាក់កក់ ១០ (ដប់) ភាគរយ។

**១៧)** ករណីការធ្វើបរិវិសកម្មដោយវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនតិចជាងចំនួននៃមូលបត្រកម្មសិទ្ធិដែលបានលៃបំរុងសម្រាប់ធ្វើប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងតាមការស្នើសុំ។ ចំនួនមូលបត្រកម្មសិទ្ធិដែលនៅសល់ ត្រូវធ្វើការបែង-ចែកទៅឱ្យវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង។

**១៨)** ករណីចំនួនមូលបត្រកម្មសិទ្ធិសរុបដែលបានស្នើសុំធ្វើបរិវិសកម្ម ដោយវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនលើសពីចំនួននៃមូលបត្រកម្មសិទ្ធិ ដែលត្រូវបានលៃបំរុងទុកសម្រាប់គោលដៅនេះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនតាមវិធានប្រូរ៉ាតា (Pro Rata)។

**១៩)** ករណីចំនួនមូលបត្រកម្មសិទ្ធិសរុបដែលបានស្នើសុំធ្វើបរិវិសកម្ម ដោយវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនទាបជាងចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវបានលៃបំរុងទុកសម្រាប់គោលដៅនេះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនទៅតាមការស្នើសុំធ្វើបរិវិសកម្ម ហើយមូលបត្រកម្មសិទ្ធិដែលនៅសល់ ត្រូវបែងចែកទៅឱ្យវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ករណីវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង បានធ្វើបរិវិ-សកម្មមូលបត្រកម្មសិទ្ធិ លើសពីចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវលៃបំរុងទុកសម្រាប់ការធ្វើប៊ុកបៀលឌីង។

**២០)** ករណីមានមូលបត្រកម្មសិទ្ធិដែលនៅសល់បន្ទាប់ពីការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដូចមានចែង ក្នុងគោលការណ៍ណែនាំនេះ ក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវទិញមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់។

**២១)** ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្ម ហើយដាក់ជូន **គ.ម.ក.** ភ្លាម ដើម្បីសុំការពិនិត្យ និងសម្រេច។

**គណៈកម្មការមូលបត្រកម្ពុជា**